ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# គោលនយោបាយជាតិ

# ស្តីពី

# ការអភិវឌ្ឍជនបទ ឆ្នាំ២០២៥-២០៣៥

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី
ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៥

# បុព្វកថា

ប្រទេសកម្ពុជាទទួលបានសន្តិភាពពេញលេញក្រោមការដឹកនាំដ៏ត្រឹមត្រូវរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាមគ្គុទេសក៍ឯកនិងប្រតិបត្តិករនយោបាយឈ្នះ ឈ្នះ ដែលសម្រេចបានសុខសន្តិភាព ឯកភាពជាតិពេញលេញ និងការអភិវឌ្ឍគ្រប់វិស័យ។ រាជរដ្ឋាភិបាលក្នុងនីតិកាលកន្លងមក ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី បច្ចុប្បន្នជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ  និងជាប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា បានអនុវត្តដោយជោគជ័យនូវយុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណទាំងបួនដំណាក់កាល ដែលបានធ្វើឱ្យប្រទេសជាតិមានភាពរីកចម្រើនលើគ្រប់វិស័យ និងបានប្រែក្លាយពីប្រទេសក្រីក្របំផុតមកជាប្រទេសមានចំណូលមធ្យមកម្រិតទាបក្នុងឆ្នាំ២០១៥ និងបានធ្វើសមាហរណកម្មចូលទៅក្នុងតំបន់និងអន្តរជាតិ ព្រមទាំងបានធ្វើឱ្យកិត្យានុភាពកម្ពុជាលេចឡើងខ្ពស់ត្រដែតលើឆាកអន្តរជាតិគួរជាទីមោទនៈ។

ជាមួយនឹងសមិទ្ធផលខាងលើនេះ រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា បានបន្តយកចិត្តទុកដាក់ថែរក្សាសមិទ្ធផលជាប្រវត្តិសាស្ត្រ ដែលបានកសាងឡើងដោយរាជរដ្ឋាភិបាលនីតិកាលកន្លងមក ជាពិសេសការថែរក្សាឱ្យបានគង់វង្សយូរអង្វែងនូវសុខសន្តិភាព ស្ថិរភាពនយោបាយ ឯករាជ្យ អធិបតេយ្យភាព និងបូរណភាពទឹកដី ដែលបានមកដោយការខិតខំយ៉ាងលំបាកបំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និងឥស្សរជនស្នេហាជាតិជាច្រើនរូបទៀត។ ទន្ទឹមគ្នានេះ រាជរដ្ឋាភិបាលកំពុងបន្តខិតខំអភិវឌ្ឍប្រទេសជាតិឱ្យកាន់តែរីកចម្រើនបន្ថែមទៀត ដោយបានដាក់ចេញនូវកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ក្រោមបាវចនា : កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព ដោយកំណត់អាទិភាពគន្លឹះចំនួន៥គឺ មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា(ឌីជីថល) ដើម្បីឆ្ពោះទៅសម្រេចបានចក្ខុវិស័យ «**កម្ពុជាក្លាយជាប្រទេសមានប្រាក់ចំណូលខ្ពស់ក្នុងឆ្នាំ២០៥០**»។

ដើម្បីរួមចំណែកក្នុងការសម្រេចបាននូវចក្ខុវិស័យខាងលើនេះ រាជរដ្ឋាភិបាលចាំបាច់ត្រូវរៀបចំ «**គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនបទ ឆ្នាំ២០២៥-២០៣៥**» ដោយកំណត់ចក្ខុវិស័យ «**កសាងសង្គមជនបទកម្ពុជាឱ្យមានវិបុលភាពប្រកបដោយបរិយាបន្ន សមធម៌ និងចីរភាព**» និងមានគោលបំណងធ្វើឱ្យ «**ប្រជាជននៅតំបន់ជនបទមានជីវភាពរស់នៅសមរម្យប្រកបដោយភាពធន់ មានសុខភាពមាំមួន រស់នៅក្នុងបរិស្ថានល្អប្រកបដោយចីរភាព និងមានសេចក្តីថ្លៃថ្នូរ**» ដោយផ្តោតទៅលើការអភិវឌ្ឍតំបន់ជនបទឱ្យឆ្លើយតបទៅនឹងតម្រូវការជាអាទិភាព ប្រកបដោយតុល្យភាព ភាពធន់ បរិយាបន្ន និងនិរន្តរភាព ដែលនឹងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ កាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់គុណភាព និងគុណតម្លៃនៃជីវិតរស់នៅរបស់ប្រជាជននៃព្រះរាជាណាចក្រកម្ពុជា។

គោលនយោបាយនេះ ត្រូវបានរៀបចំឡើងដោយមានការសិក្សាស្រាវជ្រាវនិងវិភាគស៊ីជម្រៅអំពីស្ថានភាពជនបទនៅកម្ពុជា និងផ្អែកលើបទពិសោធល្អៗនៃការងារអភិវឌ្ឍន៍ជនបទ ព្រមទាំងជាតុចូលពីគ្រប់តួអង្គពាក់ព័ន្ធ ដើម្បីឆ្លើយតបទៅនឹងលក្ខខណ្ឌនិងតម្រូវការអភិវឌ្ឍន៍ជនបទ ស្របតាមបរិការណ៍សេដ្ឋកិច្ចសង្គមនៃប្រទេសកម្ពុជា។

ក្នុងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំសូមសម្តែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះក្រសួងអភិវឌ្ឍន៍ជនបទ ដែលបានខិតខំប្រឹងប្រែងយកអស់កម្លាំងកាយចិត្តនិងប្រាជ្ញាស្មារតី ក្នុងការរៀបចំ «**គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនបទ ឆ្នាំ២០២៥-២០៣៥**» ដ៏មានសារៈសំខាន់នេះ ប្រកបដោយភាពប្រទាក់ក្រឡា គ្រប់ជ្រុងជ្រោយ និងជាក់ស្តែងនិយម សំដៅធ្វើការអភិវឌ្ឍតំបន់ជនបទនៃព្រះរាជាណាចក្រកម្ពុជាឱ្យមានភាពរីកចម្រើន ប្រកបដោយភាពធន់ បរិយាបន្ន និងចីរភាព។

ទន្ទឹមគ្នានេះ ខ្ញុំសូមណែនាំក្រសួង ស្ថាប័នពាក់ព័ន្ធថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ សហគមន៍មូលដ្ឋានជនបទ ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងសប្បុរសជននានា ចូលរួមសហការឱ្យបានពេញលេញរួមគ្នាជាសហថាមពល ដើម្បីអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនបទ ឆ្នាំ២០២៥-២០៣៥ នេះឱ្យទទួលបានលទ្ធផលល្អប្រសើរប្រកបដោយប្រសិទ្ធភាពនិងសក្តិសិទ្ធិភាពខ្ពស់។

ខ្ញុំនឹងបន្តតាមដានការអនុវត្តគោលនយោបាយនេះ ដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងវិស័យអភិវឌ្ឍន៍ជនបទឱ្យមានប្រសិទ្ធភាពនិងប្រសិទ្ធផលខ្ពស់ ដើម្បីជាឧត្តមប្រយោជន៍ជាតិ និងប្រជាជនកម្ពុជា។

ថ្ងៃអង្គារ ១២កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

# មាតិកា


បុព្វកថា ... i

មាតិកា ... iii

បញ្ជីអក្សរកាត់ ... iv

**១- សេចក្ដីផ្ដើម** ... ១

**២- ការអភិវឌ្ឍជនបទ ស្ថានភាព បញ្ហា ការប្រឈម និងកាលានុវត្តភាព** ... ៣

២.១- ការអភិវឌ្ឍជនបទ ... ៣

២.២- ស្ថានភាពជនបទនៃប្រទេសកម្ពុជា ... ៥

២.៣- បញ្ហា ការប្រឈម និងកាលានុវត្តភាព ... ១០

**៣- ចក្ខុវិស័យ** ... ១៥

**៤- គោលបំណងនិងគោលដៅ** ... ១៥

៤.១- គោលបំណង ... ១៥

៤.២- គោលដៅ ... ១៥

**៥- យុទ្ធសាស្ត្រ** ... ១៥

**៦- ផែនការសកម្មភាព** ... ១៨

៦.១- ការបង្កើតយន្តការ ... ១៨

៦.២- ការបង្កើតក្របខ័ណ្ឌគតិយុត្ត ... ១៨

៦.៣- ការគាំទ្រហិរញ្ញវត្ថុ ... ១៨

៦.៤- ការបណ្ដុះបណ្ដាលធនធានមនុស្ស ... ១៨

៦.៥- ដំណើរការអនុវត្តន៍ ... ១៨

**៧- ការតាមដាននិងការវាយតម្លៃ** ... ២០

**៨- សេចក្ដីសន្និដ្ឋាន** ... ២០

**បរិសិដ្ឋ** ... ២២

បរិសិដ្ឋ១ : សទ្ទានុក្រម ... ២២

បរិសិដ្ឋ២ : ផែនទីបង្ហាញទីតាំងតំបន់ភូមិសាស្ត្រទាំង៤ នៃប្រទេសកម្ពុជា ... ២៦

បរិសិដ្ឋ៣ : តារាងម៉ាទ្រិកយុទ្ធសាស្ត្រ និងវិធានការគន្លឹះសម្រាប់ការអនុវត្តគោលនយោបាយ ... ២៧

បរិសិដ្ឋ៤ : ក្របខ័ណ្ឌគោលនយោបាយជាតិស្ដីពីការអភិវឌ្ឍជនបទ ឆ្នាំ២០២៥-២០៣៥ ... ៤១

បរិសិដ្ឋ៥ : វិធីសាស្ត្រអនុវត្តន៍កម្មវិធីអាទិភាពនៃគោលនយោបាយ ... ៤៣

**ឧបសម្ព័ន្ធ** ... ៤៥

ឧបសម្ព័ន្ធ១ : ទស្សនាទាននិងគោលការណ៍អភិវឌ្ឍន៍ជនបទ ... ៤៥

ឧបសម្ព័ន្ធ២ : តារាងទិន្នន័យគ្រួសារក្រ១ ក្រ២ និងគ្រួសារងាយរងគ្រោះតាមខេត្ត ... ៤៨

ឧបសម្ព័ន្ធ៣ : ហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទក្រាលកៅស៊ូមួយជាន់ ពីរជាន់ បេតុង និងផ្លូវល្បាយគ្រួស ... ៥០

ឧបសម្ព័ន្ធ៤ : អត្រាគ្របដណ្ដប់ទឹកស្អាតតាមគ្រួសារ និងអនាម័យកម្រិតមូលដ្ឋានតាមខ្នងផ្ទះ ... ៥២

# បញ្ជីអក្សរកាត់

| | | |
|---|---|---|
| ADB | : | Asian Development Bank<br>ធនាគារអភិវឌ្ឍន៍អាស៊ី |
| AFD | : | Agence Francaise De Developpement<br>ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង |
| AIIB | : | Asian Infrastructure Investment Bank<br>ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី |
| CSES | : | Cambodia Social and Economic Survey<br>អង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា |
| EIB | : | European Investment Bank<br>ធនាគារវិនិយោគអឺរ៉ុប |
| EU | : | European Union<br>សហភាពអឺរ៉ុប |
| IFAD | : | International Fund for Agricultural Development<br>មូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍកសិកម្ម |
| JICA | : | Japan International Cooperation Agency<br>ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន |
| KfW | : | Kreditanstalt fur Wiederaufbau<br>សហភាពឥណទានសម្រាប់កសាងឡើងវិញ |
| KOICA | : | Korea International Cooperation Agency<br>ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ |
| ODF | : | Open Defecation Free<br>បញ្ចប់ការបន្ទោបង់ពាសវាលពាសកាល |
| ODF Plus | : | Open Defecation Free Plus<br>បញ្ចប់ការបន្ទោបង់ពាសវាលពាសកាលកម្រិតខ្ពស់ |
| WB | : | World Bank<br>ធនាគារពិភពលោក |

## ១- សេចក្តីផ្តើម

ក្រោមម្លប់សុខសន្តិភាពជាង២៦ឆ្នាំចុងក្រោយ ព្រះរាជាណាចក្រកម្ពុជាបានប្រែក្លាយពីប្រទេសក្រីក្រមកជាប្រទេសមានការអភិវឌ្ឍ តាមមាគ៌ាលទ្ធិប្រជាធិបតេយ្យ និងបានធ្វើសមាហរណកម្មចូលទៅក្នុងតំបន់និងអន្តរជាតិគួរជាទីមោទនៈ។ ប្រទេសកម្ពុជាធ្លាប់បានឆ្លងកាត់ភ្លើងសង្គ្រាមតាំងពីឆ្នាំ១៩៧០ ដោយសារវិបត្តិនយោបាយ និងបានធ្លាក់ទៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ របបនេះបានលុបបំបាត់សិទ្ធិ សេរីភាព កម្មសិទ្ធិឯកជន ផ្សារ សាលារៀន មន្ទីរពេទ្យ វត្តអារាម បង្ខំប្រជាជនឱ្យធ្វើការធ្ងន់ហួសកម្លាំង គ្មានអាហារគ្រប់គ្រាន់ រស់ក្នុងស្ថានភាពក្រីក្រតោកយ៉ាកបំផុត មានជំងឺប្រចាំកាយ គ្មានទីជម្រក និងព្រាត់ប្រាសក្រុមគ្រួសារ ព្រមទាំងបានកាប់សម្លាប់ប្រជាជនស្លូតត្រង់ និងបញ្ញវន្តអស់ជាង៣លាននាក់យ៉ាងអយុត្តិធម៌និងព្រៃផ្សៃបំផុត។ បច្ច័យអវិជ្ជមាននៃសង្គ្រាម បានធ្វើឱ្យប្រទេសធ្លាក់ក្នុងភាពទុរគតនិងខ្ទេចខ្ទាំ បន្សល់ទុកនូវស្ត្រីមេម៉ាយ ក្មេងកំព្រា ជនមានពិការភាព និងអនក្ខរជន។

ដោយសារអំពើព្រៃផ្សៃរបស់របបប៉ុលពត ទើបចលនារណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ត្រូវបានបង្កើតឡើងដោយក្រុមអ្នកស្នេហាជាតិនៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨ និងបានតស៊ូ លះបង់ បូជាជីវិត ដើម្បីផ្តួលរំលំរបបប៉ុលពតដោយទទួលបានជ័យជម្នះនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ ក្រោយថ្ងៃរំដោះ រដ្ឋាភិបាលដឹកនាំដោយឥស្សរជនស្នេហាជាតិ បានខិតខំរកគ្រប់មធ្យោបាយ ដើម្បីទប់ស្កាត់ការវិលត្រឡប់នៃរបបប្រល័យពូជសាសន៍ដែលនៅសេសសល់ផង និងដោះស្រាយភាពអត់ឃ្លានរបស់ប្រជាជនផង ទោះបីស្ថិតក្រោមគំនាបនយោបាយ និងទណ្ឌកម្មសេដ្ឋកិច្ចពីបរទេសក៏ដោយ។ នៅក្នុងស្ថានភាពដ៏លំបាកនោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានយល់ឃើញថា សង្គ្រាមបានបំផ្លាញអ្វីៗគ្រប់យ៉ាងដល់ឫសគល់ ពុំមានឱកាសអភិវឌ្ឍប្រទេសជាតិឡើយ ហើយមិនអាចយកសង្គ្រាមទៅបញ្ចប់សង្គ្រាមបានទេ។ ដូច្នេះ មានតែការចរចាធ្វើសម្បទានឱ្យគ្នាទៅវិញទៅមក ដោយតម្កល់ផលប្រយោជន៍ជាតិជាធំតែប៉ុណ្ណោះ ទើបអាចបញ្ចប់សង្គ្រាមបាន។

ជាមួយនឹងទស្សនៈសន្តិភាពនិយម និងឧត្តមគតិស្នេហាជាតិដ៏ខ្ពង់ខ្ពស់នេះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានចាប់ផ្តើមស្វែងរកឱកាសចរចាជាមួយខ្មែរគ្រប់ភាគីចាប់ពីឆ្នាំ១៩៨៧ រហូតបានចុះកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសនាថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១។ លទ្ធផលជាប្រវត្តិសាស្ត្រនេះបាននាំឱ្យខ្មែរគ្រប់ភាគី(ភាគីរដ្ឋកម្ពុជា ភាគីខ្មែរក្រហម ភាគីហ៊្វុនស៊ិនប៉ិច និងភាគីសឺនសាន) ដែលមានកម្លាំងប្រដាប់អាវុធគ្រប់គ្រងតំបន់ផ្សេងៗគ្នា ជាពិសេសនៅតាមព្រំដែនជាមួយប្រទេសថៃ ឯកភាពគ្នា និងចូលរួមបោះឆ្នោតជាសកលលើកទី១ នៅក្នុងឆ្នាំ១៩៩៣ តាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ក្រោមការសម្របសម្រួលនិងរៀបចំដោយអ៊ុនតាក់(UNTAC) ដោយបង្កើតបានជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាន់យករបបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ។

ប៉ុន្តែជាអកុសល កម្ពុជាមិនអាចទទួលបានសន្តិភាពពេញលេញនៅឡើយទេ ព្រោះភាគីខ្មែរក្រហមមិនគោរពតាមកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស និងមិនចូលរួមក្នុងដំណើរការបោះឆ្នោត ហើយបានបន្តកាន់កាប់និងបង្កសង្គ្រាមនៅតាមតំបន់មួយចំនួនដូចជាប៉ៃលិន សំឡូត អន្លង់វែង ឱរ៉ាល់ ភ្នំវល្លិ៍ជាដើម។ ស្ថិតក្នុងកាលៈទេសៈនោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានដាក់ចេញនិងអនុវត្តនូវយុទ្ធសាស្ត្រ **«ឈ្នះ ឈ្នះ»** ដោយផ្អែកលើគោលការណ៍គន្លឹះចំនួនបី គឺរក្សាអាយុជីវិត រក្សាតួនាទីនិងអាជីព និងរក្សាទ្រព្យសម្បត្តិ និងកម្មសិទ្ធិ ដើម្បីចរចានិងអូសទាញភាគីខ្មែរក្រហមឱ្យវិលមកចូលរួមរស់ជាមួយរាជរដ្ឋាភិបាល និងបានឈានទៅរំលាយអង្គការចាត់តាំងខ្មែរក្រហមទាំងស្រុង ព្រមទាំងបានធ្វើសមាហរណកម្មកម្លាំងទ័ពខ្មែរក្រហមចូលក្នុងក្របខ័ណ្ឌកងយោធពលខេមរភូមិន្ទតែមួយនៅក្នុងឆ្នាំ១៩៩៨។ នៅក្នុងបុព្វហេតុពន្លត់ភ្លើងសង្គ្រាម និងកសាងសន្តិភាព

ប្រកបដោយជោគជ័យជាប្រវត្តិសាស្ត្រនេះ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់យកថ្ងៃទី២៩ ខែធ្នូ ជាថ្ងៃរំលឹកគុណសន្តិភាពសម្រាប់ប្រជាជាតិកម្ពុជាទាំងមូលដោយប្រសិទ្ធនាម «**ទិវាសន្តិភាពនៅកម្ពុជា**»។

នយោបាយ«**ឈ្នះ ឈ្នះ**» បាននាំយកសន្តិភាពពេញលេញជូនប្រជាជនកម្ពុជានៅទូទាំងប្រទេស ហើយបានចាប់ផ្តើមបើកទំព័រប្រវត្តិសាស្ត្រថ្មីសម្រាប់ការអភិវឌ្ឍប្រទេស ដើម្បីកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់កិត្យានុភាពជាតិឡើងវិញ។ នៅក្នុងដំណើរការអភិវឌ្ឍន៍ប្រទេសឡើងវិញនេះ រាជរដ្ឋាភិបាលបានពង្រឹងនិងពង្រីកនយោបាយការទូត ធ្វើសមាហរណកម្មចូលក្នុងតំបន់និងអន្តរជាតិ និងកែទម្រង់ផ្ទៃក្នុងជាបន្តបន្ទាប់។ ទន្ទឹមគ្នានេះ រាជរដ្ឋាភិបាលពីមួយអាណត្តិទៅមួយអាណត្តិ បានដាក់ចេញនូវកម្មវិធីនយោបាយ យុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណទាំង៤ដំណាក់កាល គោលនយោបាយអភិវឌ្ឍន៍ជាតិ គោលនយោបាយអភិវឌ្ឍន៍តាមវិស័យ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ព្រមទាំងខិតខំប្រឹងប្រែងអនុវត្តប្រកបដោយប្រសិទ្ធភាព និងសក្តិសិទ្ធិភាព រហូតទទួលបានភាពរីកចម្រើនលើគ្រប់វិស័យគួរជាទីមោទនៈ ដូចបានឃើញជាក់ស្តែងនាពេលបច្ចុប្បន្ននេះ។

ទោះជាយ៉ាងណា ប្រទេសកម្ពុជានៅមានបញ្ហានិងការប្រឈមជាច្រើនទៀតលើវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវិស័យការពារជាតិ ព្រមទាំងជំងឺរាតត្បាតសកល ដូចជាជំងឺរាតត្បាតកូវីដ-១៩ជាដើម ដែលតម្រូវឱ្យមានការអភិវឌ្ឍខ្លាំងក្លាបន្ថែមទៀតលើគ្រប់វិស័យ ជាពិសេសនៅតំបន់ជនបទដែលមានប្រជាជនរស់នៅភាគច្រើនលើសលប់ ដូចជាការអភិវឌ្ឍធនធានមនុស្ស ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត(ផ្លូវ ទឹក អគ្គិសនី) អនាម័យ បរិស្ថាន ការងារ និងមុខរបរ ដើម្បីលើកកម្ពស់សេដ្ឋកិច្ច សង្គមកិច្ច សុខភាព វប្បធម៌ បរិស្ថានរស់នៅក្នុងតំបន់ជនបទទូទៅ និងតំបន់ដីសម្បទានសង្គមកិច្ចសម្រាប់ប្រជាជនក្រីក្រខ្វះដី និងកងកម្លាំងឈរជើងតាមព្រំដែន ព្រមទាំងគ្រួសារអតីតយុទ្ធជន រួមទាំងសហគមន៍ជនជាតិដើមភាគតិចផងដែរ ដើម្បីកសាងសង្គមជនបទឱ្យមានផាសុកភាពនិងសុខដុមនីយកម្ម ពោលគឺប្រជាជនមានជីវភាពសមរម្យ មានសុខភាពល្អ រស់នៅក្នុងបរិស្ថានល្អ និងសេចក្តីថ្លៃថ្នូរ។

ក្នុងការបន្តបេសកកម្មអភិវឌ្ឍន៍ប្រទេសទៅអនាគត រាជរដ្ឋាភិបាលកម្ពុជាដែលកើតចេញពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ឆ្នាំ២០២៣ តាមមាគ៌ាលទ្ធិប្រជាធិបតេយ្យ សេរី និងពហុបក្ស ក្រោមការដឹកនាំបន្តវេនប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បាននិងកំពុងយកចិត្តទុកដាក់ថែរក្សាសមិទ្ធផលនានាដែលបានកសាងឡើងចាប់ពីថ្ងៃរំដោះ ៧ មករា ១៩៧៩ រហូតមកដល់បច្ចុប្បន្ន ជាពិសេសការពារសន្តិភាព និងស្ថិរភាពនយោបាយដែលរកបានដោយលំបាកបំផុតក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាមគ្គុទេសក៍ឯក និងប្រតិបត្តិករនយោបាយឈ្នះ ឈ្នះ។

រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា បាននិងកំពុងខិតខំបន្តការអភិវឌ្ឍប្រទេសឱ្យរីកចម្រើនបន្ថែមទៀតដោយបានដាក់ចេញនូវ**យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១** ក្រោមបាវចនា : កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព ដែលមានអាទិភាពគន្លឹះចំនួន៥គឺ មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា(ឌីជីថល) និងគោលដៅជាយុទ្ធសាស្ត្រចំនួន៥គឺ (ទី១) ធានាកំណើនសេដ្ឋកិច្ច (ទី២) បង្កើតការងារឱ្យបានកាន់តែច្រើន (ទី៣) សម្រេចឱ្យបាននូវគោលដៅកាត់បន្ថយភាពក្រីក្រឱ្យនៅក្រោម១០% (ទី៤) បន្តពង្រឹងសមត្ថភាពអភិបាលកិច្ច និងលើកកម្ពស់គុណភាពស្ថាប័ន និង(ទី៥) ធានាឱ្យបាននូវចីរភាពនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ដើម្បីឆ្ពោះទៅសម្រេចបានចក្ខុវិស័យ «**កម្ពុជាក្លាយជាប្រទេសមានប្រាក់ចំណូលខ្ពស់ក្នុងឆ្នាំ២០៥០**»។

ផ្អែកលើយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ រាជរដ្ឋាភិបាលបានកំណត់គោលនយោបាយអាទិភាពចំនួន៦ រួមមាន(ទី១) ការផ្តល់ការថែទាំសុខភាពឆ្ពោះទៅរកកម្មវិធីគ្របដណ្តប់សុខភាពជាសកល (ទី២) ការបណ្តុះ

បណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសដល់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យនៅទូទាំងប្រទេស (ទី៣) ការធ្វើស្ថាបនូបនីយកម្មកម្មវិធីជាតិជំនួយសង្គមសម្រាប់គ្រួសារក្រីក្រ និងក្រុមជនងាយងាយរងគ្រោះនៅក្នុងគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យនៅក្នុងគ្រាមានវិបត្តិសេដ្ឋកិច្ចនិងគ្រាមានគ្រោះអាសន្ន (ទី៤) ការដាក់ចេញនិងការជំរុញអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ចក្រៅប្រព័ន្ធឱ្យមានលទ្ធភាពចូលរួមក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធនិងអាចទទួលបានផលប្រយោជន៍ពីប្រព័ន្ធគាំពារសង្គមផ្លូវការ (ទី៥) ការដាក់ចេញនូវយន្តការសម្របសម្រួល និងកម្មវិធីហិរញ្ញប្បទាន សំដៅលើកស្ទួយផលិតកម្ម រកទីផ្សារ និងរក្សាលំនឹងថ្លៃកសិផលសំខាន់ៗក្នុងកម្រិតសមរម្យ តាមរយៈការដាក់ចេញកញ្ចប់ថវិកាដាក់លាក់ (ទី៦) ការដាក់ពង្រាយមន្ត្រីបច្ចេកទេសកសិកម្មទៅគ្រប់ឃុំសង្កាត់ ដែលមានសកម្មភាពកសិកម្មនៅទូទាំងប្រទេស។ រាជរដ្ឋាភិបាលក៏បានរៀបចំ **«គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនបទ ឆ្នាំ២០២៥-២០៣៥»** ដើម្បីជាត្រីវិស័យតម្រង់ទិសលើកិច្ចការអភិវឌ្ឍន៍ជនបទនៃប្រទេសកម្ពុជាឱ្យឆ្លើយតបទៅនឹងតម្រូវការអាទិភាពរបស់ប្រជាជនដែលរស់នៅក្នុងភូមិសាស្ត្រផ្សេងៗគ្នា ជាអាទិ៍ តំបន់ទំនាបកណ្តាល តំបន់ជុំវិញបឹងទន្លេសាប តំបន់ឆ្នេរសមុទ្រ និងតំបន់ខ្ពង់រាបនិងភ្នំ ឱ្យមានប្រសិទ្ធភាពនិងសក្តិសិទ្ធិភាពខ្ពស់ និងប្រកបដោយតុល្យភាព ភាពធន់ បរិយាបន្ន និងចីរភាព ពិសេសផ្តោតលើការអភិវឌ្ឍតំបន់ជនបទនៅតាមបន្ទាត់ព្រំដែន ដើម្បីកសាងព្រំដែនសន្តិភាព មិត្តភាព សហប្រតិបត្តិការ និងអភិវឌ្ឍន៍។

គោលនយោបាយជាតិនេះបង្កើតឡើងដោយមានការសិក្សាលើទស្សនាទាន និងគោលការណ៍អភិវឌ្ឍន៍ជនបទសំខាន់ៗ(ឧបសម្ព័ន្ធ១) ការអភិវឌ្ឍជនបទទូទៅ និងស្ថានភាពជនបទនៃប្រទេសកម្ពុជា ដើម្បីកំណត់ចក្ខុវិស័យ គោលបំណង គោលដៅ យុទ្ធសាស្ត្រ ផែនការសកម្មភាព និងវិធីសាស្ត្រអនុវត្តន៍ ដែលគ្របដណ្តប់ទៅលើវិសាលភាពតំបន់ជនបទ ដែលជាតំបន់ស្ថិតនៅក្រៅរង្វង់ទីក្រុង និងមានប្រជាជនប្រកបរបរកសិកម្មលើសពី៥០% ឬមានដង់ស៊ីតេប្រជាជនតិចជាង២០០នាក់/គម២ (CSES 2021)។

## ២- ការអភិវឌ្ឍជនបទ ស្ថានភាពជនបទ បញ្ហា ការប្រឈម និងកាលានុវត្តភាព

ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍជនបទ និងសមស្របទៅនឹងបរិបទនៃប្រទេសកម្ពុជាបានគ្រប់ជ្រុងជ្រោយ ការរៀបចំគោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនបទ ឆ្នាំ២០២៥-២០៣៥ ចាំបាច់ត្រូវតែស្វែងយល់ពីសកម្មភាពអភិវឌ្ឍន៍ជនបទសំខាន់ៗដែលត្រូវបានអនុវត្តជាទូទៅ និងស្ថានភាពតំបន់ជនបទជាក់ស្តែងនៃប្រទេសកម្ពុជាដូចខាងក្រោម៖

### ២.១- ការអភិវឌ្ឍជនបទ

ការអភិវឌ្ឍជនបទនៅក្នុងប្រទេសនីមួយៗអាស្រ័យទៅលើភូមិសាស្ត្រ ប្រជាសាស្ត្រ ធនធាន សេដ្ឋកិច្ចសង្គម វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ ជំនឿជាដើម ហើយតែងមានការផ្លាស់ប្តូរទៅតាមការវិវត្តឬការប្រែប្រួលនៃព្រឹត្តិការណ៍នយោបាយ សេដ្ឋកិច្ចសង្គម បច្ចេកវិទ្យា បរិស្ថាន និងកត្តាផ្សេងៗទៀត។ ជាក់ស្តែង សកម្មភាពអភិវឌ្ឍន៍ជនបទសំខាន់ៗមួយចំនួនត្រូវបានអនុវត្តនៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍដូចជា៖

- **ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនិងគមនាគមន៍ជនបទ** : ហេដ្ឋារចនាសម្ព័ន្ធនិងគមនាគមន៍ជនបទត្រូវបានចាត់ទុកជាសរសៃឈាមសេដ្ឋកិច្ចដ៏សំខាន់ក្នុងការផ្សារភ្ជាប់សកម្មភាពធុរកិច្ចផ្សេងៗនៅក្នុងតំបន់ជនបទ។ ជាមួយគ្នានេះ ការផ្គត់ផ្គង់អគ្គិសនីនិងទឹក ក៏ជាកត្តាចាំបាច់នៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គមជនបទ។ ជាក់ស្តែង រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់អភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធគ្រប់ប្រភេទនៅទូទាំងប្រទេស ក្នុងនោះក្រសួងអភិវឌ្ឍន៍ជនបទ បានស្ថាបនា កែលម្អ និងថែទាំផ្លូវជនបទគ្រប់ប្រភេទរួមទាំងសំណង់សិល្បការ្យផ្សេងៗនៅទូទាំងប្រទេសសរុបប្រវែងប្រមាណ៥ម៉ឺនគ.ម. តភ្ជាប់ទៅដល់គ្រប់ភូមិឋានដែលមានប្រជាជនរស់នៅ

- **ការកែលម្អសេវាសង្គមជនបទ ដើម្បីលើកកម្ពស់សុខភាព អនាម័យ និងបរិស្ថានល្អ** : ការលើកកម្ពស់សេវាសង្គម គឺជាទិដ្ឋភាពសំខាន់នៃការអភិវឌ្ឍជនបទ ដើម្បីលើកកម្ពស់លក្ខខណ្ឌរស់នៅ និងគុណភាពជីវិតរបស់ប្រជាជន ក្នុងនោះសុខភាពគឺជាកត្តាចាំបាច់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងធនធានមនុស្ស។ ជាក់ស្តែង រាជរដ្ឋាភិបាលកម្ពុជាបានខិតខំផ្តល់សេវាសាធារណៈលើគ្រប់វិស័យ និងបានលើកកម្ពស់គុណភាពសេវាជាបន្តបន្ទាប់ ដើម្បីផ្តល់ផលប្រយោជន៍ដល់ប្រជាជនឱ្យបានល្អប្រសើរ ក្នុងនោះក្រសួងអភិវឌ្ឍន៍ជនបទបានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្គត់ផ្គង់ទឹកស្អាតនិងលើកកម្ពស់អនាម័យជនបទ
- **ការអភិវឌ្ឍកសិកម្មប្រកបដោយនិរន្តរភាព** : នាពេលបច្ចុប្បន្ន មានការយកចិត្តទុកដាក់កាន់តែខ្លាំងឡើងទៅលើការអនុវត្តកសិកម្មដែលមានភាពធន់ កសិកម្មសរីរាង្គ និងការចិញ្ចឹមសត្វជាដើម ដោយអភិរក្សធនធានធម្មជាតិនិងជីវៈចម្រុះ ដើម្បីធានាសន្តិសុខស្បៀង និងសុខភាពប្រជាជន។ រាជរដ្ឋាភិបាលបានពង្រាយមន្ត្រីកសិកម្មនៅគ្រប់ឃុំសង្កាត់ និងបានដាក់ចេញនូវយុទ្ធសាស្ត្រនានា ដើម្បីពង្រឹងវិស័យកសិកម្មនៅតាមឃុំសង្កាត់ ក្នុងគោលដៅបង្កើនប្រាក់ចំណូលគ្រួសារនិងផ្គត់ផ្គង់ទីផ្សារ។ ក្រសួងអភិវឌ្ឍន៍ជនបទក៏បានចូលរួមចំណែកលើការងារនេះ តាមរយៈសកម្មភាពអភិវឌ្ឍន៍សហគមន៍ជនបទចម្រុះ រួមមានការបណ្តុះបណ្តាលជំនាញដាំដុះ និងចិញ្ចឹមសត្វលក្ខណៈគ្រួសារ ព្រមទាំងចែកពូជសត្វនិងពូជដំណាំផ្សេងៗផងដែរ
- **ការធ្វើពិពិធកម្មសកម្មភាពសេដ្ឋកិច្ច** : ការអភិវឌ្ឍជនបទត្រូវផ្តោតទៅលើការធ្វើពិពិធកម្មប្រភពចំណូល រួមទាំងការបង្កើតឱកាសការងារ បណ្តុះបណ្តាលជំនាញ លើកកម្ពស់សិប្បកម្ម ទេសចរណ៍ និងឧស្សាហកម្មសេវាកម្មផ្សេងៗនៅក្នុងមូលដ្ឋាន។ រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងយកចិត្តទុកដាក់លើការធ្វើពិពិធកម្មសេដ្ឋកិច្ច ដើម្បីបង្កើនប្រាក់ចំណូលនិងឱកាសការងារនៅទូទាំងប្រទេស។ ដោយឡែក ក្រសួងអភិវឌ្ឍន៍ជនបទបានអនុវត្តសកម្មភាពបណ្តុះបណ្តាលជំនាញបំណិនជីវិតមូលដ្ឋាន និងសហគ្រិនភាព ព្រមទាំងគាំទ្រលើការកែច្នៃផលិតផលក្នុងមូលដ្ឋានសម្រាប់ការប្រើប្រាស់ក្នុងគ្រួសារនិងទីផ្សារផងដែរ
- **ការអភិវឌ្ឍចម្រុះ ចលនាភូមិមួយផលិតផលមួយ និងចលនាភូមិគំរូ** : ការអភិវឌ្ឍចម្រុះ **ចលនាភូមិមួយផលិតផលមួយ និងចលនាភូមិគំរូ** ដោយមានការចូលរួមពីសហគមន៍មូលដ្ឋាន ប្រកបដោយសាមគ្គីភាព ភាពឧស្សាហ៍ព្យាយាម និងភាពជាម្ចាស់ ត្រូវបានលើកទឹកចិត្តនៅក្នុងដំណើរការនៃការអភិវឌ្ឍជនបទ។ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយជាតិស្តីពីការជំរុញចលនាភូមិមួយផលិតផលមួយ និងបានអនុវត្តសាកល្បងនូវគម្រោងអភិវឌ្ឍន៍ភូមិគំរូនៅតំបន់ជនបទ ជាពិសេសនៅក្នុងនីតិកាលទី៧ ការជំរុញការអភិវឌ្ឍចម្រុះនិងការបន្តអនុវត្តចលនាភូមិមួយផលិតផលមួយ និងចលនាភូមិគំរូ។ ជាមួយគ្នានេះ ក្រសួងអភិវឌ្ឍន៍ជនបទ បានយកចិត្តទុកដាក់លើកិច្ចអភិវឌ្ឍន៍សហគមន៍ចម្រុះ និងគាំពារចលនាភូមិគំរូ ដែលបច្ចុប្បន្ននេះបានទទួលស្គាល់ភូមិគំរូចំនួន៣០ និងកំពុងអភិវឌ្ឍភូមិចំនួន៣៤ ព្រមទាំងបានដាក់ចេញនូវផែនការអភិវឌ្ឍភូមិគំរូឱ្យបានយ៉ាងតិច៥០ភូមិក្នុងមួយឆ្នាំ
- **ការធ្វើប្រទានកម្មដីរដ្ឋតាមរយៈកម្មវិធីដីសម្បទានសង្គមកិច្ចជូនប្រជាពលរដ្ឋក្រីក្រ** : ការបែងចែកដីលំនៅឋាន និងដីកសិកម្មដល់ប្រជាជនដែលខ្វះដីសម្រាប់រស់នៅ និងបង្កបង្កើនផល គឺជាការគាំពារ និងឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍ដ៏ចាំបាច់នៅតំបន់ជនបទ ដើម្បីបង្កើតមុខរបរចិញ្ចឹមជីវិត រកប្រាក់ចំណូលរក្សាលំនឹងជីវភាពរបស់ប្រជាជនក្រីក្រ។ រាជរដ្ឋាភិបាលបាននិងកំពុងអនុវត្តការធ្វើប្រទានកម្មដីរដ្ឋតាមរយៈកម្មវិធីដីសម្បទានសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធនិងគ្រួសារ គ្រួសារកងទ័ព និងនគរបាលជាតិតាមព្រំដែន ព្រមទាំងប្រជាពលរដ្ឋក្រីក្រស៊ីវិលទូទៅ និងកម្មវិធីផ្តល់ដីការពារព្រៃ ដើម្បី

រួមគ្នាអភិវឌ្ឍដោយចីរភាព។ ជាមួយគ្នានេះ ក្រសួងអភិវឌ្ឍន៍ជនបទបានចូលរួមគាំទ្រយ៉ាងសកម្មលើការងារអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្លូវ ការផ្គត់ផ្គង់ទឹកស្អាត អនាម័យ បណ្តុះបណ្តាលជំនាញបំណិនជីវិតមូលដ្ឋាន និងលើកកម្ពស់ជីវភាពប្រជាជននៅក្នុងសហគមន៍ជីសម្បទានសង្គមកិច្ចគ្រប់ប្រភេទផងដែរ

- **សមភាពយេនឌ័រ បរិយាបន្ន និងភាពធន់នឹងការប្រែប្រួលអាកាសធាតុ** : នៅក្នុងដំណើរការអភិវឌ្ឍន៍ជនបទដែលមានគុណភាពនិងប្រសិទ្ធភាព តែងតែមានការគិតគូរយ៉ាងទូលំទូលាយអំពីសារៈសំខាន់នៃសមភាពយេនឌ័រ សេចក្តីត្រូវការរបស់គ្រួសារក្រីក្រនិងគ្រួសារងាយរងគ្រោះ និងសារៈសំខាន់នៃភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ដើម្បីធានាថា ស្ត្រីមានសិទ្ធិនិងទទួលបានឱកាសការងារ និងប្រជាជនក្រីក្រនិងងាយរងគ្រោះ ដូចជាទារក កុមារ ស្ត្រីមានផ្ទៃពោះ ជនមានពិការភាព និងជនចាស់ជរាគ្មានទីពឹងជាដើម ត្រូវទទួលបានការគាំពារពីរាជរដ្ឋាភិបាល។ ក្រសួងអភិវឌ្ឍន៍ជនបទបានយកចិត្តទុកដាក់និងអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលផ្តោតការយកចិត្តទុកដាក់លើសមភាពយេនឌ័រ បរិយាបន្ន និងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ
- **ការអប់រំនិងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ជំនាញបំណិនជីវិត និងបង្កើតការងារ** : ការយកចិត្តទុកដាក់លើការអប់រំនិងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ជំនាញបំណិនជីវិតដល់ប្រជាពលរដ្ឋនៅតំបន់ជនបទ គឺជានិន្នាការមួយនៅក្នុងកិច្ចការអភិវឌ្ឍជនបទ ដើម្បីជួយឱ្យប្រជាពលរដ្ឋមានលំនឹងការងារ និងប្រាក់ចំណូល រស់នៅដោយសុខដុមនីយកម្ម ព្រមទាំងកាត់បន្ថយបាននូវការចំណាកស្រុកដោយប្រថុយប្រថាន។ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនិងបច្ចេកទេសដល់យុវជនមកពីគ្រួសារក្រីក្រនិងគ្រួសារងាយរងហានិភ័យចំនួន១,៥លាននាក់។ ជាមួយគ្នានេះ ក្រសួងអភិវឌ្ឍន៍ជនបទបានរួមចំណែកអនុវត្តសកម្មភាពបណ្តុះបណ្តាលជំនាញបំណិនជីវិតមូលដ្ឋាននៅតាមភូមិតំបន់ជនបទផងដែរ
- **បច្ចេកវិទ្យាឌីជីថល** : ការធ្វើសមាហរណកម្មបច្ចេកវិទ្យានៅក្នុងកម្មវិធីអភិវឌ្ឍន៍ជនបទ គឺជាកត្តាចាំបាច់ក្នុងសម័យបរិវត្តកម្មឌីជីថលនាពេលបច្ចុប្បន្ន។ ប្រព័ន្ធអ៊ីនធឺណិត និងអក្ខរកម្មឌីជីថលបានអនុញ្ញាតឱ្យសហគមន៍ជនបទទទួលបានអត្ថប្រយោជន៍ជាច្រើន ដូចជាពាណិជ្ជកម្មអេឡិចត្រូនិក ការអប់រំ សេវាសុខភាព និងសេវាផ្សេងៗតាមទូរសព្ទ ឬតាមប្រព័ន្ធផ្សព្វផ្សាយសង្គមផ្សេងៗ។ រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងផ្តោតលើបច្ចេកវិទ្យានិងឌីជីថលូបនីយកម្មនៅក្នុងការអភិវឌ្ឍប្រទេសលើគ្រប់វិស័យ។ ជាមួយគ្នានេះ ក្រសួងអភិវឌ្ឍន៍ជនបទបាននិងកំពុងយកចិត្តទុកដាក់លើឌីជីថលូបនីយកម្មសម្រាប់ការគ្រប់គ្រងការងារអភិវឌ្ឍន៍ជនបទ រួមទាំងការគ្រប់គ្រងមន្ត្រីរាជការ ការផ្សព្វផ្សាយសមិទ្ធផល ការធ្វើទំនាក់ទំនង ការរៀបចំនិងគ្រប់គ្រងទិន្នន័យសម្រាប់ការងារអភិវឌ្ឍន៍ជនបទ។

## ២.២- ស្ថានភាពជនបទនៃប្រទេសកម្ពុជា

### ២.២.១- សមិទ្ធផលនៃការអភិវឌ្ឍជនបទ

បច្ចុប្បន្នកម្ពុជាមានភាពរីកចម្រើនគួរឱ្យកត់សម្គាល់លើគ្រប់វិស័យ មានជាអាទិ៍វិស័យអប់រំ សុខាភិបាល ហិរញ្ញវត្ថុ កសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម ទេសចរណ៍ វប្បធម៌ សាសនា ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត(ផ្លូវ ស្ពាន ប្រឡាយ ទំនប់ អគ្គិសនី ផ្សារ សាលារៀន មន្ទីរពេទ្យ។ល។) ដែលបានធ្វើឱ្យអត្រានៃភាពក្រីក្រថយចុះជាលំដាប់ ពីអត្រាក្រីក្រ ស្មើរតែ១០០% នៅដើមទសវត្សទី៨០ មកនៅត្រឹម៤៧% ក្នុងឆ្នាំ២០០៤ ៣៣,៨% ក្នុងឆ្នាំ២០០៩ ២៦,៣% ក្នុងឆ្នាំ២០១៤ និងបន្តធ្លាក់ចុះមកដល់១៧,៨% ក្នុងឆ្នាំ២០២០។ ប៉ុន្តែដោយសារជំងឺកូវីដ-១៩ អត្រាក្រីក្របានកើនដល់៣២,១% ក្នុងឆ្នាំ២០២១ និងបានថយចុះមក២០,៦% វិញក្នុងឆ្នាំ២០២៣។

ជាមួយនឹងភាពរីកចម្រើនគួរឱ្យកត់សម្គាល់ខាងលើនេះ ក្រសួងអភិវឌ្ឍន៍ជនបទ ចាប់តាំងពីពេលបង្កើតឡើងដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ បានអនុវត្តតួនាទីនិងភារកិច្ចដែលកំណត់នៅក្នុងអនុក្រឹត្យលេខ៧៨ និងលេខ៥១ ដោយមានការចូលរួមយ៉ាងសកម្មពីដៃគូអភិវឌ្ឍនិងអង្គការមិនមែនរដ្ឋាភិបាល សម្រេចលទ្ធផលបានដូចខាងក្រោម៖

**ក- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងគមនាគមន៍ :** ការស្តារ ស្ថាបនា ថែទាំ និងកែលម្អ លើកកម្រិតហេដ្ឋារចនាសម្ព័ន្ធរូបវន្តជនបទ បាននិងកំពុងរួមចំណែកដល់កំណើនសេដ្ឋកិច្ចជាតិ។ ក្រសួងអនុវត្តតាមច្បាប់ផ្លូវថ្នល់ និងលិខិតបទដ្ឋានពាក់ព័ន្ធនានាក្នុងការស្ថាបនាផ្លូវជនបទ បានកែលម្អផ្លូវជនបទពីផ្លូវដីនិងផ្លូវល្បាយក្រួសឱ្យទៅជាផ្លូវក្រាលកៅស៊ូពីរជាន់និងក្រាលបេតុង ដែលបានបង្កលក្ខណៈងាយស្រួលក្នុងការធ្វើដំណើរ ដឹកជញ្ជូនបង្កើតមុខរបរ និងជួយឱ្យប្រជាជននៅតំបន់ជនបទមានភាពងាយស្រួលក្នុងការទទួលបានសេវាសាធារណៈនានា។ ផ្អែកលើបញ្ជីសារពើភណ្ឌនិងប្រព័ន្ធគ្រប់គ្រងផ្លូវជនបទ ក្រសួងគ្រប់គ្រងផ្លូវជនបទសរុបប្រវែង៥០ ២៦០គ.ម. ក្នុងនោះមានផ្លូវក្រាលកៅស៊ូពីរជាន់(DBST) ប្រវែង៦ ៧២៣គ.ម. និងផ្លូវក្រាលបេតុងប្រវែង១ ៨០៤គ.ម. ផ្លូវក្រាលល្បាយក្រួសប្រវែង៣១ ៧០៤គ.ម. និងផ្លូវដីសប្រវែង១០ ០២៩គ.ម. ព្រមទាំងមានសំណង់សិល្បការគ្រប់ប្រភេទសរុបចំនួន៤៨ ៨២២កន្លែង សរុបប្រវែង៣១ ៥៥៧ម. (ស្ពានបេតុងចំនួន២ ៣០៣កន្លែង សរុបប្រវែង២៧ ៧៣៦ម. ស្ពានដែកចំនួន៨៣កន្លែង សរុបប្រវែង២ ១៤៦ម. ស្ពានឈើចំនួន១២៦កន្លែង សរុបប្រវែង១ ៦៧៥ម. លូមូលសរុបចំនួន៣៦ ១២៨កន្លែង លូប្រអប់ចំនួន៤ ០៦៣កន្លែង)។

**ខ- ការកែលម្អលក្ខខណ្ឌរស់នៅរបស់សហគមន៍ជនបទ :** សុខភាព អនាម័យ និងបរិស្ថានរស់នៅស្អាតជាកត្តានាំឱ្យប្រជាពលរដ្ឋរស់នៅមានសុខភាពល្អ បញ្ញាវាងវៃ និងមានអាយុសង្ឃឹមរស់ជាមធ្យម(Life Expectancy) កាន់តែវែង។ ផ្អែកលើផែនការយុទ្ធសាស្ត្រជាតិផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ គោលនយោបាយជាតិនិងលិខិតបទដ្ឋានគតិយុត្តនានា ក្រសួងបានរួមចំណែកក្នុងការកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់ប្រជាជននៅតំបន់ជនបទ តាមរយៈការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត ការសម្អាត អនាម័យ និងបរិស្ថានស្អាត។ ក្រសួងបានអនុវត្តសកម្មភាពផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទសម្រេចបានលទ្ធផល៖

- **ការងារផ្គត់ផ្គង់ទឹកស្អាតជនបទ :** បានសម្រេចលទ្ធផលកម្រិតមូលដ្ឋាន ៨៩,២១% និងកម្រិតសុវត្ថិភាពសម្រេចបាន២១% ដោយបានសាងសង់អណ្តូងចំនួន៦៣៨ ១៨២អណ្តូង សាងសង់ស្រះសហគមន៍ចំនួន១០ ៦១៩ស្រះ សាងសង់អាងត្រងទឹកភ្លៀងចំនួន៥៨ ៦១៤អាង សាងសង់ប្រព័ន្ធចែកចាយទឹកតាមបណ្តាញបំពង់ខ្នាតតូចសហគមន៍ចំនួន៤២៩ប្រព័ន្ធ សាងសង់ពាងយក្សចំនួន២៦៩ ៣៨៤ពាង ផ្តល់ធុងចម្រោះទឹកស្អាតចំនួន២៦ ០៤៦ធុង សាងសង់ស្ថានីយផលិតទឹកចំនួន២២០ស្ថានីយ សាងសង់ប្រព័ន្ធស្រោចស្រពខ្នាតតូចចំនួន១៦ខ្សែ និងកសាងប្រឡាយទឹកចំនួន១០ខ្សែ។ ទន្ទឹមគ្នានេះ ក្រសួងបានបណ្តុះបណ្តាលបច្ចេកទេសថែទាំនិងជួសជុលអណ្តូងមានអ្នកចូលរួមចំនួន១ ៨១១នាក់ និងបានអប់រំប្រជាពលរដ្ឋឱ្យយល់ដឹងពីការគ្រប់គ្រងនិងប្រើប្រាស់ទឹកស្អាតមានអ្នកចូលរួមចំនួន១៣ ៧០៦នាក់
- **ការងារលើកកម្ពស់អនាម័យជនបទ :** បានសម្រេចលទ្ធផលកម្រិតមូលដ្ឋាន៩៤,៧៦% និងកម្រិតសុវត្ថិភាពសម្រេចបាន៥១% ដោយបានសាងសង់បង្គន់គ្រួសារចំនួន២ ៦០២ ១៩៥បង្គន់ បង្គន់អនាម័យសាធារណៈចំនួន១០ ៥២០បង្គន់ និងបង្គន់អនាម័យនៅតំបន់លិចទឹកចំនួន៩១០បង្គន់។ ទន្ទឹមគ្នានេះ ក្រសួងបានបណ្តុះបណ្តាលនិងផ្សព្វផ្សាយគោលការណ៍ណែនាំដល់មន្ត្រីបង្គោលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចំនួន៣៥៥វគ្គ មានអ្នកចូលរួមចំនួន១៣ ៩៣០នាក់

បានចុះអប់រំផ្សព្វផ្សាយជំរុញប្រជាពលរដ្ឋឱ្យប្រតិបត្តិអនាម័យល្អទាំង៣(សាងសង់និងប្រើប្រាស់បង្គន់អនាម័យ លាងសម្អាតដៃនឹងសាប៊ូក្រោយពេលបន្ទោបង់និងមុនពេលបរិភោគអាហារ និងការផឹកទឹកសុវត្ថិភាព) មានអ្នកចូលរួម៥៨ ៤០១នាក់

- **យុទ្ធនាការបញ្ចប់ការបន្ទោបង់ពាសវាលពាសកាល** : ក្រសួងបានបង្កើតយន្តការថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដោយមានការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាល និងប្រជាជនដើម្បីអនុវត្តកម្មវិធីបញ្ចប់ការបន្ទោបង់ពាសវាលពាសកាល(ODF) ដោយគិតត្រឹមឆ្នាំ២០២៥ សម្រេចលទ្ធផលបញ្ចប់ការបន្ទោបង់ពាសវាលពាសកាល(ODF)១០០% នៅទូទាំងប្រទេស ក្នុងនោះរាជធានីភ្នំពេញ និងខេត្តកណ្តាលបានបញ្ចប់ការបន្ទោបង់ពាសវាលពាសកាលកម្រិតខ្ពស់(ODF Plus)។

**គ- ការធ្វើពិពិធកម្មសេដ្ឋកិច្ចគ្រួសារ និងអភិវឌ្ឍន៍សហគមន៍ជនបទ** : ក្រសួងបានជំរុញនិងគាំទ្រសកម្មភាពបណ្តុះបណ្តាលជំនាញមូលដ្ឋាន បង្កើតមុខរបរនិងការងារ ភូមិគំរូនិងអភិវឌ្ឍន៍សហគមន៍ចម្រុះ ដើម្បីលើកកម្ពស់ជីវភាពប្រជាជនសម្រេចលទ្ធផលបាន៖

- **ការងារអភិវឌ្ឍន៍សហគមន៍ជនបទ** : ក្រសួងបានប្រកាសទទួលស្គាល់និងប្រគល់វិញ្ញាបនបត្រ «**ភូមិគំរូ**» ជូនដល់ភូមិជ័យលាភីចំនួន៣០ភូមិ បាននិងកំពុងអនុវត្តគម្រោងភូមិគំរូចំនួន៣៤ភូមិ ក្នុងនោះ «**ភូមិសន្តិភាព**» ចំនួន៣០ភូមិ និង«**ចលនាភូមិថ្មី**» ចំនួន៤ភូមិ បានផ្សព្វផ្សាយសារាចរណែនាំស្តីពីការបង្កើតនិងការប្រព្រឹត្តទៅគណៈកម្មាធិការអភិវឌ្ឍភូមិ(គ.អ.ភ.) នៅទូទាំងប្រទេស មានអ្នកចូលរួមចំនួន៤៣៤៧នាក់ ដោយបានចែកសៀវភៅសារាចរណែនាំចំនួន២៦០០ក្បាល បានបណ្តុះបណ្តាលគ.អ.ភ. ចំនួន៨៦៩៧ភូមិ (៥៨,១%) នៃភូមិសរុប បានរៀបចំសិក្ខាសាលាផ្លាស់ប្តូរបទពិសោធការងារពង្រឹងសមត្ថភាពគ.អ.ភ. ចំនួន១១ខេត្ត មានអ្នកចូលរួមចំនួន១២៣០នាក់ បានអភិវឌ្ឍភូមិចម្រុះចំនួន១០១ភូមិ ក្នុងនោះបានផ្តល់ស្រះទឹកគ្រួសារចំនួន៥២៣ស្រះ កូនឈើហូបផ្លែ កូនឈើចម្រុះ ពូជដំណាំបន្លែចម្រុះ ពូជសត្វចិញ្ចឹម(គោ ក្របី ពពែ ជ្រូក មាន់ ទា ត្រី) និងបានផ្តល់សម្ភារៈសម្រាប់សាងសង់រោងជីកំប៉ុស
- **ការងារជំរុញសកម្មភាពសេដ្ឋកិច្ចគ្រួសារ** : ក្រសួងមានទ្រព្យសកម្មសរុបចំនួន២ ៣២៦ ១៦៦ ៦៤០,៦៥រៀល(ពីរប៊ីលាន បីរយម្ភៃប្រាំមួយលាន មួយរយហុកសិបប្រាំមួយពាន់ ប្រាំមួយរយសែសិបរៀល ក្បៀសហុកសិបប្រាំសេន) ដែលបានផ្តល់ឥណទានជូនប្រជាជនចំនួន៤១៨នាក់ (ស្រីចំនួន២៨៧នាក់) នៅក្នុងភូមិគោលដៅចំនួន៧៦ភូមិ ៤១ឃុំ ២១ស្រុក ក្នុងខេត្តចំនួន៩។ ក្រសួងបានសាងសង់ផ្សារសហគមន៍ជនបទចំនួន៦ផ្សារ និងបានរៀបចំតាំងពិព័រណ៍ផលិតផលជនបទក្រោមប្រធានបទ «**ភូមិខ្ញុំផលិតផលខ្ញុំ**» ចំនួន៧លើក ព្រមទាំងបានបង្កើតសិប្បកម្មផលិតសាប៊ូចំនួន៦៣កន្លែង
- **ការងារបណ្តុះបណ្តាលនិងសិក្ខាសាលា** : ក្រសួងបានរៀបចំវគ្គបណ្តុះបណ្តាល និងសិក្ខាសាលា មានអ្នកចូលរួមសរុប៧២ ១៤២នាក់ ដែលផ្តោតលើប្រធានបទ គំនិតផ្តួចផ្តើមនិងការគ្រប់គ្រងអាជីវកម្មខ្នាតតូច គំនិតកែច្នៃផលិតផលក្នុងសហគមន៍ជនបទ គោលការណ៍និងការចងក្រងសហគមន៍សន្សំប្រាក់ កិច្ចបញ្ជីការគ្រប់គ្រងហិរញ្ញវត្ថុក្នុងអាជីវកម្ម ការប្រើប្រាស់ឥណទានជនបទជំនាញមូលដ្ឋាន គ្រូបង្គោលថ្នាក់ខេត្តថ្នាក់ស្រុកស្តីពីសន្តិសុខស្បៀងជាលក្ខណៈគ្រួសារ សួនដំណាំគ្រួសារ និងរបៀបធ្វើជីកំប៉ុសដល់គ្រួសារសហគមន៍ ការអប់រំអក្ខរកម្ម គ្រូបង្គោល

ស្តីពីការត្រៀមបង្ការនិងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ភាពជាអ្នកដឹកនាំកម្រិតភូមិ ការចិញ្ចឹមសត្វ ដាំបន្លែ កែច្នៃម្ហូបអាហារ និងបានរៀបចំសិក្ខាសាលា មានជាអាទិ៍គំនិតផ្តួចផ្តើម និងសហគ្រិនភាពក្នុងដំណើរការប្រតិបត្តិការការគ្រប់គ្រងអាជីវកម្មខ្នាតតូច ស្វែងយល់ពី ទីផ្សារ ផលិតផលជនបទ ផ្លាស់ប្តូរបទពិសោធជោគជ័យ បញ្ហា និងការប្រឈមទីផ្សារ ព្រមទាំងការផ្សព្វផ្សាយពីផលិតផលសម្រេចផ្សេងៗ

- **ការងារអភិរក្សនិងអភិវឌ្ឍន៍ជនជាតិដើមភាគតិច** : ក្រសួងបានចេញលិខិតទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចចំនួន២០៣សហគមន៍ រៀបចំបទបញ្ជាផ្ទៃក្នុងចំនួន១០១សហគមន៍ រៀបចំទិវាជាតិជនជាតិដើមភាគតិច រៀបចំសិក្ខាសាលាផ្សព្វផ្សាយគោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច និងរៀបចំសិក្ខាសាលាស្តីពីការពង្រឹងរចនាសម្ព័ន្ធគណៈកម្មការសហគមន៍ជនជាតិដើមភាគតិចសរុបចំនួន៨៤លើក។

**ឃ- ការពង្រឹងស្ថាប័ន និងការអនុវត្តការកែទម្រង់នានារបស់រាជរដ្ឋាភិបាល** : ក្រសួងបានរួមចំណែកយ៉ាងសកម្មក្នុងការអនុវត្តកម្មវិធីកំណែទម្រង់ និងកម្មវិធីនានារបស់រាជរដ្ឋាភិបាល៖

- ពង្រឹងសមត្ថភាពធនធានមនុស្សនិងស្ថាប័ន បានបណ្តុះបណ្តាលមន្ត្រីរាជការបាន៦៤ ១១៤នាក់ (ក្នុងប្រទេសចំនួន៦២ ៩៥០នាក់ និងក្រៅប្រទេសចំនួន១ ១១២នាក់) និងបានបោះពុម្ពផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានរបស់ក្រសួងចំនួន២២លេខ ផលិតព័ត៌មានសម្រាប់ផ្សាយតាមស្ថានីយវិទ្យុ និងទូរទស្សន៍ចំនួន១ ៤២១លើក
- អនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកែទម្រង់រដ្ឋបាលសាធារណៈ សំដៅកែលម្អ និងពង្រឹងការរៀបចំថវិកា ការគ្រប់គ្រងស្ថាប័ននិងមន្ត្រីរាជការ ការតាមដានត្រួតពិនិត្យនិងវាយតម្លៃដោយផ្អែកទៅលើផែនការសមិទ្ធកម្ម
- ការងារកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ដោយបានផ្ទេរមុខងារចំនួន៣មុខងារទៅឱ្យរដ្ឋបាលស្រុកចាប់តាំងពីឆ្នាំ២០២០ នៅក្នុងខេត្តកំពង់ឆ្នាំង កំពង់ស្ពឺ និងខេត្តត្បូងឃ្មុំ រួមមាន: (១) មុខងារផ្តល់សេវាអនាម័យជនបទផ្តោតលើការបំផុសបញ្ចប់ការបន្ទោបង់ពាសវាលពាសកាល និងការសាងសង់ ជួសជុល ថែទាំបង្គន់អនាម័យសាធារណៈ សម្រេចបានចំនួន១៥ស្រុក (២) មុខងារថែទាំនិងជួសជុលសំណង់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទគ្រប់ប្រភេទ សម្រេចបានចំនួន១១ស្រុក និង(៣) មុខងារថែទាំផ្លូវលក្ខណៈប្រចាំចំពោះផ្លូវដែលតភ្ជាប់ពីភូមិទៅភូមិ និងផ្លូវក្នុងភូមិគ្រប់ប្រភេទ លើកលែងតែផ្លូវក្រាលកៅស៊ូនិងផ្លូវក្រាលបេតុង សម្រេចបានចំនួន៧ស្រុក។

### ២.២.២- ស្ថានភាពជនបទតាមតំបន់ភូមិសាស្ត្រ

ផ្អែកលើសណ្ឋានដី ភូមិសាស្ត្រ និងអនុលោមតាមCSES 2021 ប្រទេសកម្ពុជាអាចចែកជា៤តំបន់សំខាន់ៗគឺ ១- តំបន់ទំនាបកណ្តាល ២- តំបន់ជុំវិញបឹងទន្លេសាប ៣- តំបន់ឆ្នេរសមុទ្រ និង៤- តំបន់ខ្ពង់រាបនិងភ្នំ ដូចបានបង្ហាញក្នុងផែនទី(បរិសិដ្ឋ២)។ យោងតាមគេហទំព័រនៃក្រសួងផែនការអំពី កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ(Household Data Dashboards) ដែលបានដកស្រង់កាលពីថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២៥ បានបង្ហាញថា ទិន្នន័យគ្រួសារ និងអត្រាគ្រួសារក្រីក្រនៅក្នុងតំបន់ទាំង៤នេះ មានភាពខុសៗគ្នា (ឧបសម្ព័ន្ធ២)។ ជាមួយគ្នានេះ យោងតាមបញ្ជីសារពើភណ្ឌផ្លូវជនបទ និងរបាយការណ៍ប្រចាំឆ្នាំ២០២៤ របស់ក្រសួងអភិវឌ្ឍន៍ជនបទ បានបង្ហាញថា លទ្ធផលនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងអត្រាគ្របដណ្តប់ទឹកស្អាតនិងអនាម័យជនបទនៅក្នុងតំបន់នីមួយៗ ក៏មានភាពខុសៗគ្នាដែរ(ឧបសម្ព័ន្ធ៣ និងឧបសម្ព័ន្ធ៤) ដូចខាងក្រោម៖

**ក- តំបន់ទំនាបកណ្ដាល** គឺជាតំបន់ទំនាបនៃអាងទន្លេមេគង្គ គ្របដណ្ដប់លើខេត្តចំនួន៦គឺ ខេត្តកំពង់ចាម ត្បូងឃ្មុំ កណ្ដាល ព្រៃវែង ស្វាយរៀង និងខេត្តតាកែវ ដែលមានភូមិជនបទ៤ ៤០៣ភូមិ ស្មើនឹង៧៦,៤១% នៃភូមិសរុបនៅទូទាំងតំបន់ទំនាបកណ្ដាល(៥ ៧៦២ភូមិ)។ នៅក្នុងតំបន់នេះ មានប្រជាជនរស់នៅសរុបចំនួន ១ ៥០៤ ៦៤០គ្រួសារ ក្នុងនោះមានគ្រួសារក្រ១ ចំនួន៦៥ ៧០២គ្រួសារ(៤,៣៧%) គ្រួសារក្រ២ ចំនួន១៧៦ ៤២១គ្រួសារ(១១,៧៣%) និងគ្រួសារងាយរងគ្រោះចំនួន១៨៤ ៨៣៥គ្រួសារ(១២,២៨%)។ តំបន់នេះមានផ្លូវជនបទគ្រប់ប្រភេទ(T1, T2, T3, T4) សរុប៤ ៨៩៩ខ្សែ ប្រវែងប្រមាណ១៥ ៣៨៩គ.ម. (៣០,៦%) នៃផ្លូវជនបទនៅទូទាំងប្រទេស។ ផ្លូវជនបទនៅក្នុងតំបន់នេះ ក្រាលកៅស៊ូពីរជាន់បានប្រមាណ២ ៧០០គ.ម. (១៨,២៥%) ក្រាលបេតុង៧៨១គ.ម.(៥,៨០%) និងប្រមាណជាង៧០% ទៀតជាផ្លូវល្បាយក្រួស ដីខ្សាច់ក្នំ និងផ្លូវដីស។ រីឯអត្រាគ្របដណ្ដប់នៃការផ្គត់ផ្គង់ទឹកស្អាតជនបទតាមគ្រួសារកម្រិតមូលដ្ឋានប្រមាណ៩៧,៦៥% និងអត្រាគ្របដណ្ដប់អនាម័យជនបទតាមខ្នងផ្ទះកម្រិតមូលដ្ឋានប្រមាណ៩៥,៨០%។

**ខ- តំបន់ជុំវិញបឹងទន្លេសាប** គឺជាតំបន់ទំនាបនៃបឹងទន្លេសាប គ្របដណ្ដប់លើខេត្តចំនួន៦គឺ ខេត្តបន្ទាយមានជ័យ បាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង កំពង់ធំ និងខេត្តសៀមរាប ដែលមានភូមិជនបទចំនួន ៣ ៦១៥ភូមិ (៨៤,១១%) នៃភូមិទូទាំងតំបន់២(៤ ២៩៨ភូមិ)។ នៅក្នុងតំបន់នេះ មានប្រជាជនរស់នៅសរុបចំនួន១ ២៣៥ ០៤៣គ្រួសារ ក្នុងនោះមានគ្រួសារក្រ១ ចំនួន៨៨ ៥២៩គ្រួសារ(៧,១៧%) គ្រួសារក្រ២ ចំនួន ២០៦ ០៨០គ្រួសារ(១៦,៦៩%) និងគ្រួសារងាយរងគ្រោះចំនួន១៩៤ ៣៩៥គ្រួសារ(១៥,៧៤%)។ តំបន់នេះមានផ្លូវជនបទគ្រប់ប្រភេទ(T1, T2, T3, T4) សរុប៧ ២០៨ខ្សែ ប្រវែងប្រមាណ១៨ ១១៤គ.ម. (៣៦%) នៃផ្លូវជនបទនៅទូទាំងប្រទេស។ ផ្លូវជនបទនៅក្នុងតំបន់នេះ ក្រាលកៅស៊ូពីរជាន់បានប្រមាណ ២ ៤៣៧គ.ម.(១៥,៨៣%) ក្រាលបេតុង១៩៥គ.ម.(១,១៦%) និងប្រមាណជាង៨០%ទៀតជាផ្លូវល្បាយក្រួស ដីខ្សាច់ក្នំ និងដីស។ រីឯអត្រាគ្របដណ្ដប់នៃការផ្គត់ផ្គង់ទឹកស្អាតតាមគ្រួសារជនបទកម្រិតមូលដ្ឋានប្រមាណ ៨៤.០១% និងអត្រាគ្របដណ្ដប់អនាម័យជនបទតាមខ្នងផ្ទះកម្រិតមូលដ្ឋានប្រមាណ៩៣.៧៧%។

**គ- តំបន់ឆ្នេរសមុទ្រ** គឺជាតំបន់ជាប់មាត់សមុទ្រ គ្របដណ្ដប់លើខេត្តចំនួន៤គឺ ខេត្តកែប កំពត ព្រះសីហនុ និងខេត្តកោះកុង ដែលមានភូមិជនបទចំនួន៥៩៤ភូមិ(៨០,៧១%) នៃភូមិទូទាំងតំបន់៣ (៧៣៦ភូមិ)។ នៅក្នុងតំបន់នេះ មានប្រជាជនរស់នៅសរុបចំនួន២៥៣ ១០១គ្រួសារ ក្នុងនោះមានគ្រួសារក្រ១ ចំនួន៩ ៩៤១គ្រួសារ(៣,៩៣%) គ្រួសារក្រ២ ចំនួន៣៤ ៧៨៦គ្រួសារ(១៣,៧៤%) និងគ្រួសារងាយរងគ្រោះចំនួន២២ ០៨១គ្រួសារ(៨,៧២%)។ តំបន់នេះមានផ្លូវជនបទគ្រប់ប្រភេទ(T1, T2, T3, T4) សរុប១ ២០៩ខ្សែ ប្រវែងប្រមាណ៣ ៤៣១គ.ម.(៦%) នៃផ្លូវជនបទនៅទូទាំងប្រទេស។ ផ្លូវជនបទនៅក្នុងតំបន់នេះ ក្រាលកៅស៊ូពីរជាន់បានប្រមាណ៣៦៤គ.ម.(១០,៨៨%) ក្រាលបេតុង២២៧គ.ម.(៩,៩៧%) និងប្រមាណជាង៨០%ទៀតជាផ្លូវល្បាយក្រួស ដីខ្សាច់ក្នំ និងដីស។ រីឯអត្រាគ្របដណ្ដប់នៃការផ្គត់ផ្គង់ទឹកស្អាតជនបទតាមគ្រួសារកម្រិតមូលដ្ឋានប្រមាណ៨២,៥១% និងអត្រាគ្របដណ្ដប់អនាម័យជនបទតាមខ្នងផ្ទះកម្រិតមូលដ្ឋានប្រមាណ៩២,៦២%។

**ឃ- តំបន់ភ្នំនិងខ្ពង់រាប** គឺជាតំបន់គ្របដណ្ដប់លើខេត្តចំនួន៨គឺ ខេត្តក្រចេះ មណ្ឌលគិរី រតនគិរី ស្ទឹងត្រែង ព្រះវិហារ ឧត្តរមានជ័យ ប៉ៃលិន និងខេត្តកំពង់ស្ពឺ ដែលមានភូមិជនបទចំនួន១ ៧០៣ភូមិ (៦០,៧១%)នៃភូមិទូទាំងតំបន់៤(២ ៨០៥ភូមិ)។ នៅក្នុងតំបន់នេះ មានប្រជាជនរស់នៅសរុបចំនួន ៥៨៣ ៥៣៨គ្រួសារ ក្នុងនោះមានគ្រួសារក្រ១ ចំនួន៣២ ៦៨៩គ្រួសារ(៥,៦០%) គ្រួសារក្រ២ ចំនួន ៨៥ ៦៨៤គ្រួសារ(១៤,៦៨%) និងគ្រួសារងាយរងគ្រោះចំនួន៦៧ ៦០៤គ្រួសារ(១១,៥៩%)។ តំបន់នេះមានផ្លូវជនបទគ្រប់ប្រភេទ(T1, T2, T3, T4) សរុប៣ ១៧៣ខ្សែ ប្រវែងប្រមាណ១១ ៦២០គ.ម.(២៣%) នៃផ្លូវជនបទនៅទូទាំងប្រទេស។ ផ្លូវជនបទនៅក្នុងតំបន់នេះ ក្រាលកៅស៊ូពីរជាន់បានប្រមាណ៨៦៥គ.ម. (៧,១៥%) ក្រាលបេតុងប្រវែងប្រមាណ១០០ គ.ម.(០,៧៧%) និងប្រមាណជាង៩០% ទៀតជាផ្លូវល្បាយ

ក្រួស ដីខ្សាច់ក្នុំ និងដីស។ រីឯអត្រាគ្របដណ្តប់នៃការផ្គត់ផ្គង់ទឹកស្អាតជនបទតាមគ្រួសារកម្រិតមូលដ្ឋាន ប្រមាណ៨០,៧២% និងអត្រាគ្របដណ្តប់អនាម័យជនបទតាមខ្នងផ្ទះកម្រិតមូលដ្ឋានប្រមាណ៩២,៤២%។

ជារួម នៅក្នុងតំបន់ទាំង៤ មានភូមិសរុប១៣ ៦០១ភូមិ ក្នុងនោះភូមិទីប្រជុំជនមានចំនួន៣ ២៨៦ភូមិ (២៤,១៦%) និងភូមិជនបទមានចំនួន១០ ៣១៥ភូមិ(៧៥,៨៤%) ដែលមានប្រជាជនរស់នៅសរុបចំនួន ៣ ៥៧៦ ៣២២គ្រួសារ ក្នុងនោះគ្រួសារក្រ១ មានចំនួន១៩៦ ៨៦១គ្រួសារ(៥,៥០%) គ្រួសារក្រ២ មានចំនួន ៥០២ ៩៧១គ្រួសារ(១៤,០៦%) និងគ្រួសារងាយរងគ្រោះមានចំនួន៤៦៨ ៩១៥គ្រួសារ(១៣,១១%)។ នៅក្នុងតំបន់ទាំង៤នេះ មានផ្លូវជនបទគ្រប់ប្រភេទសរុប១៦ ៤៨៩ ខ្សែ ប្រវែងប្រមាណ៥០ ២៦០គ.ម. ក្នុងនោះ ផ្លូវក្រាលកៅស៊ូពីរជាន់ប្រវែងប្រមាណ៦ ៧២៣គ.ម.(១៣%) ផ្លូវបេតុងប្រវែងប្រមាណ១ ៨០៤គ.ម.(៣,៥%) និងប្រមាណជាង ៨០% ទៀតជាផ្លូវល្បាយក្រួស ដីខ្សាច់ក្នុំ និងដីស។ រីឯអត្រាគ្របដណ្តប់នៃការផ្គត់ផ្គង់ទឹកស្អាត ជនបទតាមគ្រួសារកម្រិតមូលដ្ឋានប្រមាណ៨៩,២១% និងអត្រាគ្របដណ្តប់អនាម័យជនបទតាមខ្នងផ្ទះ កម្រិតមូលដ្ឋានប្រមាណ៩៤,៧៦%។

## ២.៣- បញ្ហា ការប្រឈម និងកាលានុវត្តភាព

### ២.៣.១- បញ្ហានៅតំបន់ជនបទ

តំបន់ជនបទនៃប្រទេសកម្ពុជានៅមានបញ្ហាមួយចំនួនដូចខាងក្រោម៖

- **ភាពក្រីក្រ** : នៅក្នុងតំបន់ទាំង៤ អត្រាគ្រួសារក្រ១ ប្រមាណ៥,៥០% និងគ្រួសារក្រ២ ប្រមាណ ១៤,០៦% និងគ្រួសារងាយរងគ្រោះប្រមាណ១៣,១១% ភាគច្រើនរស់នៅក្នុងតំបន់ជនបទ។ ប្រជាជនក្រីក្រជាទូទៅមានប្រាក់ចំណូលទាប ដែលអាចបណ្តាលមកពីកត្តាមួយចំនួន ដូចជាមិនមាន ជំនាញ មិនមានការងារជាប់លាប់ ខ្វះដីបង្កបង្កើនផល ទិន្នផលទាប តម្លៃផលិតផលមិនទៀងទាត់ជាដើម
- **នៅតាមបណ្តោយព្រំដែនដែលធ្លាប់ជាតំបន់សង្គ្រាមមានការអភិវឌ្ឍតិចតួចនៅឡើយ** : សង្គ្រាមស៊ីវិល អស់ពេលជិត៣០ឆ្នាំ ដែលជាទូទៅនៅតាមបណ្តោយព្រំដែនជាតំបន់សមរភូមិប្រយុទ្ធ ជាហេតុធ្វើ ឱ្យតំបន់ទាំងនោះមានការអភិវឌ្ឍតិចតួច និងនៅមិនទាន់បានធ្វើសមាហរណកម្មពេញលេញនៅឡើយ
- **ហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលធន់នឹងការប្រែប្រួលអាកាសធាតុនៅមានកម្រិត** : បច្ចុប្បន្ន ហេដ្ឋារចនា សម្ព័ន្ធផ្លូវជនបទភាគច្រើន(៨៤% នៅជាផ្លូវក្រាលល្បាយក្រួសនិងផ្លូវដីស) មិនទាន់បានលើកកម្រិត គុណភាពឱ្យមានធន់នឹងការប្រែប្រួលអាកាសធាតុ និងមិនអាចបម្រើសេវាដឹកជញ្ជូនបានគ្រប់រដូវកាល។ ប្រការនេះបានធ្វើឱ្យមានការលំបាកដល់ការជំរុញសកម្មភាពសេដ្ឋកិច្ច សង្គមកិច្ច និងការផ្តល់សេវា សាធារណៈផ្សេងៗនៅក្នុងតំបន់ជនបទ។ ជាមួយគ្នានេះ ប្រព័ន្ធធារាសាស្ត្រដែលអាចស្រោចស្រព បានគ្រប់រដូវកាលនិងការផ្គត់ផ្គង់ទឹកស្អាតនៅមានកម្រិត ដែលនាំឱ្យប៉ះពាល់ដល់ជីវភាពរស់នៅ របស់ប្រជាជននៅជនបទ
- **បំណុលរបស់ប្រជាជននៅតំបន់ជនបទ** : បំណុលរបស់ប្រជាជននៅតំបន់ជនបទ ក្លាយជាបញ្ហា នៅពេលប្រើប្រាស់មិនចំគោលដៅ[១]។ ដោយផ្អែកលើស្ថានភាពឥណទាននៅកម្ពុជាចុងឆ្នាំ២០២៤[២] មានអ្នកខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(មិនរាប់បញ្ចូលស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត) ជាង១,៤៨ លាននាក់ ដែលមានទំហំទឹកប្រាក់កម្ចីប្រមាណ១៦ប៊ីលានដុល្លារអាម៉េរិក

---

[១] អង្កេតវាយតម្លៃលើកម្មវិបាកនៃមីក្រូហិរញ្ញវត្ថុនៅកម្ពុជាឆ្នាំ២០២៣ អ្នកប្រើប្រាស់ប្រាក់កម្ចីឥណទាន២១% លំបាកខ្លាំង (A lot worse) ២% លំបាក (somewhat worse) ៩% លំបាកខ្លះៗ (Mixed effects) ក្រៅពីនេះកម្ចីឥណទានបានជួយឱ្យពួកគាត់មានជីវភាពល្អ។

[២] Cambodia Microfinance Sector Reviews Progress, Outlines 2025 Plans at Annual General Meeting Progress.

- **សេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទប្រកបដោយសុវត្ថិភាពនៅមានកម្រិត** : ទឹកស្អាតនិងអនាម័យជនបទ គឺជាកត្តាដ៏សំខាន់ក្នុងការទ្រទ្រង់សុខភាពនិងបរិស្ថានល្អនៅតំបន់ជនបទ។ បច្ចុប្បន្ន សេវាផ្គត់ផ្គង់ទឹកស្អាតជនបទកម្រិតមូលដ្ឋានសម្រេចបានប្រមាណ៨៩,២១% និងអនាម័យមូលដ្ឋានសម្រេចបាន៩៤,៧៦%។ ប៉ុន្តែ អត្រានៃការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទកម្រិតសុវត្ថិភាព ទើបតែសម្រេចបាន២១% និង៥១%ប៉ុណ្ណោះ។
- **កង្វះអាហារូបត្ថម្ភ** : យោងតាមរបាយការណ៍ស្ដីពីសមិទ្ធផលសំខាន់ៗនៃការអនុវត្តយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ ឆ្នាំ២០១៨-២០២២ បង្ហាញថា អត្រាកុមារក្រិសក្រិនមាន២២% និងមិនគ្រប់ទម្ងន់មាន១៦% ដែលប៉ះពាល់ដល់សុខភាពនិងការលូតលាស់ ជាពិសេសធ្វើឱ្យបញ្ញាស្មារតី និងរាងកាយរបស់កុមារមានសភាពទន់ខ្សោយ
- **ធនធានមនុស្ស និងជំនាញមូលដ្ឋាននៅមានកម្រិត** : អត្រាអនក្ខរជននៃមនុស្សពេញវ័យនៅជនបទមានប្រមាណ២១% គឺច្រើនជាងជិត៤ដង នៅរាជធានីភ្នំពេញ(៦%) និងប្រមាណ២ដងនៃទីក្រុង និងទីប្រជុំជន( ១២% )។ កម្លាំងពលកម្មភាគច្រើននៅតំបន់ជនបទ ពុំមានជំនាញច្បាស់លាស់ ខ្វះបទពិសោធការងារ និងខ្វះជំនាញទន់(អត្តចរិត ភាពអត់ធ្មត់ ឧស្សាហ៍ព្យាយាម ស្មារតីទទួលខុសត្រូវ) ជាកត្តាធ្វើឱ្យមានការលំបាកក្នុងការស្វែងរកការងារដែលមានប្រាក់ឈ្នួលខ្ពស់ ហើយក៏ជាចំណែកមួយធ្វើឱ្យលំបាកដល់អ្នកវិនិយោគទុនផងដែរ។ លើសពីនេះការនិយមទំនិញ និងផលិតផលនាំចូលពីបរទេសបានជះឥទ្ធិពលអវិជ្ជមាន និងបង្កើតទម្លាប់នៃភាពអសកម្មក្នុងការបង្កើនផលិតផលក្នុងស្រុក
- **បញ្ហាសង្គមផ្សេងៗទៀតនៅតំបន់ជនបទ** : ការបោះបង់ចោលការសិក្សានៅកម្រិតមូលដ្ឋាន ការរៀបការក្នុងវ័យអនីតិជន ល្បែងស៊ីសង គ្រឿងញៀនខុសច្បាប់ អំពើហិង្សា អបិយជំនឿមិនសមហេតុផលជាដើម គឺជាកត្តាត្រូវតែយកចិត្តទុកដាក់នៅក្នុងដំណើរការអភិវឌ្ឍន៍ជនបទ ដើម្បីជួយឱ្យសង្គមជនបទមានសណ្ដាប់ធ្នាប់ សន្តិសុខ ទំនៀមទម្លាប់ល្អ និងមានសេចក្ដីថ្លៃថ្នូរ
- **សេវាបច្ចេកវិទ្យាឌីជីថលនៅមានកម្រិត** : ហេដ្ឋារចនាសម្ព័ន្ធ និងសេវាបច្ចេកវិទ្យា ព្រមទាំងចំណេះដឹងបច្ចេកវិទ្យា នៅមានការខ្វះចន្លោះ ដែលជាចំណែកមួយធ្វើឱ្យការអភិវឌ្ឍជនបទមានសន្ទុះយឺត។ ជាក់ស្ដែង គុណភាពសេវាអ៊ីនធឺណិតនៅតំបន់ជនបទមួយចំនួននៅមានដែនកំណត់ ហើយប្រជាជននៅតំបន់ជនបទភាគច្រើន ជាពិសេសយុវជនក៏នៅមិនទាន់យល់ដឹង និងមិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការប្រើប្រាស់ បច្ចេកវិទ្យាឌីជីថល ដើម្បីជាមធ្យោបាយទំនាក់ទំនង និងជាប្រយោជន៍សេដ្ឋកិច្ចឡើយ
- **ការប្រែប្រួលអាកាសធាតុ** : កម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសងាយរងគ្រោះនៅក្នុងតំបន់ ដោយសារការប្រែប្រួលអាកាសធាតុ ដូចជារបបទឹកភ្លៀងមិនទៀងទាត់ ទឹកជំនន់ រាំងស្ងួត ខ្យល់ព្យុះ ខ្យល់កន្ត្រាក់ ផ្គររន្ទះជាដើម ដែលធ្វើប្រជាជនមានការលំបាកក្នុងការប្រកបរបរចិញ្ចឹមជីវិត ប៉ះពាល់ដល់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តជនបទ ដូចជាផ្លូវជនបទ ប្រព័ន្ធផ្គត់ផ្គង់ទឹក និងអនាម័យជនបទ។

បញ្ហានានាខាងលើ បានធ្វើឱ្យមានផលប៉ះពាល់ជាអវិជ្ជមានដល់សហគមន៍ជនបទដូចខាងក្រោម៖

- **ខាតបង់ពេលវេលានិងថវិកា** : ដោយសារហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ មិនទាន់បានតភ្ជាប់ប្រទាក់ក្រឡាគ្នា និងមានភាពធន់ដែលអាចប្រើប្រាស់បានគ្រប់រដូវកាល ធ្វើឱ្យប្រជាជនចំណាយពេលវេលា និងថវិកាច្រើនក្នុងការធ្វើដំណើរ និងការដឹកជញ្ជូនទំនិញផ្សេងៗ

- **ងាយឆ្លង ឬកើតជំងឺផ្សេងៗ :** ដោយសារប្រជាជនមួយចំនួននៅមិនទាន់យល់ដឹងពីការប្រើប្រាស់ទឹកស្អាត និងការប្រតិបត្តិអនាម័យល្អ ព្រមទាំងរស់នៅតាមដងផ្លូវជនបទមានសភាពហុយខ្លាំងនៅពេលមានរថយន្តឆ្លងកាត់ អាចធ្វើឱ្យកើតជំងឺផ្សេងៗ និងពិបាកក្នុងការថែទាំអនាម័យនៅក្នុងលំនៅឋាន និងបរិស្ថានជុំវិញភូមិ/សហគមន៍ផងដែរ
- **ងាយនឹងធ្លាក់ទៅក្នុងភាពក្រីក្រ អំពើហិង្សា អសន្តិសុខ និងចំណាកស្រុកដោយប្រថុយប្រថាន :** ដោយសារខ្វះជំនាញបំណិនជីវិត ចំណេះដឹងធ្វើអាជីវកម្ម ឬសមត្ថភាពបង្កបង្កើនផលកសិកម្មដែលអាចរកប្រាក់ចំណូលបានសមរម្យ និងខ្វះឱកាសការងារនៅក្នុងមូលដ្ឋាន ធ្វើឱ្យប្រជាជនមួយចំនួនជួបប្រទះនឹងភាពខ្វះខាតក្នុងជីវភាព ដែលជាកត្តានាំឱ្យមានការប្រព្រឹត្តអំពើអបាយមុខផ្សេងៗខុសច្បាប់ ដូចជាអំពើហិង្សាក្នុងគ្រួសារ បង្កអសន្តិសុខសង្គម និងធ្វើចំណាកស្រុកដោយប្រថុយប្រថានជាដើម។

### ២.៣.២- ការប្រឈមចំពោះការងារអភិវឌ្ឍន៍ជនបទ

ទន្ទឹមនឹងបញ្ហានិងបច្ច័យអវិជ្ជមានខាងលើ ការងារអភិវឌ្ឍន៍ជនបទមានការប្រឈមដូចខាងក្រោមៈ

- **ធនធានហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍជនបទនៅមានកម្រិត :** ទោះជាការងារអភិវឌ្ឍន៍ជនបទនៅតែជាអាទិភាពរបស់រាជរដ្ឋាភិបាលក៏ដោយ ក៏ការវិភាជថវិកាជាតិនៅតែពុំទាន់អាចឆ្លើយតបទៅនឹងសេចក្តីត្រូវការជាក់ស្តែងនៅឡើយ។ ជាមួយគ្នានេះ ថវិកាជាតិត្រូវបានធ្វើវិចារណកម្មជាបន្តបន្ទាប់ចាប់ពីឆ្នាំ២០២០ រហូតដល់បច្ចុប្បន្ន ដោយសារស្ថានភាពម៉ាក្រូសេដ្ឋកិច្ចរងផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ-១៩ វិបត្តិសង្គ្រាមនៅអ៊ុយក្រែននិងមជ្ឈិមបូព៌ា។ ដោយឡែក ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍជាពិសេសជំនួយឥតសំណង និងអង្គការមិនមែនរដ្ឋាភិបាល ក៏មាននិន្នាការថយចុះ
- **ធនធានមនុស្សនិងសមត្ថភាពស្ថាប័ននៅមានកម្រិត :** សមត្ថភាពជំនាញបច្ចេកទេសរបស់មន្ត្រី បម្រើការងារក្នុងក្រសួងអភិវឌ្ឍន៍ជនបទនៅមានកម្រិត ជាពិសេសជំនាញភាពជាអ្នកដឹកនាំ ការគ្រប់គ្រង ការត្រួតពិនិត្យ និងវាយតម្លៃ។ ទន្ទឹមនឹងនេះ ស្ថានភាពការងារក្នុងយុគសម័យបច្ចេកវិទ្យាបច្ចុប្បន្នតម្រូវឱ្យមន្ត្រីរាជការបង្កើនសមត្ថភាពនិងទេពកោសល្យ
- **កិច្ចសហប្រតិបត្តិការពីក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនៅមានកម្រិត :** កិច្ចការអភិវឌ្ឍជនបទតម្រូវឱ្យមានកិច្ចសហការ និងចូលរួមយ៉ាងសកម្មពីគ្រប់ភាគីពាក់ព័ន្ធ ដើម្បីធានាឱ្យការអភិវឌ្ឍជនបទទទួលបានលទ្ធផលល្អ ឆាប់រហ័ស និងគ្រប់ជ្រុងជ្រោយ។ ដូច្នេះ ចាំបាច់ត្រូវកៀរគរ និងកសាងកិច្ចសហការយ៉ាងសកម្មពីក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ ប្រទេសជាមិត្ត ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល សហគមន៍មូលដ្ឋាន វិស័យឯកជន និងសប្បុរសជន ដើម្បីរួមគ្នានៅក្នុងដំណើរការអភិវឌ្ឍន៍ជនបទ
- **អភិបាលកិច្ចតំបន់ជនបទនៅមានកម្រិត :** ភាពជាអ្នកដឹកនាំ ការគ្រប់គ្រង ឯកសារគតិយុត្ត នីតិវិធីការរៀបចំផែនការ ការអនុវត្ត ការត្រួតពិនិត្យ និងការវាយតម្លៃការងារនៅកម្រិតមូលដ្ឋាន នៅមិនទាន់ទទួលបានលទ្ធផលល្អប្រសើរនៅឡើយ និងការចូលរួមក្នុងសកម្មភាពអភិវឌ្ឍន៍របស់សហគមន៍នៅមានកម្រិត
- **ការអនុវត្តនូវបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងការដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់លើផ្លូវជនបទនៅមានកម្រិត :** ឯកសារគតិយុត្តសម្រាប់គ្រប់គ្រងការដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ដែលមានស្រាប់ អាចអនុវត្តបានលើផ្លូវជាតិនិងផ្លូវខេត្ត ប៉ុន្តែមិនទាន់អាចអនុវត្តបានលើផ្លូវជនបទ

នៅឡើយ។ ជាទូទៅនៅពេលផ្លូវជនបទត្រូវបានស្ថាបនាតភ្ជាប់ប្រទាក់ក្រឡា តែងមានកំណើនចរាចរណ៍ និងការដឹកជញ្ជូន ធ្ងន់ៗលើសពីទម្ងន់កម្រិតកំណត់ ក្នុងនោះរថយន្តផុនធ្ងន់ដែលមានការកែច្នៃខុសស្តង់ដាបច្ចេកទេស គឺជាចំណែកដ៏សំខាន់ក្នុងការធ្វើឱ្យផ្លូវជនបទងាយរងការខូចខាត

- **ភាពជាម្ចាស់របស់សហគមន៍ជនបទនៅមានកម្រិត** : សហគមន៍ជនបទមួយចំនួនមិនទាន់មានភាពជាម្ចាស់លើជោគវាសនារួមរបស់ខ្លួន ដែលជាការប្រឈមក្នុងការអនុវត្តការងារអភិវឌ្ឍន៍ជនបទឱ្យទទួលបានជោគជ័យ និងមាននិរន្តរភាព ដោយសារខ្វះភាពជាអ្នកដឹកនាំ ខ្វះស្មារតីសាមគ្គីភាព ខ្វះការចូលរួមសហការក្នុងសហគមន៍ និងមិនសូវមានភាពឧស្សាហ៍ព្យាយាមជាដើម ដែលជាហេតុធ្វើឱ្យសមិទ្ធផលដែលបានកសាងមិនមានចីរភាពយូរអង្វែង
- **រចនាសម្ព័ន្ធ និងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍភូមិ(គ.អ.ភ.) មិនទាន់រឹងមាំ** : បច្ចុប្បន្ន គ.អ.ភ. ជារចនាសម្ព័ន្ធដឹកនាំការអភិវឌ្ឍនៅថ្នាក់ភូមិ ដែលត្រូវបានប្រកាសទទួលស្គាល់ដោយប្រធានក្រុមប្រឹក្សាឃុំ សង្កាត់។ ប៉ុន្តែ គ.អ.ភ.មិនទាន់ត្រូវបានទទួលស្គាល់ដោយទូលំទូលាយពីគ្រប់ភាគីពាក់ព័ន្ធ ហើយលើសពីនេះ គ.អ.ភ. ភាគច្រើនមិនទាន់មានសមត្ថភាពពេញលេញក្នុងការដឹកនាំ និងសម្របសម្រួលការងារអភិវឌ្ឍន៍នៅក្នុងភូមិប្រកបដោយភាពជាម្ចាស់នៅឡើយ។

### ២.៣.៣- កាលានុវត្តភាពអភិវឌ្ឍន៍ជនបទ

ទន្ទឹមនឹងការជួបប្រទះនូវបញ្ហានិងការប្រឈមខាងលើ តំបន់ជនបទកម្ពុជាមានកាលានុវត្តភាពជាច្រើនសម្រាប់ការអនុវត្តកម្មវិធីអភិវឌ្ឍន៍ជនបទដូចខាងក្រោមៈ

- **សុខសន្តិភាពពេញលេញគឺជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការអភិវឌ្ឍប្រទេសជាតិទាំងមូល** : ផលលាភសន្តិភាពបានផ្តល់ឧត្តមប្រយោជន៍សម្រាប់វឌ្ឍនភាពផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌។ ការរក្សាបានយ៉ាងរឹងមាំ និងជាប់មិនដាច់នូវសុខសន្តិភាពនិងស្ថិរភាពនយោបាយ បាននិងកំពុងបន្តបង្កើតបរិយាកាសងាយស្រួលក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកិច្ចនៅតំបន់ជនបទក៏ដូចជានៅទូទាំងប្រទេស
- **កម្មវិធីនយោបាយច្បាស់លាស់** : ពីមួយអាណត្តិទៅមួយអាណត្តិ រាជរដ្ឋាភិបាលបានដាក់ចេញនូវកម្មវិធីនយោបាយ យុទ្ធសាស្ត្រ ផែនការអភិវឌ្ឍន៍ជាតិ និងមានយន្តការអនុវត្ត និងប្រព័ន្ធតាមដានត្រួតពិនិត្យ។ ជាមួយគ្នានេះ គ្រប់ក្រសួង ស្ថាប័ន ជាពិសេសក្រសួងអភិវឌ្ឍន៍ជនបទមានផែនការយុទ្ធសាស្ត្រ កម្មវិធីអភិវឌ្ឍន៍ជនបទ ផែនការមេផ្លូវជនបទ ផែនការយុទ្ធសាស្ត្រជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទ ព្រមទាំងផែនការសកម្មភាពជាក់លាក់ដែលត្រូវបានយកមកអនុវត្ត និងសម្រេចបានសមិទ្ធផលវិជ្ជមាន
- **ការផ្តល់អាទិភាពលើវិស័យអភិវឌ្ឍន៍ជនបទ** : ក្នុងនីតិកាលទី៧នៃរដ្ឋសភា រាជរដ្ឋាភិបាលបានផ្តោតលើការលើកស្ទួយកសិកម្ម និងការអភិវឌ្ឍជនបទ ដែលបានកំណត់នៅក្នុងមុំទី៣ នៃបញ្ចកោណទី៤ «ការបន្តអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទ តាមរយៈការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងគមនាគមន៍ជនបទ ការលើកកម្រិតគុណភាពហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ ជាពិសេសការកសាងផ្លូវជនបទតភ្ជាប់ទៅកសិដ្ឋាននិងផ្លូវជាតិឱ្យក្លាយទៅជាជនបទសមាហរណកម្ម ការកៀរគរកម្លាំងខ្លួនឯងរបស់សហគមន៍ជនបទ និងការធ្វើពិពិធកម្មសេដ្ឋកិច្ចជនបទនិងការអភិវឌ្ឍសហគមន៍ជនបទ ជាពិសេសការជំរុញការអភិវឌ្ឍចម្រុះនិងការបន្តអនុវត្ត «**ចលនាភូមិមួយផលិតផលមួយ**» និង «**ចលនាភូមិគំរូ**»

- **សមិទ្ធផលនៃការអភិវឌ្ឍក្នុងនីតិកាលកន្លងមក** : ភាពរីកចម្រើនផ្នែកសេដ្ឋកិច្ចនិងសង្គម ដូចជាវិស័យអប់រំ បណ្តុះបណ្តាលជំនាញ សុខាភិបាល សន្តិសុខសង្គម ហិរញ្ញវត្ថុនិងធនាគារ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត រដ្ឋបាលសាធារណៈបាននិងកំពុងដំណើរការនៅទូទាំងប្រទេស ទោះកន្លែងខ្លះនៅមានកម្រិតក៏ដោយ ក៏បានផ្តល់ភាពងាយស្រួលនៅក្នុងដំណើរការនៃការងារអភិវឌ្ឍន៍ជនបទផងដែរ
- **រាជរដ្ឋាភិបាលមានរចនាសម្ព័ន្ធដឹកនាំ គ្រប់គ្រង អនុវត្ត និងត្រួតពិនិត្យការងារអភិវឌ្ឍន៍លើគ្រប់វិស័យ** : រាជរដ្ឋាភិបាលបានបង្កើតឱ្យមានស្ថាប័នថ្នាក់ជាតិ (ក្រសួង អគ្គនាយកដ្ឋាន នាយកដ្ឋាន ការិយាល័យកណ្តាល) និងរដ្ឋបាលថ្នាក់ក្រោមជាតិ (រដ្ឋបាលរាជធានីខេត្ត មន្ទីរជំនាញជុំវិញខេត្ត រដ្ឋបាលក្រុង ស្រុក ខណ្ឌ អាជ្ញាធរមូលដ្ឋានឃុំ សង្កាត់ និងភូមិ) ដើម្បីដឹកនាំ គ្រប់គ្រង និងអនុវត្តការងារអភិវឌ្ឍន៍លើគ្រប់វិស័យទាំងនៅទីក្រុង ទីប្រជុំជន និងជនបទ។ រាជរដ្ឋាភិបាលបានបង្កើតផងដែរនូវក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ(ក.ក.ជ.) ដែលជាយន្តការសម្របសម្រួលក្រសួងជំនាញទាំងឡាយ ដើម្បីជំរុញការងារអភិវឌ្ឍន៍នៅតំបន់ជនបទ។ លើសពីនេះ រាជរដ្ឋាភិបាលបានបង្កើតក្រុមការងារ រាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ ដែលជាយន្តការតាមដាន និងត្រួតពិនិត្យការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល
- **ភាពរីកចម្រើននៃធនធានមនុស្ស** : ធនធានមនុស្សនៅកម្ពុជានាពេលបច្ចុប្បន្ន មានភាពរីកចម្រើនដោយសារការរីកចម្រើនលើវិស័យអប់រំទូទៅក៏ដូចជាវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។ ជាមួយគ្នានេះ កម្ពុជាមានកម្លាំងពលកម្មវ័យក្មេងច្រើននិងអត្រាចូលរួមកម្លាំងពលកម្មខ្ពស់ធៀបនឹងប្រទេសក្នុងតំបន់
- **ទំនៀមទម្លាប់ប្រពៃណី និងសាសនា** : នៅតំបន់ជនបទនៃប្រទេសកម្ពុជា ទំនៀមទម្លាប់ ប្រពៃណី និងសាសនាដ៏សម្បូរបែប ចម្រុះ និងល្អផូរផង់ ត្រូវបានលើកកម្ពស់តាមរយៈការថែរក្សា និងការអនុវត្តជាប្រចាំដោយគ្មានការរើសអើង ក្នុងកម្មវិធីសាសនានិងកម្មវិធីសង្គមនានា ទាំងនៅតាមភូមិជនបទ និងភូមិជនជាតិដើមភាគតិចផងដែរ។ លើសពីនេះ ចំនុចវិជ្ជមាននៃសង្គមកម្ពុជាគឺសុខដុមនីយកម្មនៃសាសនា ដែលជាកត្តាមិនអាចខ្វះ និងដែលបានរួមចំណែករក្សាស្ថិរភាពសង្គមកម្ពុជា និងសាមគ្គីភាពជាតិកាន់តែរឹងមាំ
- **កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ និងទំនាក់ទំនងអន្តរជាតិ** : បច្ចុប្បន្ន ប្រទេសកម្ពុជាបានធ្វើសមាហរណកម្មចូលទៅក្នុងតំបន់ និងពិភពលោក ព្រមទាំងមានកិច្ចសហការជាមួយបណ្តាប្រទេសជាមិត្តទាំងទ្វេភាគីនិងពហុភាគី និងដៃគូអភិវឌ្ឍជាច្រើន តាមគោលការណ៍ «**កែទម្រង់ខាងក្នុង និងពង្រីកមិត្តខាងក្រៅដោយឈរលើស្មារតីឯករាជ្យ និងផ្អែកលើច្បាប់**» ទាំងផ្នែកនយោបាយ សេដ្ឋកិច្ច សង្គម បច្ចេកវិទ្យា វប្បធម៌ និងផ្នែកបរិស្ថាន ដែលជាកាលានុវត្តភាពសម្រាប់ការអភិវឌ្ឍប្រទេស
- **បច្ចេកវិទ្យាឌីជីថល** : ភាពរីកចម្រើននៃបច្ចេកវិទ្យា(ឌីជីថល) បាននិងកំពុងបង្កលក្ខណៈងាយស្រួលដល់ការងារអភិវឌ្ឍន៍ជនបទ ពោលគឺបច្ចេកវិទ្យាឌីជីថលនាពេលបច្ចុប្បន្ននេះ បានជួយពន្លឿនការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឱ្យមានសន្ទុះកាន់តែខ្លាំង តាមរយៈការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថលសម្រាប់ទំនាក់ទំនង និងធ្វើអាជីវកម្មជាដើម
- **ស្ថានភាពភូមិសាស្ត្រនិងធនធានធម្មជាតិសម្បូរបែប** : ប្រទេសកម្ពុជាមានផ្ទៃដីធំទូលាយធៀបនឹងចំនួនប្រជាជន មានធនធានធម្មជាតិសម្បូរបែប និងមានស្ថានភាពភូមិសាស្ត្រអំណោយផលដល់ការអភិវឌ្ឍជនបទនៅទូទាំងប្រទេស។

## ៣- ចក្ខុវិស័យ

គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនបទ ឆ្នាំ២០២៥-២០៣៥ មានចក្ខុវិស័យ «**កសាងសង្គមជនបទកម្ពុជាឱ្យមានវិបុលភាព ប្រកបដោយបរិយាបន្ន សមធម៌ និងចីរភាព**»។

## ៤- គោលបំណងនិងគោលដៅ

### ៤.១- គោលបំណង

គោលនយោបាយនេះមានគោលបំណងធ្វើឱ្យប្រជាជននៅតំបន់ជនបទមានជីវភាពរស់នៅសមរម្យ ប្រកបដោយភាពធន់ មានសុខភាពមាំមួន រស់នៅក្នុងបរិស្ថានល្អប្រកបដោយចីរភាព និងមានសេចក្តីថ្លៃថ្នូរ ដែលនឹងរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជានិងជួយជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

### ៤.២- គោលដៅ

គោលនយោបាយនេះកំណត់គោលដៅអភិវឌ្ឍន៍ជនបទ ដោយផ្តោតទៅលើភូមិសាស្ត្រផ្សេងៗគ្នានៃប្រទេសកម្ពុជាឱ្យសម្រេចបានលទ្ធផលប្រកបដោយតុល្យភាព ភាពធន់ និងបរិយាបន្ន ចំនួន៤គឺ (១) តំបន់ជនបទមានហេដ្ឋារចនាសម្ព័ន្ធប្រទាក់ក្រឡាគ្នា (២) ប្រជាជននៅតំបន់ជនបទមានសុខភាពល្អនិងអាយុសង្ឃឹមរស់វែង (៣) ប្រជាជនរស់នៅក្នុងភូមិឋានដែលមានភាពសុខក្សេមក្សាន្ត និងមានបរិស្ថានល្អ និង(៤) ប្រជាជននៅតំបន់ជនបទមានកំណើនប្រាក់ចំណូលប្រកបដោយចីរភាព។

## ៥- យុទ្ធសាស្ត្រ

គោលនយោបាយនេះកំណត់យុទ្ធសាស្ត្រសំខាន់ៗចំនួន៥ និងវិធានការអនុវត្ត ព្រមទាំងបានកំណត់ស្ថាប័នពាក់ព័ន្ធ និងក្របខ័ណ្ឌពេលវេលាក្នុងការអនុវត្តដូចកំណត់នៅក្នុងតារាងម៉ាទ្រិក(បរិសិដ្ឋ៣) ដូចខាងក្រោម៖

### ៥.១- អភិវឌ្ឍនិងថែទាំហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ជនបទប្រកបដោយភាពធន់

**វិធានការអនុវត្តមានដូចតទៅ៖**

- ធ្វើបច្ចុប្បន្នកម្មផែនការមេសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ និងចងក្រងបញ្ជីខ្សែផ្លូវជនបទ ដោយផ្អែកទៅលើប្រភេទផ្លូវជនបទ កត្តាភូមិសាស្ត្រ និងកត្តាសក្តានុពលសេដ្ឋកិច្ចនិងសង្គម
- រៀបចំលិខិតបទដ្ឋានគតិយុត្តនិងបទដ្ឋានបច្ចេកទេសសម្រាប់គ្រប់គ្រង អភិវឌ្ឍ និងថែទាំហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ
- រៀបចំនិងអនុវត្តផែនការគម្រោងវិនិយោគ ដើម្បីតភ្ជាប់ លើកកម្រិតគុណភាព និងថែទាំហេដ្ឋារចនាសម្ព័ន្ធជនបទដែលមានភាពធន់ឱ្យប្រទាក់ក្រឡានៅក្នុងភូមិសាស្ត្រជនបទនៃតំបន់នីមួយៗ និងតភ្ជាប់ទៅកាន់តំបន់សក្តានុពលសេដ្ឋកិច្ចនិងសង្គម
- រៀបចំកម្មវិធីអប់រំ និងយុទ្ធនាការផ្សព្វផ្សាយសុវត្ថិភាពចរាចរណ៍ ព្រមទាំងចលនាអាជ្ញាធរមូលដ្ឋាននិងប្រជាជនមូលដ្ឋានឱ្យចូលរួមថែរក្សាហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ។

### ៥.២- ផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យជនបទទាំងកម្រិតមូលដ្ឋាន និងកម្រិតសុវត្ថិភាពប្រកបដោយភាពធន់និងបរិយាបន្ន

**វិធានការអនុវត្តមានដូចតទៅ៖**

- ធ្វើបច្ចុប្បន្នកម្មផែនការយុទ្ធសាស្ត្រជាតិ និងផែនការសកម្មភាពជាតិស្តីពី ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទដោយផ្អែកទៅលើតម្រូវការជាអាទិភាពរបស់ប្រជាជនរស់នៅក្នុងភូមិសាស្ត្រផ្សេងគ្នានៃតំបន់ទាំង៤ ជាពិសេសតំបន់ដែលមានសក្តានុពលសេដ្ឋកិច្ចនិងសង្គម

- រៀបចំ និងអនុវត្តផែនការគម្រោងវិនិយោគ ដើម្បីជំរុញ និងពង្រីកវិសាលភាពលើវិស័យផ្គត់ផ្គង់ទឹកស្អាតជនបទ និងអនាម័យជនបទកម្រិតមូលដ្ឋាន និងកម្រិតសុវត្ថិភាព ដោយផ្អែកតាមតម្រូវការជាអាទិភាពរបស់ប្រជាជននៅក្នុងតំបន់នីមួយៗ ជាពិសេសតំបន់ដែលមានសក្ដានុពលសេដ្ឋកិច្ច និងសង្គម
- រៀបចំលិខិតបទដ្ឋានគតិយុត្តនិងបទដ្ឋានបច្ចេកទេសសម្រាប់គ្រប់គ្រង អភិវឌ្ឍ និងថែទាំហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ
- អប់រំនិងផ្សព្វផ្សាយពីការគ្រប់គ្រង ការប្រើប្រាស់ទឹកស្អាត និងប្រតិបត្តិអនាម័យល្អនៅក្នុងគ្រួសារ និងនៅក្នុងសហគមន៍ជនបទ។

**៥.៣- អភិវឌ្ឍសហគមន៍ជនបទ ជាពិសេសជំរុញការអភិវឌ្ឍចម្រុះ និងបន្តការអនុវត្តចលនាភូមិមួយផលិតផលមួយ និងចលនាភូមិគំរូប្រកបដោយភាពធន់និងបរិយាបន្ន**

**វិធានការអនុវត្តមានដូចតទៅ៖**

- រៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ជំរុញការអភិវឌ្ឍសហគមន៍ជនបទ ជាពិសេសជំរុញការអភិវឌ្ឍចម្រុះ និងបន្តការអនុវត្តចលនាភូមិមួយផលិតផលមួយ ចលនាភូមិគំរូ នៅក្នុងភូមិជនបទទូទៅរួមទាំងភូមិនៅតាមបណ្ដោយព្រំដែន និងសហគមន៍ដីសម្បទានសង្គមកិច្ចគ្រប់ប្រភេទ ព្រមទាំងសហគមន៍ជនជាតិដើមភាគតិចដោយមានការចូលរួម និងភាពជាម្ចាស់របស់សហគមន៍មូលដ្ឋានប្រកបដោយភាពធន់និងបរិយាបន្ន
- រៀបចំលិខិតបទដ្ឋានគតិយុត្តនិងបទដ្ឋានបច្ចេកទេសសម្រាប់គ្រប់គ្រងនិងអភិវឌ្ឍភូមិ
- ជ្រើសរើសភូមិ ដើម្បីអភិវឌ្ឍតាមចលនាភូមិមួយផលិតផលមួយ និងចលនាគំរូ
- ពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍភូមិ(គ.អ.ភ.) ឱ្យក្លាយជាយន្តការដឹកនាំនិងសម្របសម្រួលការងារអភិវឌ្ឍន៍ភូមិប្រកបដោយប្រសិទ្ធភាពនិងចីរភាព
- បណ្ដុះផ្នត់គំនិតប្រជាពលរដ្ឋជនបទឱ្យមានភាពជាម្ចាស់លើជោគវាសនារបស់ខ្លួននិងសហគមន៍ស្គាល់និងស្រឡាញ់វប្បធម៌ប្រពៃណីជាតិ ព្រមទាំងមានស្មារតីសាមគ្គីសហគមន៍ តាមរយៈការអប់រំផ្ទាល់ការបណ្ដុះបណ្ដាល ការផ្សព្វផ្សាយ និងការបង្កើតកម្មវិធីប្រពៃណីនិងសាសនា ព្រមទាំងកម្មវិធីសង្គមនានាដោយផ្ទាល់និង/ឬតាមបណ្ដាញសង្គមឌីជីថល ដើម្បីកសាងពលរដ្ឋមានសមត្ថភាព ផលិតភាពសីលធម៌ គុណធម៌ ចរិយាធម៌ ភាពអំណត់ សុចរិតភាព វិន័យ ការទទួលខុសត្រូវខ្ពស់ និងមនសិការស្នេហាជាតិ គ្រួសារគំរូ សហគមន៍គំរូ គ្មានអំពើហិង្សានិងគ្មានអំពើអបាយមុខផ្សេងៗ និងមានសមត្ថភាពចូលរួមអភិវឌ្ឍ អភិរក្សវប្បធម៌ប្រពៃណី ការពារធនធាន រួមទាំងការជួយសង្គ្រោះសហគមន៍ ការចេះយកអាសារគ្នាក្នុងគ្រាមានអាសន្ន និងដោះស្រាយបញ្ហានានានៅក្នុងសហគមន៍ប្រកបដោយភាពជាម្ចាស់ ក៏ដូចជាដើម្បីចូលរួមជំរុញការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»
- បណ្ដុះបណ្ដាលភាពជាអ្នកដឹកនាំដល់យុវជនតាមភូមិជនបទ ដើម្បីក្លាយទៅជាអ្នកដឹកនាំបន្តវេនក្នុងការអភិវឌ្ឍភូមិប្រកបដោយបរិយាបន្ន។

**៥.៤- បង្កើនប្រាក់ចំណូលគ្រួសារនៅតំបន់ជនបទប្រកបដោយចីរភាព តាមរយៈពិពិធកម្មមុខរបរ និងនវានុវត្តន៍ការងារ**

**វិធានការអនុវត្តមានដូចតទៅ៖**

- សិក្សានិងចងក្រងមុខរបរនៅតំបន់ជនបទតាមសក្ដានុពលនៃតំបន់ភូមិសាស្ត្រផ្សេងៗគ្នា និងបង្កើតមុខរបរថ្មីៗ ព្រមទាំងឱកាសការងារសមរម្យនៅក្នុងតំបន់នីមួយៗបន្ថែមទៀត

- សិក្សាពីតម្រូវការបណ្តុះបណ្តាលបច្ចេកទេស ជំនាញបំណិនជីវិត ជំនាញវិជ្ជាជីវៈជូនតា និងជំនាញសហគ្រិនភាព និងរៀបចំកម្មវិធីបណ្តុះបណ្តាលប្រជាពលរដ្ឋនៅតំបន់ជនបទ ជាពិសេសយុវជន ដើម្បីរួមចំណែកអភិវឌ្ឍមូលធនមនុស្សនៅតំបន់ជនបទ
- លើកកម្ពស់ជាតូនីយកម្ម តាមរយៈការគាំទ្រនិងជំរុញផលិតកម្មកែច្នៃផលិតផលនៅក្នុងសហគមន៍មូលដ្ឋាន និងលើកស្ទួយអត្តសញ្ញាណផលិតផលជាតិ ដើម្បីផ្គត់ផ្គង់តម្រូវការទីផ្សារក្នុងស្រុកគ្រប់គ្រាន់ និងនាំចេញទៅទីផ្សារក្រៅប្រទេស
- ចងក្រងក្រុមសន្សំប្រាក់នៅតាមសហគមន៍ផលិត ដើម្បីផ្តល់មូលនិធិធ្វើជាទុនបង្វិល ដោយមានការគាំទ្រនីតិវិធី តាមដាន ត្រួតពិនិត្យ និងវាយតម្លៃពីក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីធានាប្រសិទ្ធភាពនិងនិរន្តរភាព។

**៥.៥- លើកកម្ពស់អភិបាលកិច្ច ឌីជីថល និងកិច្ចសហប្រតិបត្តិការ**

**វិធានការអនុវត្តមានដូចតទៅៈ**

- ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដើម្បីគាំទ្រនិងបំពេញតម្រូវការឱ្យគ្នាទៅវិញទៅមកនៅក្នុងដំណើរការអភិវឌ្ឍន៍ជនបទ
- ពង្រឹងនិងពង្រីកទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសជាមិត្ត ទាំងទ្វេភាគីនិងពហុភាគី ដើម្បីរៀនសូត្រនិងចែករំលែកបទពិសោធល្អនៃការងារអភិវឌ្ឍន៍ជនបទ
- កៀរគរដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល សហគមន៍ជនបទមូលដ្ឋាន វិស័យឯកជន និងសប្បុរសជន ដើម្បីចូលរួមគាំទ្រដល់ដំណើរការអភិវឌ្ឍន៍ជនបទ
- ចូលរួមអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ដោយរៀបចំយន្តការសម្របសម្រួលនិងទំនាក់ទំនង ដើម្បីអនុវត្តការងារអភិវឌ្ឍន៍ជនបទឱ្យបានគ្រប់ជ្រុងជ្រោយនិងមានប្រសិទ្ធភាពខ្ពស់។

**ដ្យាក្រាម : ចក្ខុវិស័យ គោលបំណង គោលដៅ និងយុទ្ធសាស្ត្រនៃគោលនយោបាយ**



## ៦- ផែនការសកម្មភាព

### ៦.១- ការបង្កើតយន្តការ

ដោយការងារអភិវឌ្ឍន៍ជនបទមានលក្ខណៈចម្រុះនិងអន្តរវិស័យ គោលនយោបាយនេះត្រូវប្រើយន្តការរបស់រាជរដ្ឋាភិបាលដែលមានស្រាប់។ ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងស្ថាប័នដែលជាសេនាធិការឲ្យរាជរដ្ឋាភិបាល មានសមត្ថកិច្ចក្នុងការអនុវត្តតួនាទីនិងភារកិច្ចដែលមានចែងក្នុងអនុក្រឹត្យស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង ស្ថាប័នរៀងៗខ្លួន ដើម្បីដឹកនាំ គ្រប់គ្រង អនុវត្ត និងសម្របសម្រួលឱ្យមានការចូលរួមសហការពីរដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល សហគមន៍មូលដ្ឋាន និងសប្បុរសជននានាស្របតាមអភិក្រម **«ជវភាពនៃប្រព័ន្ធតួអង្គតែមួយ»** របស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីកសាងបានជា **«សហថាមពល»** នៅក្នុងការអភិវឌ្ឍជនបទប្រកបដោយប្រសិទ្ធភាពនិងសក្តិសិទ្ធិភាព(បរិសិដ្ឋ៤)។ ទន្ទឹមគ្នានេះ ត្រូវពង្រឹងការលើកទឹកចិត្តឱ្យមានការចូលរួមនិងភាពជាម្ចាស់របស់រដ្ឋបាលខេត្ត ស្រុក ឃុំ ភូមិ និងប្រជាជននៅក្នុងមូលដ្ឋាន និងពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍភូមិ(គ.អ.ភ.) ព្រមទាំងការចងសម្ព័ន្ធមេត្រីភាពរវាងសហគមន៍ជនបទជាមួយនឹងសហគមន៍ជនបទផ្សេងទៀតទាំងនៅក្នុងនិងក្រៅប្រទេស។

### ៦.២- ការបង្កើតក្របខ័ណ្ឌគតិយុត្ត

ដើម្បីអនុវត្តគោលនយោបាយជាតិនេះ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងកម្មវិធីស្ដីពីការអភិវឌ្ឍជនបទដែលមានស្រាប់ នឹងត្រូវធ្វើការកែសម្រួលឡើងវិញស្របតាមការចាំបាច់។ ចំពោះលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យអភិវឌ្ឍន៍ជនបទដែលមិនទាន់មាន នឹងត្រូវរៀបចំបង្កើតឡើង ដើម្បីធានានូវប្រសិទ្ធភាព សក្តិសិទ្ធិភាព និងសង្គតិភាពទៅនឹងកម្មវិធីនយោបាយនិងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល។

### ៦.៣- ការគាំទ្រហិរញ្ញវត្ថុ

គោលនយោបាយជាតិនេះនឹងប្រើប្រាស់ហិរញ្ញប្បទានសម្រាប់ការអនុវត្តសកម្មភាពគាំទ្រដែលមានប្រភពមកពីថវិកាជាតិ ហិរញ្ញប្បទានសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ ថវិការបស់អង្គការមិនមែនរដ្ឋាភិបាល និងប្រភពស្របច្បាប់ផ្សេងទៀត។

### ៦.៤- ការបណ្តុះបណ្តាលធនធានមនុស្ស

ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយជាតិនេះ រាជរដ្ឋាភិបាលកម្ពុជាបន្តអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណវុឌ្ឍិ តាមរយៈការរៀបចំនិងអនុវត្តកម្មវិធីបណ្តុះបណ្តាលរយៈពេលខ្លី មធ្យម និងវែង ដើម្បីអភិវឌ្ឍចំណេះដឹងនិងជំនាញដល់មន្ត្រីទទួលបន្ទុកការងារអភិវឌ្ឍន៍ជនបទនៅគ្រប់កម្រិតទាំងមន្ត្រីថ្នាក់ជាតិ និងមន្ត្រីថ្នាក់ក្រោមជាតិ ព្រមទាំងបង្កើនចំណេះដឹងនិងបទពិសោធការងារក្នុងវិស័យអភិវឌ្ឍន៍ជនបទសម្រាប់អ្នកបន្តវេនជំនាន់ក្រោយផងដែរ។

### ៦.៥- ដំណើរការអនុវត្តន៍

គោលនយោបាយជាតិនេះ នឹងត្រូវប្រកាន់យកនូវវិធីសាស្ត្រអនុវត្តន៍(បរិសិដ្ឋ៥) ដែលមានលក្ខណៈជារចនាសម្ព័ន្ធនិងជាដំណាក់កាល (Structured and Phased Approach) ដើម្បីអនុវត្តកម្មវិធីអាទិភាពនៃគោលនយោបាយ ដោយរៀបជាចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទរយៈពេលខ្លី មធ្យម និងវែង និងកំណត់ក្របខ័ណ្ឌតាមដាន និងការវាយតម្លៃសំដៅធានានូវការអនុវត្តប្រកបដោយប្រសិទ្ធភាពនិងទាន់ពេលវេលា។

ទន្ទឹមគ្នានេះ ដំណើរការអនុវត្ត ត្រូវមានការចូលរួមសហការអនុវត្តយ៉ាងជិតស្និទ្ធពីគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ។ គោលនយោបាយជាតិនេះ នឹងត្រូវពិនិត្យឡើងវិញ ដើម្បីពិនិត្យលទ្ធភាពនៃការធ្វើបច្ចុប្បន្នកម្ម និងកំណត់ចំណុចត្រូវកែលម្អក្នុងរយៈពេល៥ឆ្នាំម្តងឬស្របទៅតាមការប្រែប្រួលនៃវិស័យអភិវឌ្ឍន៍ជនបទ។

ផ្អែកលើយុទ្ធសាស្ត្រនៃគោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនបទ ឆ្នាំ២០២៥ - ២០៣៥ ក្រសួងអភិវឌ្ឍន៍ជនបទកំណត់យកកម្មវិធីអាទិភាព ចំនួន៥គឺ៖

- **កម្មវិធីអាទិភាពទី១ :** **ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទប្រទាក់ក្រឡាប្រកបដោយភាពធន់នឹងការប្រែប្រួលអាកាសធាតុ** តាមរយៈការលើកកម្រិតគុណភាព និងការថែទាំផ្លូវជនបទឱ្យមាននិរន្តរភាព ដើម្បីតភ្ជាប់ និងសមាហរណកម្មវិស័យសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ រវាងតំបន់ជនបទ និងទីក្រុង ផ្សាភ្ជាប់សកម្មភាពធុរកិច្ចផ្សេងៗឱ្យមានភាពរស់រវើក និងកាន់តែសកម្មឡើងបន្ថែមទៀត ដែលជាមូលដ្ឋានគ្រឹះនៃកំណើនប្រាក់ចំណូលរបស់គ្រួសារនៅតំបន់ជនបទ
- **កម្មវិធីអាទិភាពទី២ :** **ការកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់ប្រជាជននៅតំបន់ជនបទ** តាមរយៈការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត ប្រកបដោយបរិយាបន្ននិងភាពធន់ និងការអនុវត្តអនាម័យផ្ទាល់ខ្លួនតាមក្បួនខ្នាតត្រឹមត្រូវ ដើម្បីធ្វើឱ្យប្រជាជនមានសុខភាពល្អ និងមានបរិស្ថានរស់នៅល្អ ជៀសផុតពីជំងឺឆ្លងផ្សេងៗ ហើយអាយុកាលសង្ឃឹមរស់ជាមធ្យមរបស់ប្រជាជនកាន់តែវែង ដែលជាសេចក្តីប្រាថ្នារបស់មនុស្សគ្រប់រូប និងរួមចំណែកអភិវឌ្ឍប្រទេសកម្ពុជាឱ្យកាន់តែរីកចម្រើនបន្ថែមទៀត
- **កម្មវិធីអាទិភាពទី៣ :** **ការអភិវឌ្ឍភូមិ និងសហគមន៍ជនបទចម្រុះប្រកបដោយភាពធន់ ឌីជីថល និងបរិយាបន្ន** តាមរយៈការអភិវឌ្ឍភូមិគំរូគន្លឹះ និងការអភិវឌ្ឍសហគមន៍ជនបទចម្រុះ រួមទាំងរួមទាំងសហគមន៍ជីសម្បទានសង្គមកិច្ចគ្រប់ប្រភេទ និងសហគមន៍ជនជាតិដើមភាគតិច ដោយកសាងមូលធនមនុស្ស និងប្រភពធនធាននៅក្នុងមូលដ្ឋានដើម្បីធ្វើឱ្យតំបន់ជនបទមានការរីកចម្រើន និងស៊ីវិល័យប្រកបដោយសេចក្តីថ្លៃថ្នូរតជំនាន់ទៅអនាគត
- **កម្មវិធីអាទិភាពទី៤ :** **ការធ្វើពិពិធកម្មសេដ្ឋកិច្ចគ្រួសារនៅតំបន់ជនបទ** តាមរយៈការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ជំនាញបំណិនជីវិត សហគ្រិនភាព ដើម្បីបង្កើតមុខរបរ ទីផ្សារ ឱកាសការងារ និងកំណើនប្រាក់ចំណូលគ្រួសារ ព្រមទាំងកាត់បន្ថយការធ្វើចំណាកស្រុកដោយប្រថុយប្រថាន
- **កម្មវិធីអាទិភាពទី៥ :** **ការពង្រឹងអភិបាលកិច្ច និងកិច្ចសហប្រតិបត្តិការ** តាមរយៈការរៀបចំគោលនយោបាយ ហិរញ្ញវត្ថុ ឌីជីថល និងសហប្រតិបត្តិការ ដើម្បីចូលរួមអនុវត្តកម្មវិធីកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល ធានាប្រសិទ្ធភាពក្នុងការផ្តល់សេវា ដោយគណនេយ្យភាព តម្លាភាព សហប្រតិបត្តិការ និងអភិបាលកិច្ចល្អ សំដៅគ្រប់គ្រងនិងការអនុវត្តផែនការថវិកានៃកម្មវិធីអភិវឌ្ឍន៍ជនបទឱ្យមានប្រសិទ្ធភាព និងសក្តិសិទ្ធិភាព។

## ៧- ការតាមដាននិងការវាយតម្លៃ

ប្រសិទ្ធភាពនិងភាពជោគជ័យនៃការអនុវត្តគោលនយោបាយជាតិនេះ ពឹងផ្អែកយ៉ាងខ្លាំងទៅលើការរៀបចំយន្តការអនុវត្តដែលមានលក្ខណៈជាប្រព័ន្ធ មានភាពច្បាស់លាស់ មានឆន្ទៈនយោបាយមោះមុត មានធនធានគ្រប់គ្រាន់ ព្រមទាំងការបែងចែកតួនាទីនិងការទទួលខុសត្រូវច្បាស់លាស់ទៅតាមក្រសួង ស្ថាប័នពាក់ព័ន្ធនីមួយៗ និងមានយន្តការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ដើម្បីតាមដានលទ្ធផល តម្រង់ទិស និងជំរុញការអនុវត្តយុទ្ធសាស្ត្រនេះជាប្រចាំ។ ក្របខ័ណ្ឌតាមដាននិងវាយតម្លៃនៃការអនុវត្តគោលនយោបាយជាតិនេះ នឹងប្រកាន់ខ្ជាប់នូវអភិក្រមជវភាពនៃប្រព័ន្ធតួអង្គតែមួយនិងអភិក្រមទាំង៥(ប្រាំ)**«ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់»** ដែលមានសហថាមពលព្រមគ្នានិងសង្គតិភាពជាមួយគ្នា មានកិច្ចសម្របសម្រួលខ្ពស់និងការទទួលខុសត្រូវ មានកិច្ចសហការល្អនិងការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធ និងមានការរៀបចំការត្រួតពិនិត្យលទ្ធផលជាប្រចាំ។

ទន្ទឹមនេះ ដើម្បីធានានូវសង្គតិភាព ប្រសិទ្ធភាព និងសក្តិសិទ្ធិភាព ក្រសួងអភិវឌ្ឍន៍ជនបទ ដែលមានតួនាទីសម្របសម្រួល តាមដាននិងវាយតម្លៃការអនុវត្តវិធានការទាំងនេះ ត្រូវវាស់វែងលទ្ធផលនៃការអនុវត្តនិងរៀបចំជារបាយការណ៍វឌ្ឍនភាពជារៀងរាល់ឆ្នាំនិង៥(ប្រាំ)ឆ្នាំម្តងជូនរាជរដ្ឋាភិបាល។ ដោយឡែក សូចនាករសមិទ្ធកម្មគន្លឹះនឹងត្រូវវាយតម្លៃស្របតាមផែនការយុទ្ធសាស្ត្រ និងផែនការប្រចាំឆ្នាំនៃក្រសួង ស្ថាប័នពាក់ព័ន្ធ។

**ដំណាក់កាលនៃការតាមដាននិងការវាយតម្លៃ**




## ៨- សេចក្តីសន្និដ្ឋាន

គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនបទ ឆ្នាំ២០២៥-២០៣៥ មានខ្លឹមសារលម្អិតគ្រប់ជ្រុងជ្រោយ ដោយបានកំណត់ចក្ខុវិស័យ គោលបំណង គោលដៅ យុទ្ធសាស្ត្រ និងផែនការសកម្មភាព ដោយផ្អែកទៅលើគោលការណ៍ បទពិសោធ និងការវិភាគស្ថានភាពជនបទ ដោយបានបង្ហាញយ៉ាងជាក់លាក់នូវទិន្នន័យ បញ្ហាការប្រឈម កាលានុវត្តភាព នៃតំបន់ជនបទនៅក្នុងប្រទេសកម្ពុជា។ គោលនយោបាយជាតិនេះ គឺជាផែនទីបង្ហាញផ្លូវក្នុងការអភិវឌ្ឍតំបន់ជនបទកម្ពុជាប្រកបដោយវិបុលភាព បរិយាប័ន្ន និងចិរភាពចាប់ពីពេលនេះ រហូតដល់ឆ្នាំ២០៣៥ ដើម្បីឱ្យគ្រប់ក្រសួងនិងស្ថាប័នទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិរៀបចំឯកសារគតិយុត្ត ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងអនុវត្តផ្ទាល់ជាក់ស្តែង ព្រមទាំងតាមដាននិងវាយតម្លៃ ដើម្បីគាំទ្រដល់ការងារអភិវឌ្ឍន៍ជនបទនៅទូទាំងប្រទេសកម្ពុជា ដោយខិតខំកៀរគរធនធានពីប្រភពផ្សេងៗ ទាំងជំនួយបច្ចេកទេសនិងហិរញ្ញវត្ថុ ព្រមទាំងកៀរគរការចូលរួមពីដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាលសហគមន៍ជនបទមូលដ្ឋាន និងសប្បុរសជននានា ចូលរួមនិងទ្រទ្រង់ដល់ដំណើរការនៃការអភិវឌ្ឍជនបទឱ្យទទួលបានលទ្ធផលជាវិជ្ជមានប្រកបដោយប្រសិទ្ធភាព និងសក្តិសិទ្ធិភាព ស្របតាមអភិក្រម **«ជវភាពប្រព័ន្ធតួអង្គតែមួយ»** ដែលរួមគ្នាកសាងនូវ

«**សហថាមពល**»សម្រាប់ការអនុវត្តការងារអភិវឌ្ឍន៍ជនបទនៅក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យមានវិបុលភាព ប្រកបដោយបរិយាបន្ននិងចីរភាព ដែលនឹងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងការបន្ថយភាពក្រីក្រ របស់ប្រជាជនកម្ពុជាស្របតាមយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីឆ្ពោះទៅសម្រេចបាន នូវចក្ខុវិស័យ«**កម្ពុជាក្លាយជាប្រទេសមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០**»។

## បរិសិដ្ឋ

### បរិសិដ្ឋ១ : សទ្ទានុក្រម

| | |
|---|---|
| កាលានុវត្តភាព | សំដៅដល់កាលៈទេសៈដ៏គួរសមគួរ ឬដំណើរវិវឌ្ឍត្រូវពេលវេលា ឱកាសដែលអនុគ្រោះសម្រាប់ចាប់យកប្រយោជន៍កិច្ចការអ្វីមួយឬគុណសម្បត្តិអ្វីមួយដែលកំពុងលេចឡើង ក៏ប៉ុន្តែការទាញយកប្រយោជន៍នោះគឺអាចប្រឈមនឹងហានិភ័យ ហើយចាំបាច់ត្រូវប្ដេជ្ញាចិត្តយ៉ាងមុតមាំ និងមានធនធានគ្រប់គ្រាន់ ទើបគេអាចទាញយកប្រយោជន៍នោះ។ |
| គ្រួសារក្រ១ និង គ្រួសារក្រ២ | សំដៅដល់ការធ្វើចំណាត់ថ្នាក់តាមកម្រិតភាពក្រីក្រៈ ក្រកម្រិត១ (ទីទ័លក្រ) ក្រកម្រិត២ (ក្រីក្រ) ដោយផ្អែកលើពិន្ទុនិងការពិចារណាលើស្ថានភាពពិសេសដែលទទួលបានពីលទ្ធផលសម្ភាសដោយប្រើប្រាស់បញ្ជីសំណួរសម្រាប់កំណត់អត្តសញ្ញាណគ្រួសារក្រីក្រនិងក្រុមគោលដៅងាយរងគ្រោះដែលក្រុមប្រឹក្សាឃុំ សង្កាត់។ |
| គ្រួសារងាយរងហានិភ័យឬងាយរងគ្រោះ | សំដៅដល់គ្រួសារដែលរស់នៅក្បែរបន្ទាត់នៃភាពក្រីក្រ ហើយយ៉ាងហោចណាស់គ្រួសារនោះមានភាពងាយរងគ្រោះមួយយ៉ាងតិចក្នុងចំណោមប្រាំ ដូចជា (១) មានសមាជិកយ៉ាងតិចម្នាក់មានពិការភាព (២) មានមនុស្សចាស់ជរាយ៉ាងតិចម្នាក់អាយុស្មើឬលើស ៦០ឆ្នាំ (៣) មានកុមារតូចដែលមានអាយុតិចជាង២ឆ្នាំ (៤) គ្រួសារមានសមាជិកជាកុមារអាយុក្រោម១៨ឆ្នាំទាំងអស់ ឬ(៥) មេគ្រួសារជាស្ត្រី (នៅម្នាក់ឯងឬមេម៉ាយ) |
| ជវភាពនៃប្រព័ន្ធតួអង្គតែមួយ | សំដៅដល់ការចូលរួមនិងគ្រប់គ្រងអ្នកពាក់ព័ន្ធជាបន្តបន្ទាប់ពេញមួយវដ្តជីវិតនៃគម្រោងឬគោលនយោបាយ។ វិធីសាស្ត្រនេះទទួលស្គាល់ថាផលប្រយោជន៍ ឥទ្ធិពល និងការចូលរួមរបស់ភាគីពាក់ព័ន្ធអាចផ្លាស់ប្តូរតាមពេលវេលា ដែលទាមទារយុទ្ធសាស្ត្របន្សាំដើម្បីរក្សាកិច្ចសហការនិងការគាំទ្រប្រកបដោយប្រសិទ្ធភាព។ |
| ឌីជីថលនីយកម្ម ឬ ឌីជីថលូបនីយកម្ម | សំដៅដល់ដំណើរការនៃការកែសម្រួលអភិបាលកិច្ច ធុរកិច្ច ឬដំណើរការការងារឱ្យមានប្រសិទ្ធភាព តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងទិន្នន័យក្នុងទម្រង់ឌីជីថល។ |
| ថវិកាសមិទ្ធកម្ម | សំដៅដល់ប្រព័ន្ធថវិកាដែលមានគោលបំណងក្នុងការបង្កើនប្រសិទ្ធភាពនិងសក្តិសិទ្ធិភាពនៃចំណាយសាធារណៈតាមរយៈការផ្សារភ្ជាប់ការវិភាជថវិកាសម្រាប់អង្គភាពសាធារណៈទៅនឹងលទ្ធផលដែលសម្រេចបាន ដោយប្រើប្រាស់ព័ត៌មានសមិទ្ធកម្ម ដែលមានលក្ខណៈជាប្រព័ន្ធ។ បន្ថែមពីនេះ ថវិកាសមិទ្ធកម្មអាចបង្កើនគណនេយ្យភាពកាន់តែរឹងមាំសម្រាប់ឆ្លើយតបទៅនឹងលទ្ធផលទន្ទឹមនឹងការផ្តល់នូវភាពបត់បែនបន្ថែមដល់អ្នកគ្រប់គ្រងដើម្បីសម្រេចចិត្តអំពីរបៀបក្នុងការផ្តល់សេវាសាធារណៈដ៏ល្អបំផុត។ |
| និរន្តរភាព | សំដៅដល់ភាពដែលអាចកើតមានជាបន្តបន្ទាប់ឥតដាច់។ |
| នវានុវត្តន៍ | សំដៅដល់ការបញ្ចូលមកថ្មី ការមកដល់ថ្មី ការអនុវត្តបែបថ្មី និងការច្នៃប្រឌិត។ |
| បរិយាបន្ន | សំដៅដល់ការលើកកម្ពស់ស្ថានភាពរបស់បុគ្គលនិងក្រុមនានាក្នុងការចូលរួមនិងការទទួលសេវាឬផលពីសកម្មភាពនានារបស់សង្គមដោយមិនរើសអើង។ |

| | |
|---|---|
| ប្រព័ន្ធតាមដាន និងវាយតម្លៃ | សំដៅដល់ឧបករណ៍គ្រប់គ្រងវិស័យសាធារណៈដ៏សំខាន់មួយសម្រាប់រដ្ឋាភិបាលក្នុងការសម្រេចបាននូវលទ្ធផលកាន់តែប្រសើរឡើង និងឆ្លើយតបប្រកបដោយប្រសិទ្ធភាពជូនប្រជាពលរដ្ឋ វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល អង្គការសង្គមស៊ីវិល អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍនានាដែលកំពុងទាមទារនូវការផ្តល់លទ្ធផលជាក់ស្តែងនិងសមិទ្ធកម្មកាន់តែប្រសើរឡើង។ ប្រព័ន្ធនេះមានសមាសធាតុ ដូចជាសូចនាករសមិទ្ធកម្ម របាយការណ៍ សមិទ្ធកម្ម ការត្រួតពិនិត្យសមិទ្ធកម្ម ការវាយតម្លៃនិងប្រព័ន្ធទិន្នន័យដែលអាស្រ័យឬមិនអាស្រ័យគ្នាទៅវិញទៅមក។ |
| ប្រសិទ្ធភាព | សំដៅដល់កម្រិតឬសមត្ថភាពដែលសម្រេចបានជាលទ្ធផលតាមការគ្រោងទុក។ |
| ផលជះ ឬកម្មវិបាក | សំដៅដល់លទ្ធផលចុងក្រោយបំផុតនៃកម្មវិធីដែលជាមូលដ្ឋានក្នុងការវាយតម្លៃលើប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីឬគោលនយោបាយនៅក្នុងបរិការណ៍ណាមួយ។ ឧទាហរណ៍ ស្ថានភាពសង្គម អត្រាក្រីក្រថយចុះ ឬអត្រាអ្នកមានការងារធ្វើកើនឡើង ជាដើម។ |
| ផែនការយុទ្ធសាស្ត្រថវិកា | សំដៅដល់ការរៀបចំផែនការថវិកាពីក្រោមឡើងទៅលើ ឬពីក្រោមក្រសួង ស្ថាប័ន ដើម្បីសម្រេចបានគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល។ ផែនការយុទ្ធសាស្ត្រថវិកានេះ ធ្វើឡើងរយៈពេលបីឆ្នាំ ដោយផ្តល់នូវការធ្វើវិភាជបឋមមុនពេលរៀបចំកញ្ចប់លម្អិត និងរួមបញ្ចូលគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ន កម្មវិធី ឬយុទ្ធសាស្ត្រអាទិភាព សូចនាករ និងគោលដៅសូចនាករ និងការបែងចែកធនធានចរន្ត និងធនធានមូលធន ទាំងថវិការដ្ឋនិងថវិកាដៃគូអភិវឌ្ឍ។ |
| ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ | សំដៅដល់ឧបករណ៍អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលត្រូវបានបង្កើតឡើងក្នុងគោលបំណងប្រមូលផ្តុំគោលនយោបាយលើគ្រប់វិស័យដែលជាត្រីវិស័យសម្រាប់រៀបចំផែនការប្រតិបត្តិ ដោយមានកំណត់សូចនាករតាមវិស័យនិងតាមឆ្នាំនីមួយៗ។ |
| ផ្គត់ផ្គង់ទឹកកម្រិតមូលដ្ឋាន | សំដៅដល់ទឹកផឹកទទួលបានពីប្រភពទឹកដែលមានការកែលម្អក្នុងកម្រិតមូលដ្ឋាន ហើយអ្នកប្រើប្រាស់អាចទៅយកទឹកមកប្រើប្រាស់ ដោយចំណាយពេលទាំងទៅនិងមកតិចជាង៣០នាទី។ ទឹកជាមូលដ្ឋាន អាចយកមកពីអណ្តូងស្នប់ ឬទឹកស្រះ ទឹកទន្លេ ស្ទឹង បឹងបួ ដែលយកមកច្រោះឬដាំពុះមុននឹងយកមកប្រើប្រាស់។ |
| ផ្គត់ផ្គង់ទឹកស្អាតកម្រិតសុវត្ថិភាព | សំដៅដល់ទឹកគ្មានមេរោគបង្កជំងឺ គ្មានសារជាតិគីមីពុល និងមនុស្សគ្រប់រូបអាចយកមកប្រើបានគ្រប់ពេលវាលានិងគ្រប់ទីកន្លែង(ទាំងក្មេង ទាំងចាស់ មានទឹកប្រើប្រាស់បានគ្រប់ពេលវេលានិងគ្រប់ទីកន្លែង)។ |
| ផ្លូវជនបទកំណត់ជា៤ប្រភេទ (T1 T2 T3 T4) | ប្រភេទទី១(T1) សំដៅដល់ផ្លូវដែលភ្ជាប់ពីផ្លូវជាតិ ផ្លូវខេត្ត ឆ្ពោះទៅកាន់ទីរួមក្រុង ស្រុក ខណ្ឌ និងផ្លូវដែលភ្ជាប់ពីទីរួមក្រុង ស្រុក ខណ្ឌ ឆ្ពោះទៅកាន់ទីរួមក្រុង ស្រុក ខណ្ឌ។<br>ប្រភេទទី២(T2) សំដៅដល់ផ្លូវដែលភ្ជាប់ពីទីរួមក្រុង ស្រុក ខណ្ឌ ឆ្ពោះទៅកាន់ទីប្រជុំជនឃុំ។ |

| | |
|---|---|
| | ប្រភេទទី៣(T3) សំដៅដល់ផ្លូវដែលភ្ជាប់ពីទីប្រជុំជនឃុំឆ្ពោះទៅកាន់ទីប្រជុំជនឃុំ។<br>ប្រភេទទី៤(T4) សំដៅដល់ផ្លូវដែលភ្ជាប់ពីទីប្រជុំជនឃុំឆ្ពោះទៅកាន់ទីប្រជុំជនភូមិ ផ្លូវដែលភ្ជាប់ពីទីប្រជុំជនភូមិឆ្ពោះទៅកាន់ទីប្រជុំជនភូមិនិងផ្លូវក្នុងភូមិ។ |
| **ពិពិធកម្ម** | សំដៅដល់ធ្វើឱ្យមានចម្រុះកម្ម ភាពសម្បូរបែប ការកើតមានឬប្រែក្លាយជាបែបផែនផ្សេងៗ។ |
| **មូលធនមនុស្ស** | សំដៅដល់សុខភាព ចំណេះដឹង និងបំណិនជីវិត(ចំណេះច្បាស់លាស់ មានជំនាញ បំណិនជីវិតយ៉ាងតិចមួយ និងមានឥរិយាបថល្អ ថ្លៃថ្នូរ)។ |
| **វិមជ្ឈការ** | សំដៅដល់ការដែលរាជរដ្ឋាភិបាលប្រគល់ឱ្យក្រុមប្រឹក្សានូវភាពជាម្ចាស់លើមុខងារ សិទ្ធិអំណាច និងធនធាន ដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់មូលដ្ឋាន។ ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋមូលដ្ឋានលើបញ្ហាទាំងនេះ។ |
| **វិសហមជ្ឈការ** | សំដៅដល់ការដែលរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ន ធ្វើប្រតិភូកម្មមុខងារ សិទ្ធិអំណាច និងធនធានទៅអង្គភាពក្រោមបង្គាប់ឬទៅក្រុមប្រឹក្សាប្រភេទណាមួយ ដើម្បីអនុវត្តក្នុងនាមរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ន។ អង្គភាពឬក្រុមប្រឹក្សានោះ ត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលឬក្រសួង ស្ថាប័នស្របតាមតម្រូវការនៃការធ្វើប្រតិភូកម្មនោះ។ |
| **វិបុលភាព** | សំដៅដល់ភាពមានបាន ភាពរីកចម្រើនរុងរឿង ។ |
| **វិសមភាព** | សំដៅដល់ភាពមិនស្មើគ្នា។ |
| **សង្គតិភាព** | សំដៅដល់គ្រប់ក្រសួង ស្ថាប័ន ឬអង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់របស់ព្រះរាជាណាចក្រកម្ពុជាត្រូវអនុវត្តគោលការណ៍តែមួយដោយប្រទាក់ក្រឡាគ្នា។ |
| **សមិទ្ធកម្ម** | សំដៅដល់កម្រិតសមត្ថភាព វិសាលភាព លទ្ធភាព ឬគុណភាពនៃប្រតិបត្តិករ ឬនៃកិច្ចអន្តរាគមន៍ណាមួយ អាចអនុវត្តបានស្របតាមលក្ខណវិនិច្ឆ័យ/ បទដ្ឋាន/ គោលការណ៍ណែនាំជាក់លាក់ ឬសម្រេចលទ្ធផលតាមគោលបំណងឬផែនការគ្រោងទុក។ |
| **សហថាមពល** | សំដៅដល់ការធ្វើកិច្ចការរួមគ្នា ឬការរួមបញ្ចូលកម្លាំងគ្នារវាងក្រសួង ស្ថាប័ន ភ្នាក់ងារ ឬបុគ្គលពីរឬច្រើន នឹងទទួលបានលទ្ធផលខ្ពស់ជាង។ |
| **សក្តិសិទ្ធិភាព** | សំដៅដល់វិសាលភាពឬកម្រិតលទ្ធផល ដែលសម្រេចបានស្របតាមគោលបំណង និងជាកត្តាសំខាន់ក្នុងការសម្រេចបាននូវលទ្ធផលចុងក្រោយដែលបានគ្រោងទុក។ សក្តិសិទ្ធិភាពរួមបញ្ចូលទាំងការរកឱ្យឃើញអំពីលទ្ធផលចុងក្រោយ និងការកំណត់ទំនាក់ទំនងរវាងហេតុនិងផល។ |
| **សុខដុមនីយកម្ម** | សំដៅដល់ការកែសម្រួលភាពផ្សេងៗគ្នា និង/ឬភាពមិនស៊ីចង្វាក់គ្នាដែលពាក់ព័ន្ធនឹងការវាស់វែង វិធីសាស្ត្រ នីតិវិធី កាលវិភាគ លក្ខណៈបច្ចេកទេស ឬប្រព័ន្ធ ដើម្បីធ្វើឱ្យមានឯកភាពឬមានភាពសមស្របសម្រាប់ទាំងអស់គ្នា។ |

| | |
|---|---|
| សូចនាករ | សំដៅដល់អថេរ(មានលក្ខណៈជាបរិមាណឬគុណភាព) ដែលមានភាពជឿជាក់និងងាយស្រួលសម្រាប់ជ្រើសរើសយកមកវាស់វែងវឌ្ឍនភាព និងឆ្លុះបញ្ចាំងការផ្លាស់ប្តូរដែលពាក់ព័ន្ធនឹងកិច្ចអន្តរាគមន៍ណាមួយ។ |
| អនាម័យកម្រិតមូលដ្ឋាន | សំដៅដល់ការប្រើប្រាស់បង្គន់អនាម័យ ដែលមានលក្ខណៈកែលម្អដោយមិនបានប្រើប្រាស់រួមជាមួយគ្រួសារដទៃ។ |
| អនាម័យកម្រិតសុវត្ថិភាព | សំដៅដល់ការប្រើប្រាស់បង្គន់អនាម័យ ដែលមានលក្ខណៈកែលម្អ ដោយមិនប្រើប្រាស់រួមជាមួយគ្រួសារដទៃ និងទីកន្លែងដែលគ្រប់គ្រងសំណល់លាមកប្រកបដោយសុវត្ថិភាពនៅនឹងកន្លែងឬបញ្ជូនទៅតំបន់ផ្សេងដោយបានធ្វើប្រព្រឹត្តកម្មប្រកបដោយសុវត្ថិភាព។ |
| អភិវឌ្ឍសហគមន៍ចម្រុះ | សំដៅដល់វិធីសាស្ត្ររួមបញ្ចូលគ្នាឬចម្រុះ ក្នុងការសម្របសម្រួលនិងអភិវឌ្ឍសហគមន៍ជនបទមូលដ្ឋានដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជននៅក្នុងសហគមន៍ដូចជាសុខភាព ការអប់រំ កសិកម្ម លំនៅឋាន ហេដ្ឋារចនាសម្ព័ន្ធ ដោយអនុវត្តទាំងព្រម។ |
| អាយុសង្ឃឹមរស់ជាមធ្យម | សំដៅដល់លទ្ធផលបឋមនៃអង្កេតចន្លោះជំរឿនឆ្នាំ២០២៤ : ប្រទេសកម្ពុជាមានប្រជាជនជាង១៧,២លាននាក់ ចំណែកអាយុសង្ឃឹមរស់របស់ពលរដ្ឋទាំងពីរភេទគឺ៧៦,៦ឆ្នាំ ដោយបុរសមានអាយុសង្ឃឹមរស់៧៤,៧ឆ្នាំ និងស្ត្រី៧៨,៤ឆ្នាំ។ |

# បរិសិដ្ឋ២ : ផែនទីបង្ហាញទីតាំងតំបន់ភូមិសាស្ត្រទាំង៤ នៃប្រទេសកម្ពុជា



## បរិសិដ្ឋ៣ : តារាងម៉ាទ្រិកយុទ្ធសាស្ត្រ និងវិធានការគន្លឹះសម្រាប់ការអនុវត្តគោលនយោបាយ

| គោលបំណង : ធ្វើឱ្យប្រជាជននៅតំបន់ជនបទមានជីវភាពរស់នៅសមរម្យប្រកបដោយភាពធន់ មានសុខភាពមាំមួន រស់នៅក្នុងបរិស្ថានល្អប្រកបដោយចីរភាព និងមានសេចក្តីថ្លៃថ្នូរ | | | |
|---|---|---|---|
| **យុទ្ធសាស្ត្រ** | **វិធានការអនុវត្ត** | **ក្រសួង ស្ថាប័នទទួលបន្ទុក** | **ក្របខ័ណ្ឌពេលវេលា** |
| **គោលដៅទី១ :** តំបន់ជនបទមានហេដ្ឋារចនាសម្ព័ន្ធប្រទាក់ក្រឡាគ្នា | | | |
| **យុទ្ធសាស្ត្រទី១ : អភិវឌ្ឍនិងថែទាំហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ជនបទប្រកបដោយភាពធន់** | ១- ធ្វើបច្ចុប្បន្នកម្មផែនការមេសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ និងចងក្រងបញ្ជីខ្សែផ្លូវជនបទដោយផ្អែកទៅលើប្រភេទផ្លូវជនបទ កត្តាភូមិសាស្ត្រ និងកត្តាសក្តានុពលសេដ្ឋកិច្ចនិងសង្គម។ | - ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ក្រសួងផែនការ<br>- ក្រសួងសាធារណការនិងដឹកជញ្ជូន<br>- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>- ក្រសួងធនធានទឹកនិងឧតុនិយម<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ<br>- ដៃគូអភិវឌ្ឍ | រយៈពេលខ្លី (ឆ្នាំ ២០២៥-២០២៧) |
| | ២- រៀបចំលិខិតបទដ្ឋានគតិយុត្តនិងបទដ្ឋានបច្ចេកទេសសម្រាប់គ្រប់គ្រង អភិវឌ្ឍ និងថែទាំហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ។ | - ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ទីស្តីការគណៈរដ្ឋមន្ត្រី (ក្រុមប្រឹក្សាអ្នកច្បាប់)<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- ក្រសួងសាធារណការនិងដឹកជញ្ជូន<br>- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>- ក្រសួងធនធានទឹកនិងឧតុនិយម<br>- ក្រសួងកិច្ចការនារី | រយៈពេលមធ្យម (ឆ្នាំ២០២៥-២០៣០) |

| គោលបំណង : ធ្វើឱ្យប្រជាជននៅតំបន់ជនបទមានជីវភាពរស់នៅសមរម្យប្រកបដោយភាពធន់ មានសុខភាពមាំមួន រស់នៅក្នុងបរិស្ថានល្អប្រកបដោយចីរភាព និងមានសេចក្តីថ្លៃថ្នូរ | | | |
|---|---|---|---|
| **យុទ្ធសាស្ត្រ** | **វិធានការអនុវត្ត** | **ក្រសួង ស្ថាប័នទទួលបន្ទុក** | **ក្របខ័ណ្ឌពេលវេលា** |
| | | - រដ្ឋបាលថ្នាក់ក្រោមជាតិ<br>- ដៃគូអភិវឌ្ឍ<br>- អង្គការសង្គមស៊ីវិល | |
| | ៣- រៀបចំ និងអនុវត្តផែនការគម្រោងវិនិយោគ ដើម្បីតភ្ជាប់ លើកកម្រិតគុណភាព និងថែទាំ ហេដ្ឋារចនាសម្ព័ន្ធជនបទដែលមានភាពធន់ ឱ្យប្រទាក់ក្រឡានៅក្នុងភូមិសាស្ត្រជនបទ នៃតំបន់នីមួយៗ និងតភ្ជាប់ទៅកាន់តំបន់សក្តានុពលសេដ្ឋកិច្ចនិងសង្គម។ | - ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួងផែនការ<br>- ក្រសួងសាធារណការនិងដឹកជញ្ជូន<br>- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>- ក្រសួងធនធានទឹកនិងឧតុនិយម<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ | រយៈពេលខ្លី/វែង (ឆ្នាំ២០២៥-២០២៧/២០២៥-២០៣៥) |
| | ៤- រៀបចំកម្មវិធីអប់រំ និងអនុវត្តយុទ្ធនាការផ្សព្វផ្សាយសុវត្ថិភាពចរាចរណ៍ ព្រមទាំងចលនាអាជ្ញាធរមូលដ្ឋាន និងប្រជាជនមូលដ្ឋានឱ្យចូលរួមថែរក្សាហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ។ | - ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ក្រសួងមហាផ្ទៃ<br>- ក្រសួងព័ត៌មាន<br>- ក្រសួងសាធារណការនិងដឹកជញ្ជូន<br>- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>- ក្រសួងកិច្ចការនារី<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ<br>- អង្គការសង្គមស៊ីវិល | រយៈពេលខ្លី/វែង (ឆ្នាំ២០២៥-២០២៧/២០២៥-២០៣៥) |

| គោលបំណង : ធ្វើឱ្យប្រជាជននៅតំបន់ជនបទមានជីវភាពរស់នៅសមរម្យប្រកបដោយភាពធន់ មានសុខភាពមាំមួន រស់នៅក្នុងបរិស្ថានល្អប្រកបដោយចីរភាព និងមានសេចក្តីថ្លៃថ្នូរ | | | |
|---|---|---|---|
| **យុទ្ធសាស្ត្រ** | **វិធានការអនុវត្ត** | **ក្រសួង ស្ថាប័នទទួលបន្ទុក** | **ក្របខ័ណ្ឌពេលវេលា** |
| **គោលដៅទី២** : ប្រជាជននៅតំបន់ជនបទមានសុខភាពល្អ និងអាយុសង្ឃឹមរស់វែង | | | |
| **យុទ្ធសាស្ត្រទី២ : ផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យជនបទទាំងកម្រិតមូលដ្ឋាន និងកម្រិតសុវត្ថិភាព ប្រកបដោយភាពធន់និងបរិយាបន្ន** | ១- ធ្វើបច្ចុប្បន្នកម្មផែនការយុទ្ធសាស្ត្រជាតិ និងផែនការសកម្មភាពជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទដោយផ្អែកទៅលើតម្រូវការជាអាទិភាពរបស់ប្រជាជនរស់នៅក្នុងភូមិសាស្ត្រផ្សេងគ្នានៃតំបន់ទាំង៤ ជាពិសេសតំបន់ដែលមានសក្តានុពលសេដ្ឋកិច្ចនិងសង្គម។ | - ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងផែនការ<br>- ក្រសួងធនធានទឹកនិងឧតុនិយម<br>- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ<br>- អង្គការសង្គមស៊ីវិល | រយៈពេលខ្លី(ឆ្នាំ ២០២៥-២០២៧) |
| | ២- រៀបចំនិងអនុវត្តផែនការគម្រោងវិនិយោគដើម្បីជំរុញ និងពង្រីកវិសាលភាពលើវិស័យផ្គត់ផ្គង់ទឹកស្អាតជនបទ និងអនាម័យជនបទកម្រិតមូលដ្ឋាន និងកម្រិតសុវត្ថិភាព ដោយផ្អែកតាមតម្រូវការជាអាទិភាពរបស់ប្រជាជននៅក្នុងតំបន់នីមួយៗ ជាពិសេសតំបន់ដែលមានសក្តានុពលសេដ្ឋកិច្ចនិងសង្គម។ | - ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួងផែនការ<br>- ក្រសួងបរិស្ថាន<br>- ក្រសួងសាធារណការនិងដឹកជញ្ជូន<br>- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ<br>- អង្គការសង្គមស៊ីវិល | រយៈពេលខ្លី/វែង (ឆ្នាំ២០២៥-២០២៧/២០២៥-២០៣៥) |
| | ៣- រៀបចំលិខិតបទដ្ឋានគតិយុត្តនិងបទដ្ឋានបច្ចេកទេសសម្រាប់គ្រប់គ្រង អភិវឌ្ឍ និងថែទាំ | - ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | រយៈពេលខ្លី/វែង (ឆ្នាំ២០២៥- |

| គោលបំណង : ធ្វើឱ្យប្រជាជននៅតំបន់ជនបទមានជីវភាពរស់នៅសមរម្យប្រកបដោយភាពពធន់ មានសុខភាពមាំមួន រស់នៅក្នុងបរិស្ថានល្អប្រកបដោយចីរភាព និងមានសេចក្ដីថ្លៃថ្នូរ | | | |
|---|---|---|---|
| យុទ្ធសាស្ត្រ | វិធានការអនុវត្ត | ក្រសួង ស្ថាប័នទទួលបន្ទុក | ក្របខ័ណ្ឌពេលវេលា |
| | ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទ។ | - ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- ក្រសួងធនធានទឹកនិងឧតុនិយម<br>- ក្រសួងសាធារណការនិងដឹកជញ្ជូន<br>- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>- ក្រសួងកិច្ចការនារី<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ<br>- អង្គការសង្គមស៊ីវិល | ២០២៧/២០២៥-២០៣៥) |
| | ៤- អប់រំនិងផ្សព្វផ្សាយពីការគ្រប់គ្រងការប្រើប្រាស់ទឹកស្អាត និងប្រតិបត្តិអនាម័យល្អនៅក្នុងគ្រួសារ និងនៅក្នុងសហគមន៍ជនបទ។ | - ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- ក្រសួងព័ត៌មាន<br>- ក្រសួងសុខាភិបាល<br>- ក្រសួងធម្មការនិងសាសនា<br>- ក្រសួងកិច្ចការនារី<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ<br>- អង្គការសង្គមស៊ីវិល | រយៈពេលវែង(ឆ្នាំ ២០២៥-២០៣៥) |

| គោលបំណង : ធ្វើឱ្យប្រជាជននៅតំបន់ជនបទមានជីវភាពរស់នៅសមរម្យប្រកបដោយភាពធន់ មានសុខភាពមាំមួន រស់នៅក្នុងបរិស្ថានល្អប្រកបដោយចីរភាព និងមានសេចក្ដីថ្លៃថ្នូរ | | | |
|---|---|---|---|
| **យុទ្ធសាស្ត្រ** | **វិធានការអនុវត្ត** | **ក្រសួង ស្ថាប័នទទួលបន្ទុក** | **ក្របខ័ណ្ឌពេលវេលា** |
| **គោលដៅទី៣** : ប្រជាជនរស់នៅក្នុងភូមិឋានដែលមានភាពសុខក្សេមក្សាន្ត និងមានបរិស្ថានល្អ | | | |
| **យុទ្ធសាស្ត្រទី៣** : អភិវឌ្ឍសហគមន៍ជនបទ ជាពិសេសជំរុញការអភិវឌ្ឍចម្រុះ និងបន្តការអនុវត្តចលនាភូមិមួយផលិតផលមួយ និងចលនាភូមិគំរូ ប្រកបដោយភាពធន់និងបរិយាបន្ន | ១- រៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ជំរុញការអភិវឌ្ឍសហគមន៍ជនបទ ជាពិសេសជំរុញការអភិវឌ្ឍចម្រុះ និងបន្តការអនុវត្តចលនាភូមិមួយផលិតផលមួយ ចលនាភូមិគំរូនៅក្នុងភូមិជនបទទូទៅរួមទាំងភូមិនៅតាមបណ្ដោយព្រំដែន និងសហគមន៍ដីសម្បទានសង្គមកិច្ចគ្រប់ប្រភេទព្រមទាំងសហគមន៍ជនជាតិដើមភាគតិចដោយមានការចូលរួម និងភាពជាម្ចាស់របស់សហគមន៍មូលដ្ឋានប្រកបដោយភាពធន់និងបរិយាបន្ន។ | - ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ទីស្ដីការគណៈរដ្ឋមន្ត្រី(ក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ)<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួងមហាផ្ទៃ<br>- ក្រសួងការពារជាតិ<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងរ៉ែនិងថាមពល<br>- ក្រសួងផែនការ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>- ក្រសួងបរិស្ថាន<br>- ក្រសួងធនធានទឹកនិងឧតុនិយម<br>- ក្រសួងព័ត៌មាន | រយៈពេលខ្លី/វែង (ឆ្នាំ២០២៥-២០២៧/២០២៥-២០៣៥) |

គោលបំណង : ធ្វើឱ្យប្រជាជននៅតំបន់ជនបទមានជីវភាពរស់នៅសមរម្យប្រកបដោយភាពធន់ មានសុខភាពមាំមួន រស់នៅក្នុងបរិស្ថានល្អប្រកបដោយចីរភាព និងមានសេចក្ដីថ្លៃថ្នូរ

| យុទ្ធសាស្ត្រ | វិធានការអនុវត្ត | ក្រសួង ស្ថាប័នទទួលបន្ទុក | ក្របខ័ណ្ឌពេលវេលា |
|---|---|---|---|
| | | - ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ<br>- ក្រសួងទេសចរណ៍<br>- ក្រសួងធម្មការនិងសាសនា<br>- ក្រសួងកិច្ចការនារី<br>- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- អាជ្ញាធរមីន<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ<br>- ដៃគូអភិវឌ្ឍ<br>- អង្គការសង្គមស៊ីវិល | |
| | ២- រៀបចំលិខិតបទដ្ឋានគតិយុត្តនិងបទដ្ឋានបច្ចេកទេសសម្រាប់គ្រប់គ្រងនិងអភិវឌ្ឍភូមិ។ | - ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ទីស្តីការគណៈរដ្ឋមន្ត្រី(ក្រុមប្រឹក្សាអ្នកច្បាប់)<br>- ក្រសួងមហាផ្ទៃ<br>- ក្រសួងការពារជាតិ<br>- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>- ក្រសួងបរិស្ថាន<br>- ក្រសួងធម្មការនិងសាសនា<br>- ក្រសួងកិច្ចការនារី | រយៈពេលវែង(ឆ្នាំ ២០២៥-២០៣៥) |

| គោលបំណង : ធ្វើឱ្យប្រជាជននៅតំបន់ជនបទមានជីវភាពរស់នៅសមរម្យប្រកបដោយភាពធន់ មានសុខភាពមាំមួន រស់នៅក្នុងបរិស្ថានល្អប្រកបដោយចីរភាព និងមានសេចក្ដីថ្លៃថ្នូរ | | | |
|---|---|---|---|
| យុទ្ធសាស្ត្រ | វិធានការអនុវត្ត | ក្រសួង ស្ថាប័នទទួលបន្ទុក | ក្របខ័ណ្ឌ ពេលវេលា |
| | | - ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ<br>- រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ<br>- ដៃគូអភិវឌ្ឍ<br>- អង្គការសង្គមស៊ីវិល | |
| | ៣- ជ្រើសរើសភូមិ ដើម្បីអភិវឌ្ឍតាមចលនាភូមិមួយផលិតផលមួយ និងចលនាគំរូ។ | - ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ទីស្ដីការគណៈរដ្ឋមន្ត្រី( ក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ )<br>- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>- ក្រសួងបរិស្ថាន<br>- ក្រសួងធនធានទឹកនិងឧតុនិយម<br>- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>- ក្រសួងទេសចរណ៍<br>- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ<br>- ក្រសួងកិច្ចការនារី<br>- រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ<br>- ដៃគូអភិវឌ្ឍ<br>- អង្គការសង្គមស៊ីវិល | រយៈពេលវែង( ឆ្នាំ ២០២៥-២០៣៥ ) |

| គោលបំណង : ធ្វើឱ្យប្រជាជននៅតំបន់ជនបទមានជីវភាពរស់នៅសមរម្យប្រកបដោយភាពធន់ មានសុខភាពមាំមួន រស់នៅក្នុងបរិស្ថានល្អប្រកបដោយចីរភាព និងមានសេចក្តីថ្លៃថ្នូរ | | | |
|---|---|---|---|
| **យុទ្ធសាស្ត្រ** | **វិធានការអនុវត្ត** | **ក្រសួង ស្ថាប័នទទួលបន្ទុក** | **ក្របខ័ណ្ឌពេលវេលា** |
| | ៤- ពង្រឹងសមត្ថភាពគ.អ.ភ. ឱ្យក្លាយជាយន្តការដឹកនាំនិងសម្របសម្រួលការងារអភិវឌ្ឍន៍ភូមិប្រកបដោយប្រសិទ្ធភាពនិងចីរភាព។ | - ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ក្រសួងមហាផ្ទៃ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ<br>- ដៃគូអភិវឌ្ឍ<br>- អង្គការសង្គមស៊ីវិល | រយៈពេលវែង(ឆ្នាំ ២០២៥-២០៣៥) |
| | ៥- បណ្តុះផ្នត់គំនិតប្រជាពលរដ្ឋជនបទឱ្យមានភាពជាម្ចាស់លើជោគវាសនារបស់ខ្លួននិងសហគមន៍ស្គាល់និងស្រឡាញ់វប្បធម៌ប្រពៃណីជាតិ ព្រមទាំងមានស្មារតីសាមគ្គីសហគមន៍ តាមរយៈការអប់រំផ្ទាល់ ការបណ្តុះបណ្តាល ការផ្សព្វផ្សាយ និងការបង្កើតកម្មវិធីប្រពៃណីនិងសាសនា ព្រមទាំងកម្មវិធីសង្គមនានាដោយផ្ទាល់និង/ឬតាមបណ្តាញសង្គមឌីជីថល ដើម្បីកសាងពលរដ្ឋមានសមត្ថភាព ផលិតភាព សីលធម៌ គុណធម៌ ចរិយាធម៌ ភាពអំណត់ សុចរិតភាព វិន័យ ការទទួលខុសត្រូវខ្ពស់ និងមនសិការស្នេហាជាតិ គ្រួសារគំរូ សហគមន៍គំរូ គ្មានអំពើហិង្សានិងគ្មានអំពើអបាយមុខផ្សេងៗ និងមានសមត្ថភាពចូលរួមអភិវឌ្ឍ អភិរក្ស | - ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ក្រសួងមហាផ្ទៃ<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ក្រសួងរ៉ែនិងថាមពល<br>- ក្រសួងផែនការ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>- ក្រសួងបរិស្ថាន<br>- ក្រសួងធនធានទឹកនិងឧតុនិយម<br>- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>- ក្រសួងសុខាភិបាល<br>- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ<br>- ក្រសួងទេសចរណ៍<br>- ក្រសួងធម្មការនិងសាសនា<br>- ក្រសួងកិច្ចការនារី | រយៈពេលវែង(ឆ្នាំ ២០២៥-២០៣៥) |

| គោលបំណង : ធ្វើឱ្យប្រជាជននៅតំបន់ជនបទមានជីវភាពរស់នៅសមរម្យប្រកបដោយភាពធន់ មានសុខភាពមាំមួន រស់នៅក្នុងបរិស្ថានល្អប្រកបដោយចីរភាព និងមានសេចក្ដីថ្លៃថ្នូរ | | | |
|---|---|---|---|
| **យុទ្ធសាស្ត្រ** | **វិធានការអនុវត្ត** | **ក្រសួង ស្ថាប័នទទួលបន្ទុក** | **ក្របខ័ណ្ឌពេលវេលា** |
| | វប្បធម៌ប្រពៃណី ការពារធនធាន រួមទាំងការជួយសង្គ្រោះសហគមន៍ ការចេះយកអាសារគ្នាក្នុងគ្រាមានអាសន្ន និងដោះស្រាយបញ្ហានានានៅក្នុងសហគមន៍ប្រកបដោយភាពជាម្ចាស់ ក៏ដូចជាដើម្បីចូលរួមជំរុញការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»។ | - ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ | |
| | ៦- បណ្ដុះបណ្ដាលភាពជាអ្នកដឹកនាំដល់យុវជនតាមភូមិជនបទ ដើម្បីក្លាយទៅជាអ្នកដឹកនាំបន្តវេនក្នុងការអភិវឌ្ឍភូមិប្រកបដោយបរិយាបន្ន។ | - ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ក្រសួងមហាផ្ទៃ<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>- ក្រសួងបរិស្ថាន<br>- ក្រសួងធនធានទឹកនិងឧតុនិយម<br>- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ<br>- ក្រសួងទេសចរណ៍<br>- ក្រសួងធម្មការនិងសាសនា<br>- ក្រសួងកិច្ចការនារី<br>- ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ | រយៈពេលវែង(ឆ្នាំ ២០២៥-២០៣៥) |

| គោលបំណង : ធ្វើឱ្យប្រជាជននៅតំបន់ជនបទមានជីវភាពរស់នៅសមរម្យប្រកបដោយភាពធន់ មានសុខភាពមាំមួន រស់នៅក្នុងបរិស្ថានល្អប្រកបដោយចីរភាព និងមានសេចក្តីថ្លៃថ្នូរ | | | |
|---|---|---|---|
| **យុទ្ធសាស្ត្រ** | **វិធានការអនុវត្ត** | **ក្រសួង ស្ថាប័នទទួលបន្ទុក** | **ក្របខ័ណ្ឌ ពេលវេលា** |
| | | - ក្រសួងមុខងារសាធារណៈ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ<br>- អង្គការសង្គមស៊ីវិល | |
| **គោលដៅទី៤** : ប្រជាជននៅតំបន់ជនបទមានកំណើនប្រាក់ចំណូលប្រកបដោយចីរភាព | | | |
| **យុទ្ធសាស្ត្រទី៤ : បង្កើនប្រាក់ចំណូលគ្រួសារនៅតំបន់ជនបទ ប្រកបដោយចីរភាពតាមរយៈពិពិធកម្មមុខរបរនិងនវានុវត្តន៍ការងារ** | ១- សិក្សានិងចងក្រងមុខរបរនៅតំបន់ជនបទតាមសក្តានុពលនៃតំបន់ភូមិសាស្ត្រផ្សេងៗគ្នា និងបង្កើតមុខរបរថ្មីៗ ព្រមទាំងឱកាសការងារសមរម្យនៅក្នុងតំបន់នីមួយៗបន្ថែមទៀត។ | - ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងកិច្ចការនារី<br>- ក្រសួងបរិស្ថាន<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ<br>- អង្គការសង្គមស៊ីវិល | រយៈពេលវែង (ឆ្នាំ ២០២៥-២០៣៥) |
| | ២- សិក្សាពីតម្រូវការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ជំនាញបំណិនជីវិត ជំនាញវិជ្ជាជីវៈដូនតា និងជំនាញសហគ្រិនភាព និងរៀបចំកម្មវិធីបណ្តុះបណ្តាលប្រជាពលរដ្ឋនៅតំបន់ជនបទ ជាពិសេសយុវជន ដើម្បីរួមចំណែកអភិវឌ្ឍមូលធនមនុស្សនៅតំបន់ជនបទ។ | - ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងធម្មការនិងសាសនា<br>- ក្រសួងកិច្ចការនារី<br>- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ<br>- អង្គការសង្គមស៊ីវិល | រយៈពេលវែង (ឆ្នាំ ២០២៥-២០៣៥) |

| គោលបំណង : ធ្វើឱ្យប្រជាជននៅតំបន់ជនបទមានជីវភាពរស់នៅសមរម្យប្រកបដោយភាពធន់ មានសុខភាពមាំមួន រស់នៅក្នុងបរិស្ថានល្អប្រកបដោយចីរភាព និងមានសេចក្តីថ្លៃថ្នូរ | | | |
|---|---|---|---|
| **យុទ្ធសាស្ត្រ** | **វិធានការអនុវត្ត** | **ក្រសួង ស្ថាប័នទទួលបន្ទុក** | **ក្របខ័ណ្ឌពេលវេលា** |
| | ៣- លើកកម្ពស់ជាតួបនីយកម្ម តាមរយៈការគាំទ្រ និងជំរុញផលិតកម្មកែច្នៃផលិតផលនៅក្នុងសហគមន៍មូលដ្ឋាន និងលើកស្ទួយអត្តសញ្ញាណផលិតផលជាតិ ដើម្បីផ្គត់ផ្គង់តម្រូវការទីផ្សារក្នុងស្រុកគ្រប់គ្រាន់ និងនាំចេញទៅទីផ្សារក្រៅប្រទេស។ | - ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ទីស្តីការគណៈរដ្ឋមន្ត្រី(ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ)<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងកិច្ចការនារី<br>- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ<br>- អង្គការសង្គមស៊ីវិល | រយៈពេលវែង(ឆ្នាំ ២០២៥-២០៣៥) |
| | ៤- ចងក្រងក្រុមសន្សំប្រាក់នៅតាមសហគមន៍ផលិត ដើម្បីផ្តល់មូលនិធិធ្វើជាទុនបង្វិល ដោយមានការគាំទ្រ នីតិវិធី តាមដាន ត្រួតពិនិត្យ និងវាយតម្លៃពីក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីធានាប្រសិទ្ធភាពនិងនិរន្តរភាព។ | - ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ក្រសួងមហាផ្ទៃ<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ក្រសួងកិច្ចការនារី<br>- ធនាគារជាតិនៃកម្ពុជា<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ<br>- អង្គការសង្គមស៊ីវិល | រយៈពេលវែង(ឆ្នាំ ២០២៥-២០៣៥) |
| យុទ្ធសាស្ត្រទី៥ : សម្រាប់គាំទ្រគោលដៅទី១ គោលដៅទី២ គោលដៅទី៣ និងគោលដៅទី៤ នៃគោលនយោបាយ | | | |
| **យុទ្ធសាស្ត្រទី៥:លើកកម្ពស់អភិបាលកិច្ច ឌីជីថល និងកិច្ចសហប្រតិបត្តិការ** | ១- ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធទាំងថ្នាក់ជាតិ និងថ្នាក់ | - ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ទីស្តីការគណៈរដ្ឋមន្ត្រី | រយៈពេលវែង(ឆ្នាំ ២០២៥-២០៣៥) |

| គោលបំណង ៖ ធ្វើឱ្យប្រជាជននៅតំបន់ជនបទមានជីវភាពរស់នៅសមរម្យប្រកបដោយភាពធន់ មានសុខភាពមាំមួន រស់នៅក្នុងបរិស្ថានល្អប្រកបដោយចីរភាព និងមានសេចក្តីថ្លៃថ្នូរ | | | |
|---|---|---|---|
| **យុទ្ធសាស្ត្រ** | **វិធានការអនុវត្ត** | **ក្រសួង ស្ថាប័នទទួលបន្ទុក** | **ក្របខ័ណ្ឌពេលវេលា** |
| | ក្រោមជាតិ ដើម្បីគាំទ្រ និងបំពេញតម្រូវការឱ្យគ្នាទៅវិញទៅមកនៅក្នុងដំណើរការអភិវឌ្ឍន៍ជនបទ។ | - ក្រសួងមហាផ្ទៃ<br>- ក្រសួងការពារជាតិ<br>- ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងរ៉ែនិងថាមពល<br>- ក្រសួងផែនការ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>- ក្រសួងបរិស្ថាន<br>- ក្រសួងធនធានទឹកនិងឧតុនិយម<br>- ក្រសួងព័ត៌មាន<br>- ក្រសួងយុត្តិធម៌<br>- ក្រសួងអធិការកិច្ច | |

| គោលបំណង : ធ្វើឱ្យប្រជាជននៅតំបន់ជនបទមានជីវភាពរស់នៅសមរម្យប្រកបដោយភាពធន់ មានសុខភាពមាំមួន រស់នៅក្នុងបរិស្ថានល្អប្រកបដោយចីរភាព និងមានសេចក្តីថ្លៃថ្នូរ | | | |
|---|---|---|---|
| **យុទ្ធសាស្ត្រ** | **វិធានការអនុវត្ត** | **ក្រសួង ស្ថាប័នទទួលបន្ទុក** | **ក្របខ័ណ្ឌពេលវេលា** |
| | | - ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>- ក្រសួងសុខាភិបាល<br>- ក្រសួងសាធារណការនិងដឹកជញ្ជូន<br>- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ<br>- ក្រសួងទេសចរណ៍<br>- ក្រសួងធម្មការនិងសាសនា<br>- ក្រសួងកិច្ចការនារី<br>- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងមុខងារសាធារណៈ<br>- រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ<br>- ដៃគូអភិវឌ្ឍ<br>- អង្គការសង្គមស៊ីវិល | |
| | ២- ពង្រឹងនិងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសជាមិត្តទាំងទ្វេភាគីនិងពហុភាគីដើម្បីរៀនសូត្រនិងចែករំលែកបទពិសោធល្អនៃការងារអភិវឌ្ឍន៍ជនបទ។ | - ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ទីស្តីការគណៈរដ្ឋមន្ត្រី<br>- ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួងកិច្ចការនារី<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ដៃគូអភិវឌ្ឍ | រយៈពេលវែង(ឆ្នាំ ២០២៥-២០៣៥) |

គោលបំណង : ធ្វើឱ្យប្រជាជននៅតំបន់ជនបទមានជីវភាពរស់នៅសមរម្យប្រកបដោយភាពធន់ មានសុខភាពមាំមួន រស់នៅក្នុងបរិស្ថានល្អប្រកបដោយចីរភាព និងមានសេចក្តីថ្លៃថ្នូរ

| យុទ្ធសាស្ត្រ | វិធានការអនុវត្ត | ក្រសួង ស្ថាប័នទទួលបន្ទុក | ក្របខ័ណ្ឌពេលវេលា |
|---|---|---|---|
| | | - អង្គការសង្គមស៊ីវិល | |
| | ៣- កៀរគរដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល សហគមន៍ជនបទមូលដ្ឋាន វិស័យឯកជន និង សប្បុរសជន ដើម្បីចូលរួមគាំទ្រដល់ដំណើការអភិវឌ្ឍន៍ជនបទ។ | - ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួងផែនការ<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ដៃគូអភិវឌ្ឍ<br>- អង្គការសង្គមស៊ីវិល | រយៈពេលវែង (ឆ្នាំ ២០២៥-២០៣៥) |
| | ៤- ចូលរួមអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការដោយរៀបចំយន្តការសម្របសម្រួលនិងទំនាក់ទំនងដើម្បីអនុវត្តការងារអភិវឌ្ឍន៍ជនបទឱ្យបានគ្រប់ជ្រុងជ្រោយនិងមានប្រសិទ្ធភាពខ្ពស់។ | - ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ក្រសួងមហាផ្ទៃ<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួងផែនការ<br>- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>- ក្រសួងអធិការកិច្ច<br>- ក្រសួងមុខងារសាធារណៈ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ | រយៈពេលវែង(ឆ្នាំ ២០២៥-២០៣៥) |

បរិសិដ្ឋ៤ : ក្របខ័ណ្ឌគោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនបទ ឆ្នាំ២០២៥-២០៣៥

| ចក្ខុវិស័យ | កសាងសង្គមជនបទកម្ពុជាឱ្យមានវិបុលភាព ប្រកបដោយបរិយាបន្ន សមធម៌ និងចីរភាព |
|---|---|
| គោលបំណង | ធ្វើឱ្យប្រជាជននៅតំបន់ជនបទមានជីវភាពរស់នៅសមរម្យប្រកបដោយភាពធន់ មានសុខភាពមាំមួន រស់នៅក្នុងបរិស្ថានល្អប្រកបដោយចីរភាព និងមានសេចក្តីថ្លៃថ្នូរ។ |
| គោលដៅ ចំនួន៤ (តុល្យភាព ភាពធន់ និង បរិយាបន្ន) | ១- តំបន់ជនបទមានហេដ្ឋារចនាសម្ព័ន្ធប្រទាក់ក្រឡាគ្នា។<br>២- ប្រជាជននៅតំបន់ជនបទមានកំណើនប្រាក់ចំណូលប្រកបដោយចីរភាព។<br>៣- ប្រជាជននៅតំបន់ជនបទ មានសុខភាពល្អ និងអាយុសង្ឃឹមរស់រវែង។<br>៤- ប្រជាជនរស់នៅក្នុងសុខភូមិប្រកបដោយបរិស្ថានល្អ។ |
| យុទ្ធសាស្ត្រ ចំនួន៥ (តុល្យភាព យេនឌ័រ ភាពធន់ បរិយាបន្ន) | ១- អភិវឌ្ឍនិងថែទាំហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ជនបទប្រកបដោយភាពធន់។<br>២- ផ្គត់ផ្គង់ទឹកស្អាតនិងលើកកម្ពស់អនាម័យជនបទទាំងកម្រិតមូលដ្ឋាន និងកម្រិតសុវត្ថិភាពប្រកបដោយភាពធន់និងបរិយាបន្ន។<br>៣- អភិវឌ្ឍសហគមន៍ជនបទ ជាពិសេសជំរុញការអភិវឌ្ឍចម្រុះ និងបន្តការអនុវត្តចលនាភូមិមួយផលិតផលមួយ និងចលនាភូមិគំរូ ប្រកបដោយភាពធន់និងបរិយាបន្ន។<br>៤- បង្កើនប្រាក់ចំណូលគ្រួសារនៅតំបន់ជនបទប្រកបដោយចីរភាព តាមរយៈពិពិធកម្មមុខរបរ និងនវានុវត្តន៍ការងារ។<br>៥- លើកកម្ពស់អភិបាលកិច្ច ឌីជីថល និងកិច្ចសហប្រតិបត្តិការ។ |
| កម្មវិធីអាទិភាព ចំនួន៥ | ១- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទឱ្យមានភាពប្រទាក់ក្រឡាប្រកបដោយភាពធន់នឹងការប្រែប្រួលអាកាសធាតុ : ការលើកកម្រិតគុណភាពនិងការថែទាំផ្លូវជនបទឱ្យមាននិរន្តរភាព។<br>២- ការកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់ប្រជាជននៅតំបន់ជនបទ : លើកកម្ពស់សុខភាពនិងបរិស្ថានជនបទឱ្យបានល្អប្រសើរ តាមរយៈការផ្គត់ផ្គង់ទឹកស្អាត និងការលើកម្ពស់អនាម័យជនបទប្រកបដោយភាពធន់និងបរិយាបន្ន។<br>៣- ការអភិវឌ្ឍភូមិនិងសហគមន៍ជនបទចម្រុះ ប្រកបដោយភាពធន់ ឌីជីថល និង បរិយាបន្ន : ការអភិវឌ្ឍភូមិគំរូគន្លឹះ និងការអភិវឌ្ឍសហគមន៍ជនបទចម្រុះ រួមទាំងសហគមន៍ដីសម្បទានសង្គមកិច្ចគ្រប់ប្រភេទ និងសហគមន៍ជនជាតិដើមភាគតិច<br>៤- ការធ្វើពិពិធកម្មសេដ្ឋកិច្ចគ្រួសារនៅតំបន់ជនបទ : បណ្តុះបណ្តាលជំនាញបំណិនជីវិត និងសហគ្រិនភាព ដើម្បីបង្កើតមុខរបរ ទីផ្សារ ឱកាសការងារ និងប្រាក់ចំណូល។<br>៥- ការពង្រឹងអភិបាលកិច្ច និងកិច្ចសហប្រតិបត្តិការ : គ្រប់គ្រងស្ថាប័ន ធនធានមនុស្ស ការអនុវត្តគោលនយោបាយ កែទម្រង់ ត្រួតពិនិត្យ វាយតម្លៃ និងភាពជាដៃគូ។ |

| | |
|---|---|
| **វិធីសាស្ត្រអនុវត្តន៍** | (១) ភូមិសាស្ត្រ(Territorial) (២) ពហុវិស័យ(Multisectoral) (៣) ពហុកម្រិត (Multi-level) (៤) ពហុភ្នាក់ងារ(Multi-agent) (៥) បច្ចេកវិទ្យា(Technology) (៦) ចលនាភូមិគំរូ (៧) ការអភិវឌ្ឍសហគមន៍ជនបទចម្រុះ រួមទាំងសហគមន៍ជនជាតិដើមភាគតិច។ |
| **យន្តការអនុវត្តន៍ «ជីវភាពនៃប្រព័ន្ធតួអង្គតែមួយ»** | ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ(ខេត្ត ស្រុក ឃុំ ភូមិ) និង គ.អ.ភ. ប្រកបដោយកិច្ចសហប្រតិបត្តិការល្អ ជាសហថាមពល។ |
| **ធនធានហិរញ្ញវត្ថុ** | (១) ថវិកាជាតិ (២) ថវិកាហិរញ្ញប្បទានសម្បទានដៃគូ (៣) ថវិការបស់អង្គការមិនមែនរដ្ឋាភិបាល (៤) ថវិការបស់បណ្តាប្រទេសជាមិត្តជាពហុភាគីនិងទ្វេភាគី (៥)ថវិកាបានមកពីប្រភពស្របច្បាប់ផ្សេងៗទៀត។ |
| **ការតាមដាននិងការវាយតម្លៃ** | ១- សូចនាករសមិទ្ធកម្មគន្លឹះក្នុងឆ្នាំតាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រនិងផែនការប្រចាំឆ្នាំនៃក្រសួង ស្ថាប័នពាក់ព័ន្ធ និង<br>២- សូចនាករកម្មវិបាកតាមរយៈការធ្វើអង្កេតក្នុងរយៈពេល៥ឆ្នាំម្តង(ឆ្នាំ២០៣០និងឆ្នាំ២០៣៥)។ |

## បរិសិដ្ឋ៥ : វិធីសាស្ត្រអនុវត្តន៍កម្មវិធីអាទិភាពនៃគោលនយោបាយ

| វិធីសាស្ត្រ | សេចក្តីពន្យល់ |
|---|---|
| **ស្ថានភាពភូមិសាស្ត្រ** (Territorial) | វិធីសាស្ត្រនេះផ្តោតទៅលើចរិតលក្ខណៈ បញ្ហា ការប្រឈម និងតម្រូវការនៃភូមិសាស្ត្រផ្សេងៗពីគ្នាដែលតម្រូវឱ្យមានការសិក្សាឱ្យច្បាស់លាស់អំពីស្ថានភាពសេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថាន ព្រមទាំងតម្រូវការអភិវឌ្ឍនៅក្នុងតំបន់ភូមិសាស្ត្រនីមួយៗ ដើម្បីរៀបចំផែនការអភិវឌ្ឍឱ្យចំគោលដៅ និងតម្រូវការអាទិភាពជាក់ស្តែង។ |
| **ពហុវិស័យ** (Multisectoral) | វិធីសាស្ត្រនេះផ្តោតទៅលើសារៈសំខាន់នៃលក្ខណៈចម្រុះនិងអន្តរវិស័យនៃតម្រូវការអភិវឌ្ឍជនបទដែលតម្រូវឱ្យធ្វើការសិក្សា និងវិភាគពីទំនាក់ទំនង និងសក្តានុពលនៃវិស័យពាក់ព័ន្ធនានា ដើម្បីរៀបចំការអភិវឌ្ឍជនបទប្រកបដោយសមាហរណកម្ម គ្រប់ជ្រុងជ្រោយ ប្រសិទ្ធភាព និងនិរន្តរភាព។ |
| **ពហុកម្រិត** (Multi-level) | វិធីសាស្ត្រនេះផ្តោតទៅលើភាពចាំបាច់នៃយន្តការសម្របសម្រួល ដឹកនាំ គ្រប់គ្រង និងអនុវត្តការងារអភិវឌ្ឍន៍ជនបទ ដែលតម្រូវឱ្យមានការស្វែងយល់ពីរចនាសម្ព័ន្ធ តួនាទីនិងភារកិច្ច ព្រមទាំងភាពជាប់ពាក់ព័ន្ធនៃស្ថាប័នថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងនៅថ្នាក់សហគមន៍នៅគ្រប់កម្រិត ដើម្បីរៀបចំឱ្យមានការរួមអនុវត្តនិងទទួលខុសត្រូវលើកិច្ចការអភិវឌ្ឍន៍ជនបទ។ |
| **ពហុភាគី** (Multi-Stakeholders) | វិធីសាស្ត្រនេះផ្តោតទៅលើសក្តានុពល និងឥទ្ធិពល នៃតួអង្គពាក់ព័ន្ធ ដូចជាស្ថាប័នរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងសហគមន៍មូលដ្ឋាន ព្រមទាំងសប្បុរសជន ដែលតម្រូវឱ្យធ្វើការកំណត់អត្តសញ្ញាណ តួនាទី និងធនធាន ដើម្បីកៀរគរនិងលើកទឹកចិត្តឱ្យចូលរួមក្នុងដំណើរការអភិវឌ្ឍន៍ជនបទ។ |
| **ទំនាក់ទំនងរវាងទីប្រជុំជន និងទីជនបទ**(Urban-Rural linkages) | វិធីសាស្ត្រនេះផ្តោតទៅលើសក្តានុពលនិងឥទ្ធិពលនៃទីប្រជុំជននិងទីជនបទដែលអាចពឹងផ្អែកគ្នាទៅវិញទៅមកនៅក្នុងទំនាក់ទំនងសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ |
| **បច្ចេកវិទ្យា** (Technology) | វិធីសាស្ត្រនេះផ្តោតទៅលើសារៈសំខាន់នៃបច្ចេកវិទ្យានៅក្នុងការជំរុញសកម្មភាពសេដ្ឋកិច្ច ទំនាក់ទំនងការងារ និងការផ្តល់សេវាសាធារណៈ ជាពិសេសនៅក្នុងសម័យកាលបច្ចេកវិទ្យា៤.០ បច្ចេកវិទ្យាឌីជីថល គឺជាមធ្យោបាយសំខាន់សម្រាប់ការអភិវឌ្ឍជនបទឱ្យទទួលបានលទ្ធផលឆាប់រហ័សនិងមានប្រសិទ្ធភាព ដែលចាំបាច់ត្រូវសិក្សាពីចន្លោះខ្វះខាតឬតម្រូវការបច្ចេកវិទ្យានៅក្នុងតំបន់ជនបទ ដើម្បីបំពេញបន្ថែមនិងជំរុញឱ្យមានការប្រើប្រាស់ជាប្រយោជន៍សេដ្ឋកិច្ច និងសង្គមជនបទ។ |

| | |
|---|---|
| ការអភិវឌ្ឍភូមិគំរូ និងសហគមន៍ជនបទចម្រុះ | វិធីសាស្ត្រនេះផ្តោតទៅលើការជំរុញនិងគាំទ្រដល់ការអភិវឌ្ឍសហគមន៍មូលដ្ឋានចម្រុះ និងភូមិគំរូរួមទាំងជនជាតិដើមភាគតិច ដើម្បីលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ សុខភាពអនាម័យ បំណិនជីវិត វប្បធម៌ ប្រពៃណី សីលធម៌ សុជីវធម៌ នៅក្នុងតំបន់ជនបទ ដែលតម្រូវឱ្យមានការសិក្សាពីបញ្ហានិងតម្រូវការអភិវឌ្ឍន៍របស់សហគមន៍ឬភូមិ ដើម្បីការរៀបចំផែនការ និងចាត់ចែងអនុវត្តសកម្មភាពអភិវឌ្ឍន៍សហគមន៍ឬភូមិ ដោយមានការចូលរួម និងភាពជាម្ចាស់របស់សហគមន៍។ |

## ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ១ : ទស្សនាទាននិងគោលការណ៍អភិវឌ្ឍន៍ជនបទ

| | |
|---|---|
| ទស្សនាទាន អភិវឌ្ឍន៍ជនបទ | កិច្ចការអភិវឌ្ឍន៍ជនបទ មានភាពធំទូលាយគ្មានដែនកំណត់ ចម្រុះ និងអន្តរវិស័យ ដូច្នេះដើម្បីមានភាពងាយយល់អំពីក្របខ័ណ្ឌនៃការងារអភិវឌ្ឍន៍ជនបទ និងឈានទៅការរៀបចំគោលនយោបាយអភិវឌ្ឍន៍ជនបទមួយ ដែលអាចអនុវត្តបាន ក្នុងក្របខ័ណ្ឌពេលវេលាមួយជាក់លាក់ ចាំបាច់ត្រូវស្វែងយល់ពីទស្សនាទានអភិវឌ្ឍន៍ជនបទ(Rural Development Concept)។ កិច្ចការអភិវឌ្ឍជនបទជាការងារពាក់ព័ន្ធទៅនឹងការជួយអ្នកក្រីក្រខ្លាំង ឱ្យទទួលបានផលប្រយោជន៍សមស្របនិងអាទិភាពរបស់ក្រុមគ្រួសាររបស់ពួកគេ ដើម្បីលើកកម្ពស់កម្រិតជីវភាពឱ្យបានសមរម្យ។ ប្រជាពលរដ្ឋក្រីក្រជាទូទៅអាចជាកសិករតូចតាច ឬអ្នកគ្មានដីធ្លីសម្រាប់ការរស់នៅ និងបង្កបង្កើនផល មិនចេះអក្សរ ឬទទួលបានតិចតួច ខ្វះចំណេះជំនាញជាដើម។<br>យោងតាមអង្គការសហប្រជាជាតិ(UN) បានកំណត់ថា កិច្ចការអភិវឌ្ឍន៍ជនបទគឺជាដំណើរការនៃការផ្លាស់ប្តូរ ដែលការផ្លាស់ប្តូរនោះបានកើតចេញពីការខិតខំរួមគ្នារបស់សហគមន៍ ឬក្រុមមនុស្សនៅតាមជនបទផ្ទាល់ ជាមួយនឹងការគាំទ្រពីស្ថាប័នរដ្ឋាភិបាល ដើម្បីធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌសេដ្ឋកិច្ច សង្គម និងវប្បធម៌ របស់សហគមន៍ជនបទ ហើយភាពប្រសើរឡើងនោះ នឹងរួមចំណែកដល់កម្មវិធីអភិវឌ្ឍន៍ប្រទេសជាតិទាំងមូល។<br>ទស្សនាទានអភិវឌ្ឍន៍ជនបទបានបង្ហាញឱ្យឃើញពីទិដ្ឋភាព និងយល់ពីស្ថានភាពនៃកិច្ចការអភិវឌ្ឍន៍ទូទៅនៅក្នុងតំបន់ជនបទ ជាមួយនឹងក្តីរំពឹងថា បង្កើតបានសហគមន៍ជនបទប្រកបដោយភាពរស់រវើក ធន់ និងបរិយាបន្ន ដែលប្រជាជនអាចរស់នៅ និងធ្វើការប្រកបដោយសេចក្តីថ្លៃថ្នូរនិងភាពរុងរឿង។ ក្នុងន័យនេះ ទស្សនាទានអភិវឌ្ឍន៍ជនបទ បានឆ្លុះបញ្ចាំងលើកិច្ចការងារ កែលម្អគុណភាពជីវិត និងសុខុមាលភាពរបស់ប្រជាជនរស់នៅតាមតំបន់ជនបទ ដើម្បីការកាត់បន្ថយភាពក្រីក្រ ដែលគ្របដណ្តប់លើទិដ្ឋភាពជាច្រើនរួមមាន៖<br>- ការអភិវឌ្ឍសេដ្ឋកិច្ចជនបទ : បង្កើនឱកាសការងារនិងប្រាក់ចំណូលតាមរយៈការលើកកម្ពស់ការអនុវត្តកសិកម្ម សហគ្រាសធុនតូច និងមធ្យម និងទេសចរណ៍ប្រកបដោយនិរន្តរភាព<br>- ការអភិវឌ្ឍសេវាសង្គមជនបទ : បង្កើនការទទួលបានសេវាសុខភាព អប់រំ និងទឹកស្អាត<br>- ការអភិវឌ្ឍនិងការកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទ : ផ្លូវថ្នល់ ស្ពាន ប្រព័ន្ធធារាសាស្ត្រ អគ្គិសនី និងបច្ចេកវិទ្យាគមនាគមន៍ និងទីផ្សារ ដើម្បីលើកកម្ពស់ផលិតកម្ម សម្រួលដល់ចលនាទំនិញ និងសេវាកម្មនានា<br>- ការលើកកម្ពស់សមភាពយេនឌ័រ និងការចូលរួមរបស់សហគមន៍ ប្រកបដោយបរិយាបន្នក្នុងការធ្វើសេចក្តីសម្រេចចិត្ត<br>- ការការពារនិងថែរក្សាបរិស្ថាន : ការគ្រប់គ្រងធនធានធម្មជាតិ ប្រកបដោយនិរន្តរភាពនិងកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ |

| | |
|---|---|
| | ជាមួយគ្នានេះ ទស្សនាទានអភិវឌ្ឍន៍ជនបទ បានចង្អុលបង្ហាញឱ្យឃើញថា កិច្ចការអភិវឌ្ឍជនបទទាមទារឱ្យមានគិតគូរជា៖<br>- ពហុវិស័យ (Multidimensions) និងគ្រប់ជ្រុងជ្រោយ (Comprehensive) ទៅលើការងារអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមសេដ្ឋកិច្ច ហេដ្ឋារចនាសម្ព័ន្ធ សេវាកម្មនៅក្នុងភូមិ ឬសហគមន៍ជនបទ ដែលផ្តល់ជាផលប្រយោជន៍ដល់ប្រជាពលរដ្ឋនៅក្នុងតំបន់ជនបទ<br>- បាតុភូត (Phenomenon-ជាតុផ្សំនៃសមាសភាគជាច្រើន) បង្កើតបានជាលទ្ធផល តាមរយៈអន្តរកម្មរវាងកត្តាជាច្រើនដូចជា ស្ថាប័ន សង្គម វប្បធម៌ សេដ្ឋកិច្ច បច្ចេកវិទ្យាជាដើម<br>- យុទ្ធសាស្ត្រ ដើម្បីផ្តោតទៅលើការគិតគូពីសុខុមាលភាពសង្គម និងសេដ្ឋកិច្ច សម្រាប់ក្រុមមនុស្សណាមួយជាក់លាក់ ជាពិសេសអ្នកក្រីក្រ និងក្រុមអ្នកងាយរងគ្រោះ<br>- វិធីសាស្ត្រ/ជំនាញចម្រុះ (Multidisciplinary) កិច្ចការអភិវឌ្ឍជនបទ បង្ហាញពីអន្តរវិស័យ ឬចំណុចប្រសព្វនៃវិទ្យាសាស្ត្រ/ទេពកោសល្យជនបទ ដែលរួមមាន កសិកម្ម សង្គម វប្បធម៌ វិស្វកម្ម បរិស្ថាន ការដឹកនាំ និងការគ្រប់គ្រង។<br>ជារួម ទស្សនាទានអភិវឌ្ឍន៍ជនបទ បង្ហាញឲ្យយល់ពីដំណើរការ និងតួអង្គពាក់ព័ន្ធ សម្រាប់ការផ្លាស់ប្តូរជាវិជ្ជមាននៅតំបន់ជនបទ តាមរយៈសកម្មភាពអភិវឌ្ឍន៍ ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ និងភាពជាម្ចាស់នៅក្នុងតំបន់ជនបទ ដែលត្រូវផ្អែកលើ ធនធានមនុស្ស ធនធានធម្មជាតិ បច្ចេកវិទ្យា សេវាហេដ្ឋារចនាសម្ព័ន្ធ ការដឹកនាំ ការគ្រប់គ្រង ការរៀបចំគោលនយោបាយ និងកម្មវិធីផ្សេងៗរបស់សហគមន៍ និងរដ្ឋាភិបាល ក្នុងគោលដៅជំរុញ និងពន្លឿនកំណើនសេដ្ឋកិច្ចនៅក្នុងតំបន់ជនបទ និងលើកកម្ពស់គុណភាពរស់នៅរបស់អ្នកជនបទ ដើម្បីកសាងតំបន់ជនបទ ប្រកបដោយជីវភាពសមរម្យ ថ្លៃថ្នូរ ភាពសុខសាន្ត និងសុភមង្គល។ |
| គោលការណ៍អភិវឌ្ឍន៍ជនបទ | ដោយកិច្ចការអភិវឌ្ឍន៍ជនបទ មានភាពធំទូលាយ ចម្រុះ និងអន្តរវិស័យ ការរៀបចំគោលនយោបាយអភិវឌ្ឍន៍ជនបទនេះ នឹងអនុលោមតាមគោលការណ៍សំខាន់ៗចំនួន៦ ដែលបានបង្ហាញឱ្យឃើញនូវលក្ខខណ្ឌចាំបាច់ក្នុងការគិតគូរ និងផ្តោតការយកចិត្តទុកដាក់ក្នុងការកំណត់ចក្ខុវិស័យ គោលបំណង គោលដៅ យុទ្ធសាស្ត្រ និងកម្មវិធីអភិវឌ្ឍន៍ជនបទ នៃគោលនយោបាយ ដែលអាចអនុវត្តបាន និងឆ្លើយតបចំគោលដៅប្រកបដោយប្រសិទ្ធភាព សក្តិសិទ្ធិភាព បរិយាបន្ន និងចីរភាព៖<br>**១- គ្រួសារជនបទជាគោល/ស្នូលនៃកិច្ចការអភិវឌ្ឍ (Rural Family-Centred) :**<br>ការកំណត់ «គ្រួសារជនបទ» ជាគោល ឬជាប្រធានបទ នៃកិច្ចការអភិវឌ្ឍន៍ជនបទ ដើម្បីគិតគូរនិងផ្តោតទៅលើក្រុមគ្រួសាររស់នៅក្នុងភូមិនិងឃុំជនបទ ដោយធ្វើយ៉ាងណាឱ្យទទួលបានឱកាស និងមានលទ្ធភាពលើកកម្ពស់សមត្ថភាព និងមានភាពជឿជាក់ក្នុងដំណើរការ នៃកិច្ចការអភិវឌ្ឍន៍ឱ្យមានភាពរីកចម្រើន ដោយផ្អែកទៅតាមសេចក្តីត្រូវការ និងការរំពឹងទុករបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានជនបទ។ |

| | |
|---|---|
| | ២- **ចីរភាព**(Sustainable) : លើកកម្ពស់និងអភិវឌ្ឍជនបទ ទាំងផ្នែកសេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថាន ប្រកបដោយនិរន្តរភាពស្របទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព/គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជា ( Sustainable Development Goals-SDGs/Cambodia Sustainable Development Goals-CSDGs )និងចក្ខុវិស័យ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា។<br>៣- **ការចូលរួមនិងបរិយាបន្ន**(Participative and Inclusive) : លើកទឹកចិត្ត និងជំរុញការចូលរួមឱ្យសកម្មនិងគាំទ្រ/លើកកម្ពស់សាមគ្គីភាពនៅក្នុងសហគមន៍ជនបទ ព្រមទាំងកំណត់អាទិភាពតម្រូវការ នៃសមាជិកសហគមន៍ជនបទ ជាពិសេសសហគមន៍នៅដាច់ស្រយាល ដើម្បីអន្តរាគមន៍ និងឆ្លើយតបឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព។<br>៤- **សមាហរណកម្ម**(Integrated) : ធានាសង្គតិភាពជាមួយគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក ឆ្ពោះទៅសម្រេចគោលបំណងរួម និងលទ្ធផលរួម សម្រាប់ប្រជាពលរដ្ឋនៅតាមតំបន់ជនបទ ក៏ដូចជាប្រទេសជាតិទាំងមូល។<br>៥- **វឌ្ឍនភាព**(Progressive) : ពង្រឹងនិងពង្រីករាល់វឌ្ឍនភាពសំខាន់ៗ ដាវិជ្ជមាន ក៏ដូចជាបន្តភាពបត់បែនទៅតាមស្ថានភាព និងតម្រូវការអាទិភាពជាក់ស្តែង ដើម្បីជាមូលដ្ឋានក្នុងការបង្កើតឱកាសថ្មីៗសម្រាប់ពន្លឿនការអភិវឌ្ឍជនបទ។<br>៦- **អន្តរកម្មរវាងជនបទ ទីប្រជុំជន និងទីក្រុង**(Rural-Urban Interdependence) : ទទួលស្គាល់និងកំណត់លើអន្តរកម្មមុខងារ តួនាទី និងអន្តរអំពើ ឬអន្តរទំនាក់ទំនង រវាងទីប្រជុំជន និងតំបន់ជនបទក្នុងគោលដៅបំពេញតម្រូវការនិងគាំទ្រគ្នាទៅវិញមកនៅក្នុងសកម្មភាពអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម និងវប្បធម៌។ |

# ឧបសម្ព័ន្ធ២ : តារាងទិន្នន័យគ្រួសារក្រ១ ក្រ២ និងគ្រួសារងាយរងគ្រោះតាមខេត្ត

| លេខកូដ | ខេត្ត | គ្រួសារសរុប | ចំនួនប្រជាជនសរុប | គ្រួសារក្រីក្រ | | | | | | គ្រួសារងាយរងហានិភ័យ | | ចំនួនសមាជិកគ្រួសារក្រីក្រ | | | | | | អ្នកងាយរងហានិភ័យ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ចំនួនក្រ១ ក្រ២ | | | ក្រ១ ក្រ២ (%) | | | | | ចំនួនសមាជិកគ្រួសារ | | | សមាជិកគ្រួសារ (%) | | | | |
| | | | | ក្រ១ | ក្រ២ | សរុប | ក្រ១ | ក្រ២ | សរុប | ចំនួន | % | ក្រ១ | ក្រ២ | សរុប | ក្រ១ | ក្រ២ | សរុប | ចំនួន | % |
| ១- តំបន់ទំនាបកណ្តាល | | | | | | | | | | | | | | | | | | | |
| 03 | កំពង់ចាម | 286,627 | 1,138,083 | 14,810 | 29,542 | 44,352 | 5.17 | 10.31 | 15.47 | 32,775 | 11.43 | 55,873 | 114,164 | 170,037 | 4.91 | 10.03% | 14.94 | 100,862 | 8.86 |
| 25 | ត្បូងឃ្មុំ | 230,242 | 550,640 | 11,415 | 25,067 | 36,482 | 4.96 | 10.89 | 15.85 | 31,060 | 13.49 | 45,086 | 101,316 | 146,402 | 8.19 | 18.40% | 26.59 | 105,548 | 19.17 |
| 08 | កណ្តាល | 302,857 | 640,550 | 10,977 | 28,185 | 39,162 | 3.62 | 9.31 | 12.93 | 35,927 | 11.86 | 41,252 | 117,457 | 158,709 | 6.44 | 18.34% | 24.78 | 125,188 | 19.54 |
| 20 | ស្វាយរៀង | 157,877 | 664,849 | 7,046 | 25,513 | 32,559 | 4.46 | 16.16 | 20.62 | 17,450 | 11.05 | 20,946 | 71,587 | 92,533 | 3.15 | 10.77% | 13.92 | 51,282 | 7.71 |
| 21 | តាកែវ | 230,021 | 1,043,690 | 9,007 | 29,743 | 38,750 | 3.92 | 12.93 | 16.85 | 39,046 | 16.97 | 35,658 | 114,612 | 150,270 | 3.42 | 10.98% | 14.40 | 131,051 | 12.56 |
| 14 | ព្រៃវែង | 297,016 | 1,253,070 | 12,447 | 38,371 | 50,818 | 4.19 | 12.92 | 17.11 | 28,577 | 9.62 | 45,355 | 127,750 | 173,105 | 3.62 | 10.19% | 13.81 | 81,052 | 6.47 |
| សរុប | | 1,504,640 | 5,290,882 | 65,702 | 176,421 | 242,123 | 4.37 | 11.73 | 16.09 | 184,835 | 12.28 | 244,170 | 646,886 | 891,056 | 4.61 | 12.23% | 16.84 | 594,983 | 11.25 |
| ២- តំបន់ជុំវិញបឹងទន្លេសាប | | | | | | | | | | | | | | | | | | | |
| 01 | បន្ទាយមានជ័យ | 232,950 | 878,691 | 13,051 | 30,508 | 43,559 | 5.60 | 13.10 | 18.70 | 46,248 | 19.85 | 59,562 | 141,018 | 200,580 | 6.78 | 16.05% | 22.83 | 171,451 | 19.51 |
| 02 | បាត់ដំបង | 294,768 | 1,347,035 | 23,413 | 67,083 | 90,496 | 7.94 | 22.76 | 30.70 | 45,794 | 15.54 | 112,441 | 322,670 | 435,111 | 8.35 | 23.95% | 32.30 | 179,252 | 13.31 |
| 04 | កំពង់ឆ្នាំង | 138,997 | 573,789 | 3,601 | 14,090 | 17,691 | 2.59 | 10.14 | 12.73 | 26,550 | 19.10 | 14,494 | 54,853 | 69,347 | 2.53 | 9.56% | 12.09 | 84,485 | 14.72 |
| 06 | កំពង់ធំ | 180,837 | 839,991 | 16,135 | 32,327 | 48,462 | 8.92 | 17.88 | 26.80 | 24,274 | 13.42 | 64,781 | 126,324 | 191,105 | 7.71 | 15.04% | 22.75 | 76,494 | 9.11 |
| 15 | ពោធិ៍សាត់ | 132,800 | 325,504 | 9,067 | 17,459 | 26,526 | 6.83 | 13.15 | 19.97 | 13,644 | 10.27 | 35,404 | 67,378 | 102,782 | 10.88 | 20.70% | 31.58 | 45,072 | 13.85 |
| 17 | សៀមរាប | 254,691 | 1,177,265 | 23,262 | 44,613 | 67,875 | 9.13 | 17.52 | 26.65 | 37,885 | 14.87 | 90,691 | 177,829 | 268,520 | 7.70 | 15.11% | 22.81 | 153,232 | 13.02 |
| សរុប | | 1,235,043 | 5,142,275 | 88,529 | 206,080 | 294,609 | 7.17 | 16.69 | 23.85 | 194,395 | 15.74 | 377,373 | 890,072 | 1,267,445 | 7.34 | 24.65% | 24.65 | 709,986 | 13.81 |
| ៣- តំបន់ឆ្នេរសមុទ្រ | | | | | | | | | | | | | | | | | | | |
| 07 | កំពត | 161,520 | 708,398 | 6,117 | 21,412 | 27,529 | 3.79 | 13.26 | 17.04 | 12,545 | 7.77 | 24,808 | 74,779 | 99,587 | 3.50 | 10.56% | 14.06 | 36,114 | 5.10 |
| 23 | កែប | 9,898 | 43,180 | 216 | 1,151 | 1,367 | 2.18 | 11.63 | 13.81 | 823 | 8.31 | 914 | 4,144 | 5,058 | 2.12 | 9.60% | 11.71 | 2,756 | 6.38 |
| 09 | កោះកុង | 31,161 | 85,817 | 1,872 | 5,907 | 7,779 | 6.01 | 18.96 | 24.96 | 2,737 | 8.78 | 7,363 | 21,976 | 29,339 | 8.58 | 25.61% | 34.19 | 9,909 | 11.55 |
| 18 | ព្រះសីហនុ | 50,522 | 229,332 | 1,736 | 6,316 | 8,052 | 3.44 | 12.50 | 15.94 | 5,976 | 11.83 | 8,349 | 26,012 | 34,361 | 3.64 | 11.34% | 14.98 | 23,870 | 10.41 |
| សរុប | | 253,101 | 1,066,727 | 9,941 | 34,786 | 44,727 | 3.93 | 13.74 | 17.67 | 22,081 | 8.72 | 41,434 | 126,911 | 168,345 | 3.88 | 15.78% | 15.78 | 72,649 | 6.81 |

| ៤- តំបន់ភ្នំនិងខ្ពង់រាប | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 05 | កំពង់ស្ពឺ | 196,113 | 878,022 | 7,353 | 23,183 | 30,536 | 3.75 | 11.82 | 15.57 | 19,232 | 9.81 | 25,145 | 72,059 | 97,204 | 2.86 | 8.21% | 11.07 | 58,026 | 6.61 |
| 10 | ក្រចេះ | 105,614 | 453,147 | 8,265 | 18,040 | 26,305 | 7.83 | 17.08 | 24.91 | 15,427 | 14.61 | 36,530 | 76,787 | 113,317 | 8.06 | 16.95% | 25.01 | 51,630 | 11.39 |
| 11 | មណ្ឌលគិរី | 23,780 | 96,818 | 1,232 | 3,827 | 5,059 | 5.18 | 16.09 | 21.27 | 2,123 | 8.93 | 5,891 | 14,491 | 20,382 | 6.08 | 14.97% | 21.05 | 7,191 | 7.43 |
| 13 | ព្រះវិហារ | 65,029 | 267,055 | 4,129 | 10,927 | 15,056 | 6.35 | 16.80 | 23.15 | 9,492 | 14.60 | 16,523 | 42,597 | 59,120 | 6.19 | 15.95% | 22.14 | 32,890 | 12.32 |
| 16 | រតនគិរី | 62,913 | 192,448 | 4,891 | 10,982 | 15,873 | 7.77 | 17.46 | 25.23 | 7,224 | 11.48 | 21,961 | 44,486 | 66,447 | 11.41 | 23.12% | 34.53 | 25,572 | 13.29 |
| 19 | ស្ទឹងត្រែង | 42,416 | 175,319 | 2,189 | 5,566 | 7,755 | 5.16 | 13.12 | 18.28 | 5,408 | 12.75 | 9,750 | 22,477 | 32,227 | 5.56 | 12.82% | 18.38 | 18,688 | 10.66 |
| 22 | ឧត្តរមានជ័យ | 68,042 | 269,742 | 2,699 | 8,461 | 11,160 | 3.97 | 12.43 | 16.40 | 5,910 | 8.69 | 12,267 | 33,018 | 45,285 | 4.55 | 12.24% | 16.79 | 20,611 | 7.64 |
| 24 | ប៉ៃលិន | 19,631 | 81,401 | 1,931 | 4,698 | 6,629 | 9.84 | 23.93 | 33.77 | 2,788 | 14.20 | 7,671 | 19,406 | 27,077 | 9.42 | 23.84% | 33.26 | 10,360 | 12.73 |
| សរុប | | 583,538 | 2,413,952 | 32,689 | 85,684 | 118,373 | 5.60 | 14.68 | 20.29 | 67,604 | 11.59 | 135,738 | 325,321 | 461,059 | 5.62 | 19.10% | 19.10 | 224,968 | 9.32 |
| សរុបរួម | | 3,576,322 | 13,913,836 | 196,861 | 502,971 | 699,832 | 5.50 | 14.06 | 19.57 | 468,915 | 13.11 | 798,715 | 1,989,190 | 2,787,905 | 5.74 | 14.30% | 20.04 | 1,602,586 | 11.52 |

*(ប្រភព : ទិន្នន័យគ្រួសារ ដែលបានដាក់បង្ហាញនៅលើគេហទំព័រ នៃកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រប្រទេសកម្ពុជា ដកស្រង់នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២៥)*

## តារាងសង្ខេបទិន្នន័យគ្រួសារក្រ១ គ្រួសារក្រ២ និងគ្រួសារងាយរងហានិភ័យក្នុងតំបន់ទាំង៤

| តំបន់ | ចំនួនភូមិ | | គ្រួសារសរុប | គ្រួសារក្រ១ | | គ្រួសារក្រ២ | | គ្រួសារងាយរងហានិភ័យ | |
|---|---|---|---|---|---|---|---|---|---|
| | សរុប | ជនបទ | | ចំនួន | % | ចំនួន | % | ចំនួន | % |
| តំបន់ទំនាបកណ្តាល | 5,762 | 4,403 | 1,504,640 | 65,702 | 4.37 | 176,421 | 11.73 | 184,835 | 12.28 |
| តំបន់ជុំវិញបឹងទន្លេសាប | 4,298 | 3,615 | 1,235,043 | 88,529 | 7.17 | 206,080 | 16.69 | 194,395 | 15.74 |
| តំបន់ឆ្នេរសមុទ្រ | 736 | 594 | 253,101 | 9,941 | 3.93 | 34,786 | 13.74 | 22,081 | 8.72 |
| តំបន់ខ្ពង់រាបនិងភ្នំ | 2,805 | 1,703 | 583,538 | 32,689 | 5.60 | 85,684 | 14.68 | 67,604 | 11.59 |
| **សរុប** | **13,601** | **10,315** | **3,576,322** | **196,861** | **5.50** | **502,971** | **14.06** | **468,915** | **13.11** |

# ឧបសម្ព័ន្ធ៣ : ហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទក្រាលកៅស៊ូមួយជាន់ ពីរជាន់ បេតុង និងផ្លូវល្បាយគ្រួស

| ល.រ. | តំបន់ | ប្រភេទមានកម្រាល | | | | | | ប្រភេទគ្មានកម្រាល | | | | សរុប | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | កៅស៊ូ១ជាន់ | | កៅស៊ូ២ជាន់ | | បេតុង | | ល្បាយក្រួស អាចម៍ផ្កាយ និងល្បាយកម្ទេចថ្ម | | ដីស ខ្សាច់ភ្នំ និងផ្សេងៗ | | | | |
| | | គម | % | គម | % | គម | % | គម | % | គម | % | គម | ខ្សែ | % |
| **ទំនាបកណ្ដាល (៦ខេត្ត)** | | | | | | | | | | | | | | |
| ១ | ខេត្តកំពង់ចាម | 10.70 | 0.58 | 536.50 | 28.98 | 242.56 | 13.10 | 922.19 | 49.82 | 139.21 | 7.52 | 1,851.15 | 508 | 100 |
| ២ | ខេត្តត្បូងឃ្មុំ | - | 0.00 | 613.02 | 24.83 | 186.57 | 7.56 | 1,628.02 | 65.95 | 40.98 | 1.66 | 2,468.58 | 794 | 100 |
| ៣ | ខេត្តកណ្ដាល | - | 0.00 | 315.25 | 13.31 | 251.80 | 10.63 | 663.20 | 28.00 | 1,138.58 | 48.07 | 2,368.83 | 1,047 | 100 |
| ៤ | ខេត្តព្រៃវែង | 0.78 | 0.02 | 541.44 | 15.17 | 41.64 | 1.17 | 593.85 | 16.64 | 2,391.11 | 67.00 | 3,568.82 | 1,097 | 100 |
| ៥ | ខេត្តស្វាយរៀង | 58.50 | 2.14 | 333.74 | 12.22 | 18.02 | 0.66 | 555.87 | 20.35 | 1,765.65 | 64.63 | 2,731.78 | 764 | 100 |
| ៦ | ខេត្តតាកែវ | - | 0.00 | 359.73 | 14.99 | 40.06 | 1.67 | 1,320.06 | 55.00 | 680.09 | 28.34 | 2,399.94 | 689 | 100 |
| | សរុប | 69.98 | 0.46 | 2,699.67 | 18.25 | 780.64 | 5.80 | 5,683.19 | 39.29 | 6,155.62 | 36.20 | 15,389.09 | 4,899 | 100 |
| **ជុំវិញបឹងទន្លេសាប (៦ខេត្ត)** | | | | | | | | | | | | | | |
| ១ | ខេត្តបន្ទាយមានជ័យ | 14.67 | 0.49 | 342.93 | 11.52 | 111.49 | 3.75 | 1,826.99 | 61.39 | 680.02 | 22.85 | 2,976.11 | 2,071 | 100 |
| ២ | ខេត្តបាត់ដំបង | 7.01 | 0.13 | 378.06 | 6.79 | 17.53 | 0.32 | 4,161.66 | 74.78 | 1,000.71 | 17.98 | 5,564.97 | 2,140 | 100 |
| ៣ | ខេត្តកំពង់ធំ | 0.83 | 0.03 | 294.53 | 9.35 | 4.45 | 0.14 | 2,267.44 | 72.00 | 581.94 | 18.48 | 3,149.19 | 1,273 | 100 |
| ៤ | ខេត្តសៀមរាប | 101.86 | 3.94 | 493.92 | 19.11 | 31.14 | 1.20 | 1,411.40 | 54.60 | 546.86 | 21.15 | 2,585.18 | 472 | 100 |
| ៥ | ខេត្តកំពង់ឆ្នាំង | - | 0.00 | 553.77 | 28.37 | 27.11 | 1.39 | 1,314.86 | 67.36 | 56.23 | 2.88 | 1,951.96 | 672 | 100 |
| ៦ | ខេត្តពោធិ៍សាត់ | - | 0.00 | 374.11 | 19.83 | 3.13 | 0.17 | 1,283.98 | 68.05 | 225.71 | 11.96 | 1,886.94 | 580 | 100 |
| | **សរុប** | **124.37** | **0.76** | **2,437.32** | **15.83** | **194.86** | **1.16** | **12,266.33** | **66.36** | **3,091.48** | **15.88** | **18,114.34** | **7,208** | **100** |
| **ឆ្នេរសមុទ្រ (៤ខេត្ត)** | | | | | | | | | | | | | | |
| ១ | ខេត្តកំពត | - | 0.00 | 236.67 | 11.23 | 89.60 | 4.25 | 1,661.01 | 78.80 | 120.53 | 5.72 | 2,107.82 | 724 | 100 |
| ២ | ខេត្តព្រះសីហនុ | 23.36 | 6.13 | 31.30 | 8.22 | 76.42 | 20.07 | 239.24 | 62.83 | 10.48 | 2.75 | 380.80 | 202 | 100 |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ៣ | ខេត្តកែប | - | 0.00 | 24.50 | 14.82 | 16.36 | 9.90 | 114.61 | 69.34 | 9.83 | 5.95 | 165.29 | 67 | 100 |
| ៤ | ខេត្តកោះកុង | - | 0.00 | 71.91 | 9.25 | 44.03 | 5.67 | 658.24 | 84.72 | 2.80 | 0.36 | 776.98 | 216 | 100 |
| | **សរុប** | **23.36** | **1.53** | **364.38** | **10.88** | **226.41** | **9.97** | **2,673.10** | **73.92** | **143.64** | **3.69** | **3,430.89** | **1,209** | **100** |
| **ភ្នំនិងខ្ពង់រាប (៨ខេត្ត)** | | | | | | | | | | | | | | |
| ១ | ខេត្តកំពង់ស្ពឺ | 20.40 | 0.63 | 339.92 | 10.54 | 61.79 | 1.92 | 2,299.16 | 71.31 | 502.82 | 15.60 | 3,224.09 | 1,322 | 100 |
| ២ | ខេត្តក្រចេះ | - | 0.00 | 114.00 | 4.87 | 2.00 | 0.09 | 2,177.74 | 92.94 | 49.40 | 2.11 | 2,343.14 | 262 | 100 |
| ៣ | ខេត្តមណ្ឌលគិរី | - | 0.00 | - | 0.00 | 2.12 | 0.44 | 410.62 | 85.20 | 69.20 | 14.36 | 481.94 | 66 | 100 |
| ៤ | ខេត្តព្រះវិហារ | - | 0.00 | 145.01 | 9.34 | 3.80 | 0.24 | 1,403.26 | 90.41 | - | 0.00 | 1,552.07 | 468 | 100 |
| ៥ | ខេត្តរតនគិរី | - | 0.00 | 64.20 | 6.13 | 0.97 | 0.09 | 882.72 | 84.27 | 99.64 | 9.51 | 1,047.53 | 332 | 100 |
| ៦ | ខេត្តស្ទឹងត្រែង | - | 0.00 | 35.40 | 2.99 | 21.70 | 1.84 | 965.55 | 81.67 | 159.67 | 13.50 | 1,182.31 | 165 | 100 |
| ៧ | ខេត្តឧត្តរមានជ័យ | - | 0.00 | 74.94 | 5.95 | - | 0.00 | 1,164.08 | 92.36 | 21.42 | 1.70 | 1,260.44 | 384 | 100 |
| ៨ | ខេត្តប៉ៃលិន | - | 0.00 | 91.66 | 17.35 | 7.97 | 1.51 | 303.72 | 57.48 | 125.07 | 23.67 | 528.41 | 174 | 100 |
| | **សរុប** | **20.40** | **0.08** | **865.13** | **7.15** | **100.35** | **0.77** | **9,606.85** | **81.95** | **1,027.21** | **10.06** | **11,619.93** | **3,173** | **100** |

(ប្រភព : បញ្ជីសារពើភ័ណ្ឌផ្លូវជនបទ ក្រសួងអភិវឌ្ឍន៍ជនបទ ឆ្នាំ២០២៤)

## ឧបសម្ព័ន្ធ៤ : អត្រាគ្របដណ្តប់ទឹកស្អាតតាមគ្រួសារ និងអនាម័យកម្រិតមូលដ្ឋានតាមខ្នងផ្ទះ

| ល.រ. | រាជធានី ខេត្ត | ចំនួនគ្រួសារ | ចំនួនខ្នងផ្ទះ | អនាម័យមូលដ្ឋានតាមខ្នងផ្ទះ | | ទឹកស្អាតស្អាតមូលដ្ឋានតាមគ្រួសារ | |
|---|---|---|---|---|---|---|---|
| | | | | ចំនួន | % | ចំនួន | % |
| ១ | ភ្នំពេញ | 330065 | 297682 | 297595 | 99.97% | 330065 | 100.00% |
| តំបន់ទំនាបកណ្តាល | | | | | | | |
| ២ | កំពង់ចាម | 288026 | 230252 | 214135 | 93.00% | 274459 | 95.29% |
| ៣ | ត្បូងឃ្មុំ | 203910 | 175542 | 165748 | 94.42% | 192860 | 94.58% |
| ៤ | កណ្តាល | 316942 | 269115 | 265731 | 98.74% | 316942 | 100.00% |
| ៥ | ព្រៃវែង | 300153 | 257004 | 247877 | 96.45% | 297601 | 99.15% |
| ៦ | ស្វាយរៀង | 166458 | 138590 | 134970 | 97.39% | 166144 | 99.81% |
| ៧ | តាកែវ | 237504 | 221508 | 209308 | 94.49% | 230526 | 97.06% |
| | សរុប | 1512993 | 1292011 | 1237769 | 95.80% | 1478532 | 97.65% |
| តំបន់ជុំវិញបឹងទន្លេសាប | | | | | | | |
| ៨ | បន្ទាយមានជ័យ | 204912 | 170299 | 163049 | 95.74% | 147314 | 71.89% |
| ៩ | បាត់ដំបង | 298621 | 247858 | 235890 | 95.17% | 241883 | 81.00% |
| ១០ | កំពង់ធំ | 178304 | 174760 | 162872 | 93.20% | 160736 | 90.15% |
| ១១ | សៀមរាប | 263128 | 259514 | 239590 | 92.32% | 213019 | 80.96% |
| ១២ | កំពង់ឆ្នាំង | 153729 | 137392 | 134510 | 97.90% | 141469 | 92.02% |
| ១៣ | ពោធិ៍សាត់ | 133507 | 124220 | 108757 | 87.55% | 117518 | 88.02% |
| | សរុប | 1232201 | 1114043 | 1044668 | 93.77% | 1021939 | 84.01% |
| តំបន់ឆ្នេរសមុទ្រ | | | | | | | |
| ១៤ | កំពត | 166128 | 158369 | 149458 | 94.37% | 121273 | 73.00% |
| ១៥ | ព្រះសីហនុ | 54024 | 51503 | 49433 | 95.98% | 51911 | 96.09% |
| ១៦ | កែប | 11145 | 9350 | 9226 | 98.67% | 7143 | 64.09% |
| ១៧ | កោះកុង | 35207 | 31521 | 24128 | 76.55% | 34100 | 96.86% |
| | សរុប | 266504 | 250743 | 232245 | 92.62% | 214427 | 82.51% |

| | | | | | | | |
|---|---|---|---|---|---|---|---|
| តំបន់ភ្នំនិងខ្ពង់រាប | | | | | | | |
| ១៨ | កំពង់ស្ពឺ | 213686 | 206911 | 199785 | 96.56% | 166662 | 77.99% |
| ១៩ | ក្រចេះ | 107907 | 93882 | 84491 | 90.00% | 92832 | 86.03% |
| ២០ | មណ្ឌលគិរី | 24780 | 21549 | 15010 | 69.66% | 22675 | 91.51% |
| ២១ | ព្រះវិហារ | 69045 | 60270 | 54849 | 91.01% | 50559 | 73.23% |
| ២២ | រតនគិរី | 58892 | 45926 | 42467 | 92.47% | 45358 | 77.02% |
| ២៣ | ស្ទឹងត្រែង | 34958 | 29958 | 27176 | 90.71% | 33089 | 94.65% |
| ២៤ | ឧត្តរមានជ័យ | 68188 | 60051 | 55394 | 92.24% | 41124 | 60.31% |
| ២៥ | ប៉ៃលិន | 19625 | 18232 | 16836 | 92.34% | 16683 | 85.00% |
| | សរុប | 597081 | 536779 | 496008 | 92.40% | 468982 | 80.72% |
| | Grand Total | 3938844 | 3491258 | 3308285 | 94.76% | 3513945 | 89.21% |

(ប្រភព : ទិន្នន័យទឹកស្អាតនិងអនាម័យ ឆមាសទី២ ឆ្នាំ២០២៥)